មាតិកា

I-ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១១-០១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០១០៦/០០៦ ស្តីពី :
-ការតែងតាំងឯកឧត្តម **ហេង ពៅ** ជាអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ បន្ថែមលើមុខងារបច្ចុប្បន្ន ជាទីប្រឹក្សាផ្ទាល់ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។
-ត្រូវបានតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជូនឧត្តមសេនីយ៍ត្រី **ហេង ពៅ** ២២៨

II-រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

១២-០១-២០០៦ -អនុក្រឹត្យលេខ ០២ អនក្រ.បក ស្តីពីការប្តូរឈ្មោះនាយកដ្ឋានជនបរទេស ទៅជានាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ ២២៩
១២-០១-២០០៦ -អនុក្រឹត្យលេខ ២០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៣១
១២-០១-២០០៦ -អនុក្រឹត្យលេខ ២១ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៣២
១២-០១-២០០៦ -អនុក្រឹត្យលេខ ២២ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២៣៥
១២-០១-២០០៦ -អនុក្រឹត្យលេខ ២៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៣៦
១២-០១-២០០៦ -អនុក្រឹត្យលេខ ២៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៣៧
១៣-០១-២០០៦ -អនុក្រឹត្យលេខ ២៥ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ២៣៨
១៣-០១-២០០៦ -អនុក្រឹត្យលេខ ២៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៣៩

២-សេចក្តីសំរេច

១២-០១-២០០៦ -សេចក្តីសំរេចលេខ ០១ សសរ ស្តីពីការកែសំរួលសមាសភាពគណៈកម្មាធិការជាតិអភិនិយោគរបស់រដ្ឋលើ សហគ្រាសចំការកៅស៊ូក្រុមហ៊ុនសំភារៈកសិកម្ម និងក្រុមហ៊ុនជលផល ២៤០

III-ការិយាល័យបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១២-០១-២០០៦ -ប្រកាសអន្តរក្រសួងលេខ ០៣៣ សហវ.ប្រក ស្តីពីសោហ៊ុយលើសេវាសំណង់ ២៤២
១២-០១-២០០៦ -សារាចរលេខ ០០៥ សហវ ស្តីពីការណែនាំលើការអនុវត្តន៍ថវិកាឆ្នាំ ២០០៦ ២៥០

បញ្ជាក់ *: ឯកសារ ២ ខាងក្រោមនេះផ្ញើមកនាយកដ្ឋានរាជកិច្ចផុតកាលបរិច្ឆេទកំណត់នៃការចុះផ្សាយក្នុងរាជកិច្ច តែដោយខ្លឹមសារមានសារៈសំខាន់ និងមានវិសាលភាពអនុវត្តទូទាំងប្រទេស យើងខ្ញុំសូមយកមកចុះផ្សាយក្នុងរាជកិច្ចលេខនេះ !*

២៩-១២-២០០៥ -សេចក្តីសំរេចលេខ ០០៧ សសរ.សហវ.ពដ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ស្តីពីការកំណត់តម្លៃគិតពន្ធលើដីធ្លីមិនបានប្រើប្រាស់ ២៦៤

២_ទីស្តីការរដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

២៣-១២-២០០៥ -ប្រកាសលេខ ៦៧៨ ស.អ.យ ស្តីពីនីតិវិធីអនុវត្តរបបឧបត្ថម្ភគោលនយោបាយចំពោះជនពលី ជនមរណៈ ជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារ ៣០៥

សេចក្តីបញ្ជាក់ : ដោយមានកំហុសខាងបច្ចេកទេស រាជកិច្ចលេខនេះមានរំលងលេខទំព័រ ២៣០ មួយទំព័រ ប៉ុន្តែមិនមានប៉ះពាល់ដល់ខ្លឹមសារនៃឯកសារទេ អាស្រ័យហេតុនេះសូមមេត្តាអភ័យទោស ចំពោះកំហុសឆ្គងដោយអចេតនានេះ ។

សូមអរគុណ!

នស/រកត/០១០៦/០០៦

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម **ហេង ពៅ** ជាអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ បន្ថែមលើមុខងារបច្ចុប្បន្ន ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : ត្រូវបានតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជូនឧត្តមសេនីយ៍ត្រី **ហេង ពៅ** អត្តលេខ ០៣៤០ ។

មាត្រា ៣ : រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៦០១.០០៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០៦

លេខៈ ១៣៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការប្តូរឈ្មោះនាយកដ្ឋានជនបរទេស ទៅជា នាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ំ រេ ច

មាត្រា១ :

ត្រូវបានប្តូរឈ្មោះនាយកដ្ឋានជនបរទេស ទៅជានាយកដ្ឋានអន្តោប្រវេសន៍ ដែលស្ថិតនៅចំណុះនាយកដ្ឋានកណ្តាលសន្តិសុខ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ។

មាត្រា២ :

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់នាយកដ្ឋានដូចមានចែងក្នុងមាត្រា១ ត្រូវស្ថិតនៅជាធរមាន ។

មាត្រា៣ :

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនិងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៤ :

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *អគ្គលេខាធិការនៃរាជរដ្ឋាភិបាល*
- *ដូចមាត្រា៤*
- *កាលប្បវត្តិ-ឯកសារ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៖ ...២០...អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

ស ម្រេ ច

មាត្រា១ ៖ ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនមន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធ និង សប្បុរសជនចំនួន ១៥ រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចូលរួមកសាងសមិទ្ធផលនានាក្នុង ខេត្ត- ក្រុង មួយចំនួន នៃព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម ÷

១- ឯកឧត្តម **ទៀ ឈុដា**
២- ឯកឧត្តម **ឃឹម ប៊ូរ**
៣- លោក **ប៊ុន សង**
៤- លោក **ម៉េង ហៀង**
៥- លោក **តាន់ សេងខួន**
៦- លោក **សិទ្ធ សារគល**
៧- លោក **គីត សាលី**
៨- លោកវរសេនីយ៍ត្រី **សៀង ឡឹក**
៩- លោកវរសេនីយ៍ត្រី **ឈាង គឹមឈាន់**
១០- លោកវរសេនីយ៍ត្រី **ឆាយ ប៊ុនណា**
១១- លោកអនុសេនីយ៍ឯក **សួន សុជាតិ**
១២- លោកអនុសេនីយ៍ឯក **យិន ឆារ៉ា**
១៣- លោកអនុសេនីយ៍ឯក **អៀ សុផល**
១៤- លោកអនុសេនីយ៍ឯក **ឈាង ហាក់**
១៥- លោកអនុសេនីយ៍ទោ **យី រិទ្ធី**

មាត្រា២ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៦

ហ៊ុន សែន

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២១ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធ និង នាយទាហាន ពលទាហាន ក្នុងកងឯកភាពអង្គរក្ស សម្តេចនាយករដ្ឋមន្ត្រី ចំនួន ៥០ រូប ដែលមានស្នាដៃល្អក្នុងការចុះជួយប្រជាពលរដ្ឋ ពេលជួបប្រទះនូវគ្រោះធម្មជាតិផ្សេងៗ ក្នុងឆ្នាំ ២០០៥ ដូចមានរាយនាមខាងក្រោម ÷

ក_មេដាយមាសការងារ :

១- ឯកឧត្តម ឧត្តមសេនីយ៍ឯក **សឺង សំណាង** មេបញ្ជាការកងទ័ពអាកាស នៃកងយោធពលខេមរភូមិន្ទ
២- លោកវរសេនីយ៍ឯក **ជួន សុវណ្ណ** មេបញ្ជាការកងរាជអាវុធហត្ថខេត្តកណ្តាល
៣- លោកវរសេនីយ៍ឯក **ឡា វ៉ន្ន** មេបញ្ជាការកងរាជអាវុធហត្ថខេត្តតាកែវ
៤- លោកវរសេនីយ៍ឯក **សាយ សារុន** មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងតាកែវ
៥- លោកវរសេនីយ៍ឯក **ម៉ាន់ ម៉េងអៀង** មេបញ្ជាការរងកងរាជអាវុធហត្ថរាជធានីភ្នំពេញ
៦- លោកវរសេនីយ៍ឯក **ហ៊ឹម ណារិទ្ធ** កងហោះឧទ្ធម្ភាគចក្រដឹកជញ្ជូនគណៈប្រតិភូជាន់ខ្ពស់ ប្រចាំការបញ្ជាយសុវត្ថិភាពទួលក្រសាំង
៧- លោកវរសេនីយ៍ឯក **ឆេត សុភីរ** កងហោះឧទ្ធម្ភាគចក្រដឹកជញ្ជូនគណៈប្រតិភូជាន់ខ្ពស់ ប្រចាំការបញ្ជាយសុវត្ថិភាពទួលក្រសាំង
៨- លោកវរសេនីយ៍ឯក **ប៉ូច យាង** កងហោះឧទ្ធម្ភាគចក្រដឹកជញ្ជូនគណៈប្រតិភូជាន់ខ្ពស់ ប្រចាំការបញ្ជាយសុវត្ថិភាពទួលក្រសាំង
៩- លោកវរសេនីយ៍ទោ **ជួន សុតិនណារ៉ា** កងហោះឧទ្ធម្ភាគចក្រដឹកជញ្ជូនគណៈប្រតិភូជាន់ខ្ពស់ ប្រចាំការបញ្ជាយសុវត្ថិភាពទួលក្រសាំង
១០- លោកវរសេនីយ៍ទោ **ចាប សុជា** កងហោះឧទ្ធម្ភាគចក្រដឹកជញ្ជូនគណៈប្រតិភូជាន់ខ្ពស់ ប្រចាំការបញ្ជាយសុវត្ថិភាពទួលក្រសាំង

១១- លោកវរសេនីយ៍ទោ ង៉ូ ផាណា កងហោះដឹកជញ្ជូនគណៈប្រតិភូជាន់ខ្ពស់ ប្រចាំការបន្ទាយសុវត្ថិភាពទួលក្រសាំង

១២- លោកវរសេនីយ៍ទោ សួរ សារិទ្ធ កងហោះដឹកជញ្ជូនគណៈប្រតិភូជាន់ខ្ពស់ ប្រចាំការបន្ទាយសុវត្ថិភាពទួលក្រសាំង

១៣- លោកវរសេនីយ៍ទោ កែវ ប៊ុនណា កងហោះដឹកជញ្ជូនគណៈប្រតិភូជាន់ខ្ពស់ ប្រចាំការបន្ទាយសុវត្ថិភាពទួលក្រសាំង

១៤- លោកវរសេនីយ៍ទោ ហ៊ិន វឌ្ឍ កងហោះដឹកជញ្ជូនគណៈប្រតិភូជាន់ខ្ពស់ ប្រចាំការបន្ទាយសុវត្ថិភាពទួលក្រសាំង

១៥- លោកវរសេនីយ៍ទោ អ៊ុក បុណ្ណរស្មី កងហោះដឹកជញ្ជូនគណៈប្រតិភូជាន់ខ្ពស់ ប្រចាំការបន្ទាយសុវត្ថិភាពទួលក្រសាំង

១៦- លោកវរសេនីយ៍ទោ សាយ សាគង់ ជំនួយការឯកឧត្តម ទៅ ឌុល

១៧- លោកវរសេនីយ៍ទោ វៃ ពួរ ជំនួយការឯកឧត្តម ទៅ ឌុល

១៨- លោកវរសេនីយ៍ទោ សុស សារី ជំនួយការឯកឧត្តម ទៅ ឌុល

១៩- លោកវរសេនីយ៍ទោ អ៊ិត សុផាត នាយទាហានការពារផ្ទាល់ នៃកងឯកភាពអង្គរក្ស

២០- លោកវរសេនីយ៍ទោ ឃឹម សាធាន នាយទាហានការពារផ្ទាល់ នៃកងឯកភាពអង្គរក្ស

២១- លោកវរសេនីយ៍ទោ នួន សារិទ្ធ នាយទាហានការពារផ្ទាល់ នៃកងឯកភាពអង្គរក្ស

២២- លោកវរសេនីយ៍ទោ អាន រិទ្ធី នាយទាហានការពារផ្ទាល់ នៃកងឯកភាពអង្គរក្ស

២៣- លោកវរសេនីយ៍ទោ ឈុញ ប្លង់ ប្រធានការិយាល័យបុគលិក នាយកដ្ឋានអន្តោប្រវេសន៍

២៤- លោកវរសេនីយ៍ទោ សេង មហា មេបញ្ជាការរង កងរាជអាវុធហត្ថខេត្តតាកែវ

២៥- លោកវរសេនីយ៍ទោ ម៉ែន ស៊ីមន មេបញ្ជាការរង កងរាជអាវុធហត្ថខេត្តកំពង់ស្ពឺ

២៦-លោក ជីវ កេង ប្រធានតុលាការក្រុងភ្នំពេញ

២៧-លោក អ៊ិត សារឿន ព្រះរាជអាជ្ញា អមតុលាការរាជធានីភ្នំពេញ

២៨-លោក សុខ ជឿន ព្រះរាជអាជ្ញារង អមតុលាការរាជធានីភ្នំពេញ

២៩- លោក នួច សារិន អនុប្រធាននាយកដ្ឋានរដ្ឋបាល ទីស្តីការគណៈរដ្ឋមន្ត្រី

៣០- លោក គីម សច្ចាត ជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី និងជា អនុប្រធាននាយកដ្ឋានពិធីការ

៣១- លោក ចួន សរ ប្រធានមន្ទីរដែនដីនគរូបនីយកម្មសំណង់ និង សុរិយោដីខេត្តកណ្តាល

៣២- លោក គួច ចំរើន អភិបាលខ័ណ្ឌចំការមន រាជធានីភ្នំពេញ

៣៣- លោក គីម គន្ធា មន្ត្រីសាខាគយ និងរដ្ឋាករ ខេត្តបាត់ដំបង

៣៤- លោក ស្រី អួន អនុប្រធានមន្ទីរដែនដីនគរូបនីយកម្មសំណង់ និង សុរិយោដីខេត្តសៀមរាប

៣៥- លោកវរសេនីយ៍ត្រី សាំង សុខា ជំនួយការឯកឧត្តម ស្នងការនគរបាលរាជធានីភ្នំពេញ

៣៦- លោកវរសេនីយ៍ត្រី ជួន ណារិន្ទ នាយការិយាល័យព្រហ្មទ័ណ្ឌកំរិតធ្ងន់ ស្នងការនគរបាលរាជធានីភ្នំពេញ

៣៧- លោកវរសេនីយ៍ត្រី លី រ៉ាស៊ុ នាយរងទី១ការិយាល័យព្រហ្មទ័ណ្ឌកំរិតស្រាល ស្នងការនគរបាលរាជធានីភ្នំពេញ

៣៨- លោកវរសេនីយ៍ត្រី ហ៊ុន សុខ អធិការនគរបាលខ័ណ្ឌទួលគោក នៃ ស្នងការនគបាលរាជធានីភ្នំពេញ

៣៩- លោកវរសេនីយ៍ត្រី ហ៊ុន សុធី អធិការនគរបាលខ័ណ្ឌទួលគោក នៃស្នងការនគរបាលរាជធានីភ្នំពេញ

៤០- លោកវរសេនីយ៍ត្រី ហួត ចាន់យ៉ារ៉ាវ៉ន់ អធិការនគរបាលខ័ណ្ឌមានជ័យ នៃស្នងការនគរបាលរាជធានីភ្នំពេញ

៤១- លោកវរសេនីយ៍ត្រី សុខ សំណាង ប្រធាននគរបាលអន្តោប្រវេសន៍ ព្រលានយន្តហោះអន្តរជាតិខេត្តសៀមរាប

៤២- លោកវរសេនីយ៍ត្រី ដាំ បូរ៉ាត្ន កងហោះដឹកជញ្ជូនគណៈប្រតិភូជាន់ខ្ពស់ ប្រចាំការបន្ទាយសុវត្ថិភាពទួលក្រសាំង

៤៣- លោកវរសេនីយ៍ត្រី យឹម រ៉ុង កងហោះដឹកជញ្ជូនគណៈប្រតិភូជាន់ខ្ពស់ ប្រចាំការបន្ទាយសុវត្ថិភាពទួលក្រសាំង

៤៤- លោកវរសេនីយ៍ត្រី យិន យ៉េត នាយរងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

៤៥- លោកវរសេនីយ៍ត្រី **ឈឹម [illegible]** ជំនួយការឯកឧត្តមនាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

៤៦- លោកវរសេនីយ៍ត្រី **មុត ចន្ទូ** នាយទាហានការពារផ្ទាល់ នៃកងឯកភាពអង្គរក្ស

៤៧- លោកវរសេនីយ៍ត្រី **ឈឹម សុខវណ្ណារិន** នាយទាហានការពារផ្ទាល់ នៃកងឯកភាពអង្គរក្ស

៤៨- លោកវរសេនីយ៍ត្រី **ខួន មករា** នាយទាហានការពារផ្ទាល់ នៃកងឯកភាពអង្គរក្ស

៤៩- លោកអនុសេនីយ៍ឯក **ម៉ុខ លមមាច** ការិយាល័យអភិវឌ្ឍន៍ក្រាំងចេក នៃកងឯកភាពអង្គរក្ស

៥០- លោកអនុសេនីយ៍ឯក **ខួន លីណា** ការិយាល័យអភិវឌ្ឍន៍ក្រាំងចេក នៃកងឯកភាពអង្គរក្ស

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

__កន្លែងទទួល__ :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៣២ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៙

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សរិទ្ធិ** ជូនជាកិច្ចបច្ឆាមរណៈ ចំពោះសព លោក **ឆេព សុជាតិ** មន្ត្រីគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដែលមានស្នាដៃល្អក្នុងការបំរើជាតិមាតុភូមិ ហើយបានទទួលមរណភាព នាពេលកន្លងទៅនេះ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ [illegible] ឆ្នាំ ២០០៦

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ស ម្រេ ច

មាត្រា ១ : ត្រូវបានតែងតាំងអ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ សុជាតិវង្ស** ជាជំនួយការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៦

ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ_កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៣រូប ដែលបានចំណាយថវិកាផ្ទាល់ខ្លួន ចូលរួមជួយកសាងកុដិ ០១ខ្នង ២ជាន់ បណ្តោយ ១៤ម៉ែត្រ ទទឹង ៨ម៉ែត្រ ព្រមទាំងបំពាក់គ្រឿងសង្ហារិម នៅវត្តបទុមវតី រាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

- លោកស្រី **ចាយ ម៉ូរី** ថវិកាចំនួន ១២.០០០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

១-លោក **ហ៊ាង បូផា** ថវិកាចំនួន ៧.៥០០ ដុល្លារ

២-លោក **វ៉ាន់ សុផល** ថវិកាចំនួន ៥.២០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៣៥...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី
៙
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនលោកស្រី **Elisabeth Pimay** ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជាអ្នកទទួលបន្ទុកអប់រំ ផ្នែកសុខភាព និងការអភិវឌ្ឍន៍សង្គម នៅព្រះរាជាណាចក្រកម្ពុជា ពីឆ្នាំ ១៩៨៦ ដល់ ឆ្នាំ ២០០៥ សម្រេចបានលទ្ធផលល្អប្រសើរ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៦. អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/ ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១: ត្រូវបានប្រគល់ភារកិច្ចជូនលោក **នួន ជីវន្ត** អនុមន្ត្រីថ្នាក់លេខ ៥ បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអាមេរិក អោយបំពេញមុខងារ ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានអាស៊ាន នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដោយរក្សាការឡើងឋានន្តរស័ក្តិនិងថ្នាក់ ទៅតាមគោលការណ៍ដែលមានចែងក្នុងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ។

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...០១...ស.ស.រ

សេចក្តីសំរេច

ស្តីពី

ការកែសំរួលសមាសភាពគណៈកម្មាធិការជាតិអទិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និងក្រុមហ៊ុនជលផល

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញអនុក្រឹត្យលេខ៣០ អនក្រ បក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៣ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអទិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និង ក្រុមហ៊ុនជលផល

-បានឃើញសេចក្តីសំរេចលេខ ៧៧ ស.ស.រ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិអទិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និង ក្រុមហ៊ុនជលផល

-យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

ប្រការ១ : ត្រូវបានតែងតាំង ឯកឧត្តម **សួន ម៉េងគា** អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជា **អនុប្រធាន** គណៈកម្មាធិការជាតិអទិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និង ក្រុមហ៊ុនជលផល ជំនួសឯកឧត្តម **ចាន់ សុធី** ដែលជាអនុប្រធានគណៈកម្មាធិការជាតិអទិនិយោគរបស់រដ្ឋ ដូចបានតែងតាំងក្នុងសេចក្តីសំរេចលេខ ៧៧ ស.ស.រ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ។

ប្រការ២ ៖ បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៣ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និង សាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និង ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ...០៣៣...សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមករា ឆ្នាំ ២០០៦

ប្រកាសអន្តរក្រសួង
ស្តីពី
សោហ៊ុយលើសេវាសំណង់

❖❖❖❖❖

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រម លេខ ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំទឹកដី នគរោបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យ លេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យ លេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យ លេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់

/.

- បានឃើញអនុក្រឹត្យ លេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វ័យតរាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យ លេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាស លេខ ៧៥ប្រក.ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាសក្រុមហ៊ុនសិក្សាគំរោងប្លង់ និងសាងសង់
- បានឃើញប្រកាស លេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ
- អនុវត្តតាមសារាចរណែនាំ លេខ ០០២ សហវ.ម ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីរដ្ឋទេយ្យចំណូល
- យោងតាមការចាំបាច់លើការងារគ្រប់គ្រងវិស័យសំណង់ ។

សំរេច

ប្រការ ១ .-

ត្រូវបានបង្កើតសោហ៊ុយលើសេវាសំណង់ ក្នុងការពិនិត្យ និងសំរេចលើការសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន លិខិតបិទការដ្ឋាន ឬវិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ លើការចុះបញ្ជីប្រកបអាជីវកម្មសាងសង់ និងសិក្សាគំរោងប្លង់ ។

ប្រការ ២ .-

សោហ៊ុយលើសេវាសំណង់មានចែងក្នុងប្រការ ១ ខាងលើ ត្រូវបានកំណត់ដូចតារាងខាងក្រោមនេះ ៖

I- លិខិតអនុញ្ញាត ដែលជាសមត្ថកិច្ចរបស់សាលា ខេត្ត ក្រុង

ល.រ	រាយមុខសេវាកម្ម	សោហ៊ុយសេវា (គិតជាប្រាក់រៀល)											ទឹកប្រាក់សរុប
		ក. ពាក្យសុំ	ខ. តែម	គ. បង្កាន់ដៃទទួលពាក្យ	ឃ. ផ្ទៃក្រឡាគម្រោលសំណង់								
					≤១០០ម²	≤២០០ម²	≤៣០០ម²	≤៤០០ម²	≤៥០០ម²	≤១០០០ម²	≤២០០០ម²	≤៣០០០ម²	
	ក- លិខិតអនុញ្ញាតសាងសង់												
១	*សំណង់លំនៅឋាន*												
	១.១ ភូមិគ្រឹះ	២០០០	២០០០	៥០០	១២០០០០	១៤០០០០	១៦០០០០	១៨០០០០	២០០០០០	២៤០០០០	២៨០០០០	៣២០០០០	ក+ខ+គ+ឃ
	១.២ ផ្ទះល្វែង	២០០០	២០០០	៥០០	៨០០០០	១០០០០០	១២០០០០	១៤០០០០	១៦០០០០	២០០០០០	២៤០០០០	២៨០០០០	ដ
	១.៣ ថ្មក្រោម ឈើលើ	២០០០	២០០០	៥០០	៤០០០០	៦០០០០	៨០០០០	១០០០០០	១២០០០០	១៦០០០០	២០០០០០	២៤០០០០	ដ
២	*សំណង់អគារផ្សេងៗក្រៅពីលំនៅឋាន*	២០០០	២០០០	៥០០	១៤០០០០	១៦០០០០	១៨០០០០	២០០០០០	២២០០០០	២៦០០០០	៣០០០០០	៣៤០០០០	ដ

ល.រ	វាយមុខសេវាកម្ម	សោហ៊ុយសេវា (គិតជាប្រាក់រៀល)											ទឹកប្រាក់សរុប
		ក. ពាក្យសុំ	ខ. តែម	គ. បង្កាន់ដៃទទួលពាក្យ	ឃ. ផ្ទៃក្រឡាកម្រាលសំណង់								
					≤១០០ម²	≤២០០ម²	≤៣០០ម²	≤៤០០ម²	≤៥០០ម²	≤១០០០ម²	≤២០០០ម²	≤៣០០០ម²	
ខ- លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែម រុះរើ ជួសជុល													
១	សំណង់លំនៅឋាន												
	១.១ ភូមិគ្រឹះ	២០០០	២០០០	៥០០	៨០០០០	១០០០០០	១២០០០០	១៤០០០០	១៦០០០០	២០០០០០	២៤០០០០	២៨០០០០	ក+ខ+គ+ឃ
	១.២ ផ្ទះល្វែង	២០០០	២០០០	៥០០	៤០០០០	៦០០០០	៨០០០០	១០០០០០	១២០០០០	១៦០០០០	២០០០០០	២៤០០០០	ដ
	១.៣ ផ្ទះក្រោម ឈើលើ	២០០០	២០០០	៥០០	២០០០០	៤០០០០	៦០០០០	៨០០០០	១០០០០០	១៤០០០០	១៨០០០០	២២០០០០	ដ
២	សំណង់អគារផ្សេងៗ ក្រៅពីលំនៅឋាន	២០០០	២០០០	៥០០	១០០០០០	១២០០០០	១៤០០០០	១៦០០០០	១៨០០០០	២២០០០០	២៦០០០០	៣០០០០០	ដ
គ- លិខិតអនុញ្ញាតបើកការដ្ឋាន													
១	សំណង់លំនៅឋាន												
	១.១ ភូមិគ្រឹះ	២០០០	២០០០	៥០០	២០០០០	២៥០០០	៣០០០០	៣៥០០០	៤០០០០	៦០០០០	៨០០០០	១០០០០០	ដ
	១.២ ផ្ទះល្វែង	២០០០	២០០០	៥០០	១០០០០	១៥០០០	២០០០០	២៥០០០	៣០០០០	៥០០០០	៧០០០០	៩០០០០	ដ
	១.៣ ផ្ទះក្រោម ឈើលើ	២០០០	២០០០	៥០០	៥០០០	១០០០០	១៥០០០	២០០០០	២៥០០០	៤៥០០០	៦៥០០០	៨៥០០០	ដ
២	សំណង់អគារផ្សេងៗ ក្រៅពីលំនៅឋាន	២០០០	២០០០	៥០០	៣០០០០	៣៥០០០	៤០០០០	៤៥០០០	៥០០០០	៧០០០០	៩០០០០	១១០០០០	ដ
ឃ- លិខិតបិទការដ្ឋាន ឬ វិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ													
១	សំណង់លំនៅឋាន												
	១.១ ភូមិគ្រឹះ	២០០០	២០០០	៥០០	២៥០០០	៣០០០០	៣៥០០០	៤០០០០	៤៥០០០	៦៥០០០	៨៥០០០	១០៥០០០	ដ
	១.២ ផ្ទះល្វែង	២០០០	២០០០	៥០០	១៥០០០	២០០០០	២៥០០០	៣០០០០	៣៥០០០	៥៥០០០	៧៥០០០	៩៥០០០	ដ
	១.៣ ផ្ទះក្រោម ឈើលើ	២០០០	២០០០	៥០០	១០០០០	១៥០០០	២០០០០	២៥០០០	៣០០០០	៥០០០០	៧០០០០	៩០០០០	ដ
២	សំណង់អគារផ្សេងៗ ក្រៅពីលំនៅឋាន	២០០០	២០០០	៥០០	៣៥០០០	៤០០០០	៤៥០០០	៥០០០០	៥៥០០០	៧៥០០០	៩៥០០០	១១៥០០០	ដ

II- លិខិតអនុញ្ញាត ដែលជាសមត្ថកិច្ចក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ល.រ	វាយមុខសេវាកម្ម	សោហ៊ុយសេវា (គិតជាប្រាក់រៀល)											ទឹកប្រាក់សរុប
		ក. ពាក្យសុំ	ខ. តែម	គ. បង្កាន់ដៃទទួលពាក្យ	ឃ. ផ្ទៃក្រឡាកម្រាលសំណង់								
					≤៤០០០ម²	≤៦០០០ម²	≤១០០០០ម²	≤២០០០០ម²	≤៤០០០០ម²	≤៦០០០០ម²	≤១០០០០០ម²	>១០០០០០ម²	
ក- លិខិតអនុញ្ញាតសាងសង់													
១	សំណង់លំនៅឋាន	២០០០	២០០០	៥០០	៣៦០០០០	៤៤០០០០	៦០០០០០	៦៨០០០០	៧៦០០០០	៨៤០០០០	១០០០០០០	១៥០០០០០	ក+ខ+គ-ឃ
២	សំណង់អគារផ្សេងៗ ក្រៅពីលំនៅឋាន	២០០០	២០០០	៥០០	៣៨០០០០	៤៦០០០០	៦២០០០០	៧០០០០០	៧៨០០០០	៨៦០០០០	១០២០០០០	១៥២០០០០	ដ

ល.រ	រាយមុខសេវាកម្ម	សោហ៊ុយសេវា (គិតជាប្រាក់រៀល)											ទឹកប្រាក់សរុប
		ក. ពាក្យសុំ	ខ. តែម	គ. បង្កាន់ដៃទទួលពាក្យ	ឃ. ផ្ទៃក្រឡាកម្រាលសំណង់								
					≤៤០០ម៉ែ	≤៦០០ម៉ែ	≤១០០០ម៉ែ	≤២០០០ម៉ែ	≤៤០០០ម៉ែ	≤៦០០០ម៉ែ	≤១០០០០ម៉ែ	>១០០០០ម៉ែ	
ខ- លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែម រុះរើ ជួសជុល													
១	*សំណង់លំនៅឋាន*	២០០០	២០០០	៥០០	៣២០០០០	៤០០០០០	៥៦០០០០	៦៤០០០០	៧២០០០០	៨០០០០០	៩៦០០០០	១៤៦០០០០	ក+ខ+គ+ឃ
២	*សំណង់អគារផ្សេងៗក្រៅពីលំនៅឋាន*	២០០០	២០០០	៥០០	៣៤០០០០	៤២០០០០	៥៨០០០០	៦៦០០០០	៧៤០០០០	៨២០០០០	៩៨០០០០	១៤៨០០០០	ដ
គ- លិខិតអនុញ្ញាតបើកការដ្ឋាន													
១	*សំណង់លំនៅឋាន*	២០០០	២០០០	៥០០	១៤០០០០	២២០០០០	៣៨០០០០	៤៦០០០០	៥៤០០០០	៦២០០០០	៧៨០០០០	១២៨០០០០	ដ
២	*សំណង់អគារផ្សេងៗក្រៅពីលំនៅឋាន*	២០០០	២០០០	៥០០	១៥០០០០	២៣០០០០	៣៩០០០០	៤៧០០០០	៥៥០០០០	៦៣០០០០	៧៩០០០០	១២៩០០០០	ដ
ឃ- លិខិតបិទការដ្ឋាន ឬ វិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ													
១	*សំណង់លំនៅឋាន*	២០០០	២០០០	៥០០	១៤៥០០០	២២៥០០០	៣៨៥០០០	៤៦៥០០០	៥៤៥០០០	៦២៥០០០	៧៨៥០០០	១២៨៥០០០	ដ
២	*សំណង់អគារផ្សេងៗក្រៅពីលំនៅឋាន*	២០០០	២០០០	៥០០	១៥៥០០០	២៣៥០០០	៣៩៥០០០	៤៧៥០០០	៥៥៥០០០	៦៣៥០០០	៧៩៥០០០	១២៩៥០០០	ដ

ផ្ទៃក្រឡាកម្រាលសំណង់ ដែលត្រូវយកសោហ៊ុយលើសេវាចំពោះការសាងសង់ពង្រីកបន្ថែម រុះរើ ជួសជុល គឺត្រូវកំណត់យកតែផ្ទៃក្រឡាកម្រាលសំណង់សាងសង់ពង្រីកបន្ថែម រុះរើ ជួសជុល ដោយមិនបូកបញ្ចូលនូវផ្ទៃក្រឡាកម្រាលសំណង់មានស្រាប់ ។

III- ការចុះបញ្ជីប្រកបអាជីវកម្ម ដែលជាសមត្ថកិច្ចមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង

ល.រ	សោហ៊ុយសេវា (គិតជាប្រាក់រៀល)						
	ប្រភេទ	ក. ពាក្យសុំ	ខ. តែមប្រិ	គ. បង្កាន់ដៃទទួលពាក្យ	ឃ. វិញ្ញាបនប័ត្រ	ង. សេវាប្រតិបត្តិ	ទឹកប្រាក់សរុប
ក- ចុះបញ្ជីលើកដំបូង							
១	*ក្រុមជាងសំណង់*	២០០០	២០០០	៥០០	២០០០	៦០០០០	ក+ខ+គ+ឃ+ង
ខ- បន្តសុពលភាព							
២	*ក្រុមជាងសំណង់*	២០០០	២០០០	៥០០	២០០០	៤០០០០	ដ

IV- ការចុះបញ្ជីប្រកបអាជីវកម្ម ដែលជាសមត្ថកិច្ចក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ល.រ	សោហ៊ុយសេវា (គិតជាប្រាក់រៀល)						
	ប្រភេទ	ក. ពាក្យសុំ	ខ. តែម	គ. បង្កាន់ដៃទទួលពាក្យ	ឃ. វិញ្ញាបនបត្រ	ង. សេវាប្រតិបត្តិតាមប្រភេទ ចំណាត់ថ្នាក់នីមួយៗ	ទឹកប្រាក់សរុប
ក- ចុះបញ្ជីលើកដំបូង							
១	ប្រភេទ ៣ (តូច)	២០០០	២០០០	៥០០	២០០០	១០០០០០	ក+ខ+គ+ឃ+ង
២	ប្រភេទ២ (មធ្យម)	២០០០	២០០០	៥០០	២០០០	២០០០០០	ដ
៣	ប្រភេទ១ (ធំ)	២០០០	២០០០	៥០០	២០០០	៣០០០០០	ដ
ខ- បន្តសុពលភាព							
១	ប្រភេទ ៣ (តូច)	២០០០	២០០០	៥០០	២០០០	៨០០០០	ដ
២	ប្រភេទ២ (មធ្យម)	២០០០	២០០០	៥០០	២០០០	១៤០០០០	ដ
៣	ប្រភេទ១ (ធំ)	២០០០	២០០០	៥០០	២០០០	២០០០០០	ដ
គ- ដំឡើងឋានៈប្រភេទ							
ល.រ	សោហ៊ុយសេវា (គិតជាប្រាក់រៀល)						
	ប្រភេទ សុំដំឡើង	ក. ពាក្យសុំ	ខ. តែម	គ. បង្កាន់ដៃទទួលពាក្យ	ឃ. វិញ្ញាបនបត្រ	ង. សេវាប្រតិបត្តិតាមប្រភេទ ចំណាត់ថ្នាក់នីមួយៗ	ទឹកប្រាក់សរុប
១	ប្រភេទ៣ (តូច) -ប្រភេទ២ (មធ្យម)	២០០០	២០០០	៥០០	២០០០	១៥០០០០	ក+ខ+គ+ឃ+ង
២	ប្រភេទ២ (មធ្យម) -ប្រភេទ១ (ធំ)	២០០០	២០០០	៥០០	២០០០	២៥០០០០	ដ

ប្រការ ៣ .-

ម្ចាស់សំណង់ត្រូវទទួលបន្ទុកបន្ថែមលើថ្លៃបង្គោល និងការដាំបង្គោល ។

ចំពោះសំណង់ដែលមានទីតាំងឆ្ងាយលើសពី ៥០គីឡូម៉ែត្រពីអង្គភាពជំនាញ ម្ចាស់សំណង់ត្រូវទទួលបន្ទុកបន្ថែមលើ ÷

១- សោហ៊ុយធ្វើដំណើរស្នាក់នៅ ហូបចុករបស់មន្ត្រីជំនាញ

២- ចំពោះតំបន់ដាច់ស្រយាល សោហ៊ុយលើសេវាសំណង់ត្រូវគិតបន្ថែម ២០% លើសោហ៊ុយសេវាសំណង់សរុប ។

ប្រការ ៤ .-

រាល់ទំរង់បែបបទ និងសំណុំឯកសារដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តតាមនីតិវិធីនៃការសុំលិខិតអនុញ្ញាតជាធរមាន ។

ប្រការ ៥ .-

ការបង់ប្រាក់ និងការទទួលប្រាក់ចំណូលពីសោហ៊ុយលើសេវាសំណង់ ត្រូវអនុវត្តតាមរយៈរដ្ឋទេយ្យករចំណូលនៅថ្នាក់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ឬ ថ្នាក់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ប្រការ ៦ .-

ការគ្រប់គ្រងចំណូលពីសោហ៊ុយលើសេវាសំណង់ ត្រូវអនុវត្តតាមនីតិវិធីនៃកិច្ចប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ។

ប្រការ ៧ .-

ចំណូលពីសោហ៊ុយលើសេវាសំណង់ត្រូវបង់ ១០០%ចូលថវិការដ្ឋ ដោយកត់ត្រាក្នុងជំពូក ២១ ប្រការ ០៣ កថាខណ្ឌ ៣០ ថវិកាខេត្ត ក្រុង និងថវិកាឃុំ សង្កាត់នៅគេនាគារជាតិ និងខេត្ត ក្រុង ។

ប្រការ ៨ .-

ចំណូលពីសោហ៊ុយលើសេវាសំណង់ ត្រូវបានកំណត់បែងចែកដូចខាងក្រោម ÷

ក-ចំណូលពីសោហ៊ុយលើសេវាផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន លិខិតបិទការដ្ឋាន ឬវិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ សំរាប់សមត្ថកិច្ចសាលាខេត្ត ក្រុង ត្រូវបានបែងចែកដូចតទៅ ÷

- ៣០% សំរាប់បង់ចូលថវិការដ្ឋ
- ៣០% ជាចំណែករបស់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសំរាប់ចាត់ចែងផ្តល់ដល់អង្គភាពជំនាញក្រោមឱវាទ
- ៣០% សំរាប់បំរើអោយគុណប្រយោជន៍ថវិកា ខេត្ត ក្រុង ក្នុងនោះមាន ១០% ជាចំណែករបស់ស្រុក ខណ្ឌ
- ១០% សំរាប់បំរើអោយគុណប្រយោជន៍ថវិកា របស់ឃុំ សង្កាត់ ។

ខ-ចំណូលពីសោហ៊ុយលើសេវាផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន លិខិតបិទការដ្ឋាន ឬ វិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ សំរាប់សមត្ថកិច្ចក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានបែងចែកដូចតទៅ ÷

- ៣០% សំរាប់បង់ចូលថវិការដ្ឋ

- ៣៥% ជាចំណែករបស់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសំរាប់ចាត់ចែងផ្តល់ដល់អង្គភាពជំនាញក្រោមឱវាទ
- ២៥% សំរាប់បំរើអោយគុណប្រយោជន៍ថវិកា ខេត្ត ក្រុង ក្នុងនោះមាន ៨% ជាចំណែករបស់ស្រុក ខណ្ឌ
- ១០% សំរាប់បំរើអោយគុណប្រយោជន៍ថវិកា របស់ឃុំ សង្កាត់ ។

គ- ចំណូលពីសោហ៊ុយលើសេវាចុះបញ្ជីប្រកបអាជីវកម្ម សំរាប់សមត្ថកិច្ចមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ត្រូវបានបែងចែកដូចតទៅ ÷

- ៤០% សំរាប់បង់ចូលថវិការដ្ឋ
- ៣៥% ជាចំណែករបស់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសំរាប់ចាត់ចែងផ្តល់ដល់អង្គភាពជំនាញក្រោមឱវាទ
- ២៥% សំរាប់បំរើអោយគុណប្រយោជន៍ថវិកា ខេត្ត ក្រុង ។

ឃ- ចំណូលពីសោហ៊ុយលើសេវាចុះបញ្ជីប្រកបអាជីវកម្ម សំរាប់សមត្ថកិច្ចក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានបែងចែកដូចតទៅ÷

- ៣០% សំរាប់បង់ចូលថវិការដ្ឋ
- ៧០% ជាចំណែករបស់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសំរាប់ចាត់ចែងផ្តល់ដល់អង្គភាពជំនាញក្រោមឱវាទ ។

ប្រការ ៩ ៈ

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង និងអគ្គនាយកដ្ឋានជំនាញពាក់ព័ន្ធ ត្រូវបូកសរុបធ្វើរបាយការណ៍នៃចំណូលនេះជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុង១ត្រីមាសម្តង ដោយភ្ជាប់មកជាមួយនូវសលាកប័ត្របង់ប្រាក់ ។

ផ្អែកលើការបូកសរុបស្ថានភាពបង់ចំណូលប្រចាំត្រីមាស អង្គភាពដែលមានចំណែកត្រូវលើកសំណើសុំចំណាយក្នុងរង្វង់ភាគរយ (%) នៃចំណូលរបស់ខ្លួន ដែលបានបង់ចូលថវិកាតាមបណ្តាថ្នាក់រៀង១ខ្លួន ទៅអង្គភាពហិរញ្ញវត្ថុ ដើម្បីពិនិត្យសំរេចផ្តល់ជូនតាមចំណែកដែលត្រូវបានទទួល តែត្រូវភ្ជាប់មកជាមួយនូវ ÷

- សលាកប័ត្របង់ប្រាក់ចំណូលពីសោហ៊ុយលើសេវាសំណង់

- របាយការណ៍ចំណាយនៃចំណែកភាគរយ (%) របស់ខ្លួន ដែលថវិការដ្ឋបានបើកផ្តល់លើកមុន ដោយមានភ្ជាប់មកជាមួយនូវសក្ខីប័ត្រគ្រប់គ្រាន់ និងត្រឹមត្រូវ ។

នីតិវិធីនៃការបើក ផ្តល់ ចំណាយ ត្រូវធ្វើឡើងតាមរយៈអាណត្តិបើកប្រាក់ ដោយកត់ត្រានៅក្នុងជំពូក ១០ ប្រការ ០២ កថាខណ្ឌ ០៣ វាក្យខណ្ឌ ០៧ ដែលមានអាទិភាពក្នុងការបើកផ្តល់សាច់ប្រាក់ ។

ប្រការ ១០.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ១១.-

អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋានជំនាញ និងអង្គភាពពាក់ព័ន្ធ ដែលស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានជំនាញ និងអង្គភាពពាក់ព័ន្ធ ដែលស្ថិតក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អ៊ឹម ឈុនលឹម

<u>**ចំលងជូន :**</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អាជ្ញាធរសវនកម្មជាតិ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត ក្រុង
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..00៥......សហវ.....

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៦

សារាចរ

ស្តីពី

ការណែនាំលើការអនុវត្តន៍ថវិកាឆ្នាំ ២០០៦

I. សេចក្តីផ្តើម

១. ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ។ ដើម្បីអនុវត្តច្បាប់នេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ១៥៣ អនក្រ.ប.ក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការផ្ទេរថវិកា អនុក្រឹត្យលេខ ១៥៤ អនក្រ.ប.ក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ និង អនុក្រឹត្យលេខ ១៥៥ អនក្រ.ប.ក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ។ ដោយផ្អែកលើមូលដ្ឋាននៃអនុក្រឹត្យនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានចេញប្រកាសលេខ ៩៨៨_សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូលថវិកាទូទៅរបស់រដ្ឋសំរាប់ ការគ្រប់គ្រងឆ្នាំ ២០០៥ ប្រកាសលេខ ៩៨៩ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណាយឥណទានថវិកាផ្ទៃក្នុងជំពូកតាមប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ និង ប្រកាសលេខ ៩៩០ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការផ្ទេរឥណទានថវិកា ។ ដើម្បីឱ្យការអនុវត្តន៍ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ មានដំណើរការប្រកបដោយលទ្ធផលល្អ និង មានប្រសិទ្ធភាពខ្ពស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការណែនាំលើការអនុវត្តន៍ថវិការដ្ឋ ឆ្នាំ ២០០៦ ដែលមានតាមលំដាប់លំដោយដូចខាងក្រោម ។

២- ថវិកាឆ្នាំ ២០០៦ ត្រូវបានរៀបចំឡើងដោយផ្អែកលើកម្មវិធីគោលនយោបាយ ៧៣ ចំណុចរបស់រាជរដ្ឋាភិបាលនីតិកាលទី ៣ នៃរដ្ឋសភា ដែលសំដៅបំពីអោយការអនុវត្ត ***ផែនការយុទ្ធសាស្ត្រជាតិសំរាប់ការអភិវឌ្ឍន៍ (National Strategy Development Plan-NSDP)*** ការបន្តអនុវត្តន៍ ***យុទ្ធសាស្ត្រជាតិ***

កាត់បន្ថយភាពក្រីក្រ (National Poverty Reduction Strategy-NPRS) និង ជាពិសេស ការអនុវត្តន៍ *«យុទ្ធសាស្ត្រចតុកោណ» (Rectangular Strategy)*-ដើម្បី *កំណើន ការងារ សមធម៌* និង *ប្រសិទ្ធភាព* ។ ជាក់ស្តែង ថវិការដ្ឋឆ្នាំ ២០០៦ បានបង្ហាញពីឆន្ទៈនយោបាយដ៏មោះមុតក្នុងការបន្តអនុវត្តកម្មវិធីកំណែទំរង់លើគ្រប់ផ្នែករបស់រាជរដ្ឋាភិបាលដូចជា (១) ការបន្តអនុវត្តកម្មវិធីកែទំរង់ហិរញ្ញវត្ថុសាធារណៈ ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ (២) ការអនុវត្តន៍កំណែទំរង់រចនាសម្ព័ន្ធ ដើម្បីពង្រឹងបរិស្ថានអំណោយផលសម្រាប់ការអភិវឌ្ឍន៍ផ្នែកឯកជន (៣) ការអនុវត្តន៍នូវកំណែទម្រង់ការគ្រប់គ្រងដីធ្លី ដើម្បីលើកស្ទួយ និង ប្រែក្លាយវិស័យកសិកម្មអោយទៅជាមូលដ្ឋានរឹងមាំនៃកំណើនសេដ្ឋកិច្ច និង បំរើអោយគោលដៅនៃការកាត់បន្ថយភាពក្រីក្រ (៤) ការពង្រឹងប្រព័ន្ធធនាគារ និង វិស័យធានារ៉ាប់រង និង ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុទាំងមូល ដើម្បីគៀរគរធនធានហិរញ្ញវត្ថុសម្រាប់ការធ្វើហិរញ្ញប្បទានគម្រោងរបស់ផ្នែកឯកជន (៥) ការកសាង និង ពង្រឹងការអនុវត្តន៍ច្បាប់ និង បទបញ្ជា ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និង អភិបាលកិច្ចល្អ (៦) ការអនុវត្តកំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការ ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលបច្ចេកទេស និង ហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាឃុំ- សង្កាត់ និង ការអភិវឌ្ឍន៍មូលដ្ឋាន និង (៧) ការអនុវត្តន៍កំណែទម្រង់រដ្ឋបាលសាធារណៈ ពិសេស ការពង្រឹង និង ពង្រីកការអនុវត្តន៍កន្សោមអាទិភាព និង កម្មវិធីផ្តល់លាភការទៅតាមសមត្ថភាព និង លទ្ធផលការងារដើម្បីបង្កើនប្រសិទ្ធភាព និង ផលិតភាពការងារ ។

II. លំនាំនិង ទិសដៅការងារក្នុងការអនុវត្តន៍ថវិកាឆ្នាំ ២០០៦

ក- ការអនុវត្តន៍ការប្រមូលចំណូលថវិកា

៣. ដើម្បីអោយការអនុវត្តន៍ច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ សំរេចបានជោគជ័យ ជាពិសេស ដើម្បីអោយការអនុវត្តន៍ថវិកាសំរេចបានតាមការគ្រោងទុក ជាក់ស្តែងគឺដើម្បីអោយការប្រមូលចំណូលក្នុងស្រុក សំរេចបានតាមគោលដៅ ២ ៩០៥ ៣២០ លានរៀល គឺស្មើនឹង ១២% នៃផសស រាជរដ្ឋាភិបាលនឹងជំរុញការបង្កើនការប្រមូលចំណូលចរន្តអោយបាន ២ ៨៣៣ ៣២០ លានរៀល បើធៀបទៅនឹងចំណូលចរន្តនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ គឺនឹងត្រូវកើនឡើង ២០,៣% ដែលក្នុងនោះចំណូលសារពើពន្ធនឹងត្រូវកើន ២២,៦% (ចំណូលគយ និង រដ្ឋាករនឹងត្រូវកើន ២១,៨% និង ចំណូលពន្ធដារនឹងត្រូវកើន ២៥%) និង ចំណូលមិនមែនសារពើពន្ធនឹងត្រូវកើន ១២,៦% ។

៤- ថវិកាឆ្នាំ ២០០៦ បានឆ្លុះបញ្ចាំងពីកំនើននៃចំណូលធៀបនឹងគំរោងចំណូលថវិកាឆ្នាំ ២០០៥ ជាពិសេស ការបង្កើនចំណូលក្នុងស្រុកអោយដល់ ២ ៩០៥ ៣២០ ពាន់លានរៀល គឺស្មើនឹង ១២% (ចំណូលក្នុងស្រុកដែលជាថវិការដ្ឋ ២ ៨១២ ៧២០ ពាន់លានរៀល គឺស្មើនឹង ១១,៦២% នៃផសស) នៃផសស ដែលនឹងមានកំនើនស្មើនឹង ២៥,៩% (ចំណូលថវិការដ្ឋកើន ២៥,៩%) ធៀបទៅនឹងលទ្ធផលប៉ាន់ស្មានចំណូលថវិកាឆ្នាំ ២០០៥ ។ ការបង្កើន និង ពង្រឹងការគៀរគរចំណូលគឺជាយុទ្ធសាស្ត្រស្នូលនៃគោលនយោបាយថវិកាឆ្នាំ ២០០៦

ជាពិសេស ការផ្តោតជាសំខាន់ទៅលើការពង្រឹងរដ្ឋបាលពន្ធដារ និង រដ្ឋបាលគយ និង រដ្ឋាករ ក្នុងគោលដៅសំរេចឱ្យបាននូវចំណូលសារពើពន្ធ ២ ២០៨ ពាន់លានរៀល គឺស្មើនឹង ៩,១២% (ចំណូលសារពើពន្ធដែលជាថវិការដ្ឋគឺស្មើនឹង ៨,៨២%) នៃផសស ក្នុងឆ្នាំ ២០០៦ ដែលមានកំនើនស្មើនឹង ២៥,៣% ធៀបទៅនឹងលទ្ធផលប៉ាន់ស្មានចំណូលថវិកាឆ្នាំ ២០០៥ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងពង្រឹងការអនុវត្តន៍ឱ្យមានប្រសិទ្ធភាពនូវច្បាប់ស្តីពីសារពើពន្ធ ពង្រឹង និង ពង្រីកសមត្ថភាពស្ថាប័ន ពង្រីកមូលដ្ឋានយកពន្ធ ព្រមទាំងទប់ស្កាត់អំពើគេចពន្ធគ្រប់បែបយ៉ាង ។ ម្យ៉ាងទៀត ចំណូលមិនមែនសារពើពន្ធនឹងសំរេចអោយបាន ៦២៥,៣២០ ពាន់លានរៀល (ចំណូលមិនមែនសារពើពន្ធដែលជាថវិការដ្ឋ ៦០៥,៧២០ ពាន់លានរៀល) គឺស្មើនឹង ២,៥៨% (ចំណូលមិនមែនសារពើពន្ធដែលជាថវិការដ្ឋគឺស្មើនឹង ២,៥០%) នៃផសស បើធៀបនឹងផែនការ ឆ្នាំ ២០០៥ គឺមានការកើនឡើង ១២,៦០% (ចំណូលមិនមែនសារពើពន្ធដែលជាថវិការដ្ឋកើនឡើង ១២%) ហើយនឹងកើនឡើង ១៨,២% (ចំណូលមិនមែនសារពើពន្ធដែលជាថវិការដ្ឋនឹងកើនឡើង ១៧,៧%) បើធៀបនឹងលទ្ធផលប៉ាន់ស្មានចំណូលថវិកាឆ្នាំ ២០០៥ ។

៥- ដើម្បីសំរេចបានតាមគោលដៅខាងលើ នាយកដ្ឋានពន្ធដារ និង ទីចាត់ការគយ និង រដ្ឋាករ ត្រូវរៀបចំកម្មវិធីប្រមូលចំណូលសារពើពន្ធប្រចាំត្រីមាសដែលមានការបែងចែកលំអិតទៅតាមខែ ។ បើគិតជាមធ្យមភាគប្រចាំខែ នាយកដ្ឋានពន្ធដារមានភារកិច្ចប្រមូលចំណូលពន្ធផ្ទៃក្នុងឱ្យបានជាមធ្យមចំនួន ៤៣,៧៥ ពាន់លានរៀលក្នុងមួយខែ ។ ចំណែកទីចាត់ការគយ និង រដ្ឋាករមានភារកិច្ចប្រមូលចំណូលពន្ធអាករឱ្យបានជាមធ្យមចំនួនប្រមាណ ១៣៤,១៦ ពាន់លានរៀលក្នុងមួយខែ ទោះជាការប្រមូលជាក់ស្តែងអាចមានកំរិតខ្ពស់ ឬទាបជាងការគ្រោងទុកបន្តិចបន្តួចទៅតាមស្ថានភាពសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈក៏ដោយ ។ ទន្ទឹមនឹងនេះ កម្មវិធីប្រមូលចំណូលនេះត្រូវមានផែនការសកម្មភាពអនុវត្តលំអិតហើយប្រគល់ឱ្យសាខាទីស្នាក់ការ និង មន្ត្រីម្នាក់ៗ ដើម្បីទទួលខុសត្រូវដោយផ្ទាល់ទៅតាមភារកិច្ចដែលខ្លួនត្រូវបំពេញរៀងៗខ្លួន ។

៦- ដើម្បីសំរេចបាននូវការប្រមូលចំណូលមិនមែនសារពើពន្ធឆ្នាំ ២០០៦ ចំនួន ៦២៥,៣២០ ពាន់លានរៀល ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរបស់ខ្លួននៅតាមខេត្ត-ក្រុងត្រូវរៀបចំកម្មវិធីប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំត្រីមាស ដែលមានការបែងចែកលំអិតតាមខែ ដោយផ្អែកលើកិច្ចសន្យានៃការជួលទ្រព្យសម្បត្តិរដ្ឋ កិច្ចសន្យាសម្បទាននានា ចំណូលពីសេវាបង់ថ្លៃសកម្មភាពអាជីវកម្ម និង សង្វាក់នៃការប្រមូលចំណូលកន្លងមក ។ ក្រសួង-ស្ថាប័នត្រូវប្រគល់ការអនុវត្តន៍កម្មវិធីនេះ ទៅឱ្យអង្គភាពក្រោមឱវាទនៅរដ្ឋបាលកណ្តាល និងនៅខេត្ត-ក្រុង អោយទទួលខុសត្រូវដោយផ្ទាល់ចំពោះការប្រមូលចំណូលទាំងនោះ ។ អង្គភាពប្រមូលចំណូល ត្រូវធ្វើការតាមដាន និង ជំរុញជាប្រចាំនូវការអនុវត្តន៍កម្មវិធីប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំត្រីមាស និង វិះរកវិធានការទាន់ពេលវេលាក្នុងករណីចាំបាច់ ។

៧- ទន្ទឹមនឹងនេះ ដើម្បីអោយការអនុវត្តន៍កម្មវិធីប្រមូលចំណូលប្រចាំត្រីមាសសំរេចបានប្រកបដោយប្រសិទ្ធភាពខ្ពស់ អង្គភាពនីមួយៗ ត្រូវធ្វើការតាមដាន និង ត្រួតពិនិត្យជាប្រចាំ (ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំខែ និង ប្រចាំត្រីមាស) លើលទ្ធផលដែលសំរេចបាន ដើម្បីរិះរកវិធានការទាន់ពេលវេលាក្នុងករណីចាំបាច់ ។ ក្រៅពីការធ្វើរបាយការណ៍អនុវត្តចំណូលប្រចាំសប្តាហ៍ និង ប្រចាំខែ អង្គភាពនីមួយៗត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាសស្តីពីការអនុវត្តន៍ចំណូលរបស់ខ្លួនសំរាប់ដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ និង មានវិធានការតាមរយៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយលើកឡើងពីលទ្ធផលដែលសំរេចបាន និង ចំណុចខ្វះខាតដែលបានកត់សំគាល់ព្រមទាំងលើកឡើងនូវសំណូមពរ និង អនុសាសន៍ដើម្បីកែលំអ និង បង្កើនប្រសិទ្ធភាពប្រមូលចំណូល ។

៨- លើសពីនេះទៅទៀត ដើម្បីធានាការប្រមូលចំណូលតាមគោលនយោបាយនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបាន ដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម៖

- *វិធានការពង្រឹងសមត្ថភាពប្រមូល និង គ្រប់គ្រងចំណូល* តាមរយៈការពង្រឹងសមត្ថភាពកសាងគោលនយោបាយ និង យន្តការគ្រប់គ្រង ការបង្កើតក្របខ័ណ្ឌ និង ជំរុញការកសាងវិធានការកៀរគរចំណូលតាមមូលដ្ឋាន ការជំរុញការកសាងការព្យាករណ៍ចំណូលរយៈពេលមធ្យម ការរៀបចំយន្តការ និង ផែនការប្រមូល និង តឹងទារាល់បំណុលសារពើពន្ធ និង មិនមែនសារពើពន្ធ និង ការពង្រឹង ការធ្វើសវនកម្ម និង អធិការកិច្ចលើការប្រមូលចំណូល ។ ជាក់ស្តែង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនឹងជំរុញការអនុវត្តន៍នូវបណ្តាសកម្មភាពមួយចំនួនដូចជា៖

  - កសាង និង រៀបចំដាក់អោយអនុវត្តនូវបង្កាន់ដៃជាតិមួយដែលឯកភាព សំរាប់ប្រើប្រាស់ក្នុងការចុះបញ្ជី និង តាមដានការគ្រប់គ្រងលើការប្រមូលចំណូលជាតិគ្រប់ប្រភេទ ។
  - រៀបចំ និង ណែនាំអោយអនុវត្តប្រកបដោយប្រសិទ្ធភាពនូវបទបញ្ជា និង វិន័យលើការប្រមូលចំណូលថវិការដ្ឋគ្រប់ប្រភេទ ជាពិសេស ចំណូលមិនមែនសារពើពន្ធ ។
  - កសាងបណ្តាជំនីសនានាដើម្បីពង្រឹងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការកសាងគោលនយោបាយ និង យន្តការគ្រប់គ្រងកម្មវិធីសមាហរណកម្មពេញលេញនៃការកៀរគរធនធានថវិកា ជាពិសេសការបង្កើនសមត្ថភាពវិភាគព្យាករណ៍ និង ស្វែងរកប្រភពចំណូលថ្មី ។
  - បង្កើតក្របខ័ណ្ឌសំរាប់កៀរគរ និង បែងចែកចំណូលទៅតាមគ្រប់លំដាប់ថ្នាក់រដ្ឋបាល និង ផ្តល់ការណែនាំដល់ការកសាងវិធានការសំដៅបង្កើនធនធាននៅតាមខេត្ត ក្រុង និង ឃុំសង្កាត់ ។
  - កសាងបណ្តាជំនីសសំរាប់រយៈពេលមធ្យម និង វែងពាក់ព័ន្ធនឹងកម្មវិធីសមាហរណកម្មនៃការកៀរគរធនធានថវិកាសំដៅបំពីនិត្យការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ។
  - កសាងបណ្តាជំនីសក្នុងការធ្វើសមាហរណកម្មការកៀរគរធនធានថវិកា ដើម្បីកំណត់បញ្ចូលទៅក្នុងដំណើរការកសាងថវិកាជាតិ និង ដំណើរការត្រួតពិនិត្យឡើងវិញនៃការអនុវត្តន៍ថវិកាជាតិ ។

- កំណត់ឱ្យបានច្បាស់លាស់នូវបំណុលសារពើពន្ធ និង បំណុលនៃចំណូលមិនមែនសារពើពន្ធ ដើម្បីរៀបចំផែនការប្រមូល និង តឹងទារឱ្យមានប្រសិទ្ធភាព ។
- ពង្រឹងការងារសវនកម្ម ទាំងសវនកម្មផ្ទៃក្នុងរបស់ក្រសួង-ស្ថាប័នសាមីនីមួយៗ ទាំងសវនកម្មផ្ទៃក្រៅ និង ការងារអធិការកិច្ច ទាំងអធិការកិច្ចរបស់រាជរដ្ឋាភិបាល ទាំងអធិការកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លើការគ្រប់គ្រងថវិកាជាតិជាពិសេសលើការប្រមូលចំណូល ។

• ***វិធានការពង្រឹងការប្រមូលចំណូលគយ និង រដ្ឋាករ*** តាមរយៈការជំរុញការអនុវត្តន៍ច្បាប់ និង បទបញ្ញាតិលើការទប់ស្កាត់ និង បង្ក្រាបការគេចពន្ធ ការជំរុញការកសាងគោលនយោបាយគយ និង រដ្ឋាករ និង សេចក្តីណែនាំការអនុវត្តន៍និតិវិធីគយ ការជំរុញការបណ្តុះបណ្តាលជំនាញដល់មន្ត្រីគយ ការបង្កើនសមត្ថភាពវិភាគចំណូល និង ការផ្តល់តួលេខចំណូលដោយសុក្រិត និង បច្ចុប្បន្នភាព ការជំរុញការអនុវត្តន៍គំរោងស្វ័យប្រវត្តិកម្មប្រតិបត្តិការគយ និង រដ្ឋាករ ការបន្តជំរុញការអនុវត្តការប្រមូលពន្ធគយតាមប្រព័ន្ធធនាគារ និង ការជំរុញការកែលំអរចនាសម្ព័ន្ធនៃការផ្តល់លាភកា និង ការលើកទឹកចិត្តដល់មន្ត្រីគយ ។ ជាពិសេស ការអនុវត្តន៍នូវបណ្តាសកម្មភាពជាក់ស្តែងមួយចំនួនដូចជា៖

- ការកសាង និង ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិខាងផ្នែកគយជាមួយប្រទេសដៃគូរពាណិជ្ជកម្មអន្តរជាតិ ជាពិសេសប្រទេសជាប់ព្រំដែន ដើម្បីទប់ស្កាត់អំពើល្មើសគេចពន្ធ តាមរយៈការផ្តល់ពត៌មាន និង ការបញ្ជាក់ទៅវិញទៅមកពាក់ព័ន្ធនឹងការនាំចេញ-នាំចូល មុខទំនិញមានវេទយិតភាពខ្ពស់លើចំណូល ។
- ចាត់វិធានការទប់ស្កាត់ការជ្រាបចូលទីផ្សារនៃទំនិញដែលនាំចូលតាមរបបអនុគ្រោះនានា ដោយដាក់អោយដំណើការនូវប្រព័ន្ធជំរះបញ្ជីច្បាស់លាស់ ។
- ពង្រឹងយន្តការត្រួតពិនិត្យទំនិញមុនពេលផ្ទុកបន្ថែមទៀត ដើម្បីកាត់បន្ថយជាអតិបរមានូវទំនិញនាំចូលដែលមិនឆ្លងការត្រួតពិនិត្យទំនិញមុនពេលផ្ទុកអោយបានត្រឹមត្រូវ ។
- ជំរុញការអនុវត្តន៍យន្តការឆ្លងកាត់ជាតិ ដើម្បីយកទំនិញសំខាន់ៗមួយចំនួនមកបំពេញបែបបទនៅជិតតំបន់ប្រើប្រាស់ ជាសវាងការចំណាយមិនចាំបាច់នានានៅតាមច្រក និង តាមដងផ្លូវងាយស្រួលដល់ផ្នែកផ្សេងទៀតជួយឃ្លាំមើល និង សង្កេតការណ៍ ។
- កែសំរួលនិតិវិធីត្រួតពិនិត្យរបស់គយអោយកាន់តែមានប្រសិទ្ធភាព លើទំនិញនាំចូលនាពេលបំពេញបែបបទបញ្ចេញទំនិញ ពេលដឹកជញ្ជូន ពេលសន្និធិ និង ពេលចរាចរចែកចាយ ។
- បន្តជំរុញ និង ពង្រីកការអនុវត្តន៍ការប្រមូលចំណូលតាមរយៈមូលប្បទានប័ត្រ និង ការផ្ទេរដោយត្រង់ទៅធនាគារជាតិ ។
- រៀបចំ និង អនុវត្តការធ្វើសវនកម្មក្រោយការយកទំនិញចេញពីគយ ដើម្បីធានាភាពត្រឹមត្រូវនៃប្រតិបត្តិការគយ ។

- រៀបចំកម្មវិធីបណ្តុះបណ្តាលធនធានមនុស្ស រួមទាំងការជ្រើសរើស និង ហ្វឹកហ្វឺនមន្ត្រី និង ភ្នាក់ងារគយ និង រដ្ឋាករ ។
- អនុវត្តយុទ្ធសាស្ត្រចាប់បង្ខំ និង គោលការណ៍គ្រប់គ្រងហានិភ័យដើម្បីកាត់បន្ថយការគេចពន្ធ និង បណ្តាសកម្មភាពខុសច្បាប់ផ្សេងៗនៅតាមព្រំដែន ។
- ពង្រឹងក្របខ័ណ្ឌគតិយុត្តិដោយផ្អែកលើច្បាប់គយថ្មី ដោយការអនុវត្តន៍យ៉ាងហ្មត់ចត់ ក្នុងនោះរួមមានទាំងការកសាងគោលនយោបាយគយ និង រដ្ឋាករ និង ការចងក្រងសេចក្តីណែនាំអនុវត្តនីតិវិធីគយ ។
- អនុវត្តកម្មវិធីគ្រប់ជ្រុងជ្រោយរបស់គយក្នុងការវិភាគលើចំណូល និង ការផ្តល់តួលេខចំណូល និង ស្ថិតិពាណិជ្ជកម្មប្រកបដោយបច្ចុប្បន្នភាព និង សុក្រឹតភាព ។
- ជំរុញការអនុវត្តន៍គំរោងបំពាក់បច្ចេកវិទ្យាពត៌មានដល់ទីចាត់ការគយ និង រដ្ឋាករ ហើយរៀបចំវិធានការរយៈពេលខ្លីសំរាប់ការអនុវត្តន៍កម្មវិធីស្វ័យប្រវត្តិកម្មគយ រួមទាំងការរៀបចំបង្កើតមូលដ្ឋានច្បាប់ និង នីតិវិធីដែលមានការពាក់ព័ន្ធនឹងការបណ្តុះបណ្តាល និង ការរៀបចំគំរោងផង ។
- កំណត់ និង អនុវត្តវិធានការពង្រឹងស្ថាប័នគយ រួមទាំងការកែលំអរចនាសម្ព័ន្ធនៃការផ្តល់កំរៃ និង ការលើកទឹកចិត្តដល់មន្ត្រីគយ និង ការអភិវឌ្ឍន៍កម្មវិធីអភិបាលកិច្ចល្អផង ។

• *វិធានការពង្រឹងការប្រមូលចំណូលពន្ធដារ* តាមរយៈការពង្រឹងការអនុវត្តន៍ច្បាប់ស្តីពីសារពើពន្ធ ការ បន្តពង្រីកមូលដ្ឋានពន្ធ រួមមានការបន្តពង្រីករបបពិតទៅតាមខេត្ត និង ពង្រឹងការអនុវត្តន៍អាករលើតំលៃបន្ថែម ការពង្រឹងសមត្ថភាពវិភាគព្យាករណ៍ និង ការរៀបចំគោលនយោបាយពន្ធដារ ការបង្កើនការប្រើប្រាស់ប្រព័ន្ធធនាគារក្នុងការបង់ពន្ធ ជាពិសេសចំពោះការបង់ពន្ធប្រភេទធំ ការពង្រឹងការគ្រប់គ្រងបំណុលពន្ធ និង អនុវត្ត ការតឹងទារបំណុលពន្ធដារ និង ការពង្រឹងការធ្វើសវនកម្មពន្ធ ជាពិសេសចំពោះអ្នកជាប់ពន្ធប្រភេទធំ ។ ជាពិសេស ការអនុវត្តន៍ នូវបណ្តាសកម្មភាពជាក់ស្តែងមួយចំនួនដូចជា៖

- រៀបចំ និង ដាក់អោយអនុវត្តការប្រមូលពន្ធលើអចលនវត្ថុ ។
- ពង្រឹងការប្រមូលចំណូលពន្ធតាមរយៈការអនុវត្តន៍ច្បាប់ស្តីពីសារពើពន្ធ និង ច្បាប់ដែលមានការពាក់ព័ន្ធ ដូចជាច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង បទបញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ។
- ពង្រឹងការគ្រប់គ្រងប្រមូលអាករពិសេស អាករលើតំលៃបន្ថែម និង យន្តការបង្វិលសងអាករលើតម្លៃបន្ថែម ។
- កែលំអការវិភាគ និង ការព្យាករណ៍លើចំណូលពន្ធដារ ក្នុងទិសដៅបង្កើតបណ្តាជំរើសគោលនយោបាយថ្មីៗ ដើម្បីបង្កើនចំណូលពន្ធ ។

- កំណត់នីតិវិធីឱ្យបានច្បាស់លាស់ សំរាប់ពង្រឹងការផ្តល់ព័ត៌មានទៅវិញទៅមក ជាពិសេសព័ត៌មានអំពីអ្នកបង់ពន្ធប្រភេទធំរវាងទីចាត់ការគយ និង រដ្ឋាករ និង នាយកដ្ឋានពន្ធដារ ។
- ការបង្កើនការប្រើប្រាស់ប្រព័ន្ធធនាគារក្នុងកិច្ចអនុវត្ត/ការអតិបរមាដើម្បីសំរួលដល់ការបង់ពន្ធ ជាពិសេសចំពោះអ្នកជាប់ពន្ធប្រភេទធំ និង មធ្យម ។
- ពង្រឹងឱ្យបានគ្រប់ជ្រុងជ្រោយនូវសេវាកម្មពន្ធ ពិសេសចំពោះអ្នកជាប់ពន្ធប្រភេទធំ និង មធ្យម។
- ពង្រឹងការគ្រប់គ្រងបំណុលពន្ធ និង អនុវត្តយ៉ាងហ្មឹងម៉ាត់នូវការតឹងទារបំណុលពន្ធដារ ក្នុងនោះរួមមានការអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសំរាប់កិច្ចប្រតិបត្តិការគ្រប់គ្រង និង ការធ្វើសវនកម្មពន្ធនៅនឹងកន្លែង ព្រមទាំងការជំរះបញ្ជីអ្នកជាប់ពន្ធផងដែរ ។
- បន្តអនុវត្តវិធានការពង្រឹងនាយកដ្ឋានពន្ធដារ រួមទាំងការរៀបចំរចនាសម្ព័ន្ធឡើងវិញ ការជ្រើសរើសមន្ត្រីថ្មីបន្ថែម ការកែលំអសេវាបំរើឱ្យអ្នកជាប់ពន្ធ ការអនុវត្តន៍កម្មវិធីបណ្តុះបណ្តាល ការធ្វើសវនកម្មផ្តោតក្នុងការបំពាក់នូវទុក្ខសំភារៈចាំបាច់ផ្សេងៗ ។ល។
- បង្កើនការផ្ទៀងផ្ទាត់ព័ត៌មានដើម្បីស្វែងរកផលរបរនៅក្នុងរបបម៉ៅការដែលត្រូវផ្ទេរទៅរបបពិត។

• *វិធានការពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធ* តាមរយៈការពង្រឹងក្របខ័ណ្ឌច្បាប់ និង វិធានការគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ ការពង្រឹងការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ការអនុវត្តន៍វិធានការដាក់វិន័យចំពោះក្រសួងដែលមិនបង់ចំណូលចូលថវិការដ្ឋតាមកាលកំណត់ និង ការអនុវត្តន៍យ៉ាងហ្មឹងម៉ាត់ និង ជាប្រចាំនូវការងារសវនកម្ម និង អធិការកិច្ចលើកាតព្វកិច្ចបង់ចំណូលមិនមែនសារពើពន្ធរបស់ក្រសួង- ស្ថាប័ន និង សហគ្រាសសាធារណៈគ្រប់ប្រភេទ ។ ជាពិសេស ការអនុវត្តន៍នូវបណ្តាសកម្មភាពជាក់ស្តែងមួយចំនួនដូចជា៖

- រៀបចំ និង ដាក់អោយអនុវត្តនូវអនុក្រឹត្យស្តីពីការគ្រប់គ្រង និង ការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ។
- ចុះសិក្សា និង ស្រាវជ្រាវរាល់បំណុលទាំងអស់ ដើម្បីរៀបចំគោលការណ៍ និង នីតិវិធីតឹងទារ ឬដោះស្រាយតាមផ្លូវច្បាប់ចំពោះបំណុលកុំរ៉ៃ
- ដាក់ចេញនូវវិធានការជាបន្ទាន់ដើម្បីពង្រឹងក្របខ័ណ្ឌច្បាប់ និង ស្ថាប័ន សំរាប់ការគ្រប់គ្រង និង ប្រមូលចំណូលមិនមែនសារពើពន្ធ ។
- ពង្រឹងការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ។
- ពង្រឹងការគ្រប់គ្រងឯកជនភាវូបនីយកម្មនៃទ្រព្យសម្បត្តិរដ្ឋឱ្យស្របទៅតាមច្បាប់ និង បទបញ្ញត្តិជាធរមាន ។
- ដាក់ចេញ និង អនុវត្តជាបន្ទាន់ឱ្យមានប្រសិទ្ធភាពនូវៈ (១)- វិធានការពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធពីការជួល ឬ លក់អចលនទ្រព្យ រួមទាំងការពង្រឹងនីតិវិធីនៃការជួល និង ការចុះកិច្ចសន្យាផង (២)- វិធានការពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធពីសហគ្រាសសាធារណៈ តាមរយៈការពង្រឹងក្របខ័ណ្ឌនៃការគ្រប់គ្រងសហគ្រាសទាំងអស់នោះ (៣)- វិធាន

ការពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធពីការលក់ទំនិញសាធារណៈ និង ការផ្តល់សេវាសាធារណៈ (៤)- វិធានការពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធពីការគ្រប់គ្រងធនធានធម្មជាតិគ្រប់ប្រភេទ ។

- ពង្រឹងប្រព័ន្ធត្រួតពិនិត្យ និង ប្រមូលចំណូលពីអាជីវកម្មឆ្នោត និង ល្បែងភ្នាល់ផ្សេងៗ ដោយសិក្សាពីបទពិសោធន៍អន្តរជាតិ ពាក់ព័ន្ធនឹងជំរើសដែលអាចបង្កើនចំណូលពីអាជីវកម្មឆ្នោត និង ល្បែងភ្នាល់ទាំងអស់នោះ ។
- ពង្រឹងក្របខ័ណ្ឌច្បាប់ក្នុងការត្រួតពិនិត្យសកម្មភាពប្រតិបត្តិការកាស៊ីណូ និង ពង្រឹងការប្រមូលចំណូលពីកាស៊ីណូឱ្យបានកើនឡើងសមស្របនឹងចំណូលជាក់ស្តែងនៃអាជីវកម្មក្នុងវិស័យនេះ ក្នុងនោះរួមមានការពង្រឹងសមត្ថភាពរបស់ស្ថាប័ន និង មន្ត្រីដែលទទួលបន្ទុកការងារប្រមូលចំណូលនេះផងដែរ ។
- ដាក់ចេញ និង អនុវត្តនូវប្រព័ន្ធដែលផ្តល់អំណាចដល់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការអនុម័តជាចុងក្រោយលើរាល់កិច្ចព្រមព្រៀង និង កិច្ចសន្យាសម្បទានគ្រប់ប្រភេទ ដើម្បីបង្កើនចំណូលពីសម្បទានរបស់រដ្ឋ និង ដើម្បីការពារផលប៉ះពាល់អាក្រក់ដល់ថវិកាជាតិ ។
- ដាក់ចេញ និង អនុវត្តជាបន្ទាន់ឱ្យបានប្រកបដោយប្រសិទ្ធភាពនូវវិធានការដាក់វិន័យ ចំពោះក្រសួង-ស្ថាប័នឬមន្ត្រីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ ដែលមិនព្រមបង់ចំណូលចូលរតនាគារជាតិ ឬ លួចលាក់ចំណូលទុកចាយនៅក្រៅបរិបថនៃថវិកាជាតិ ឬ ទុកចាយដោយខុសនីតិវិធីនៃច្បាប់ហិរញ្ញវត្ថុជាធរមាន ។
- អនុវត្តយ៉ាងហ្មឺងម៉ាត់ និង ជាប់ជាប្រចាំនូវសវនកម្ម និង អធិការកិច្ចលើការអនុវត្តន៍កាតព្វកិច្ចបង់ចំណូលពុំមែនសារពើពន្ធរបស់គ្រប់ក្រសួង-ស្ថាប័ន និង សហគ្រាសសាធារណៈ ដែលមានការពាក់ព័ន្ធ ។

ខ- ការអនុវត្តន៍ចំណាយថវិកា

៩- ដើម្បីធានាដល់ការអនុវត្តន៍ថវិកាឆ្នាំ ២០០៦ ប្រកបដោយប្រសិទ្ធភាព និង សំរេចបានតាមគោលដៅនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល ការគ្រប់គ្រងចំណាយក៏នឹងត្រូវបានបន្តពង្រឹងបន្ថែមទៀត ជាពិសេស ការគោរពអោយបានដាច់ខាតនូវវិន័យថវិកាទាំង ១១ខ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល ។ ទន្ទឹមនឹងនេះ ត្រូវបន្តពង្រឹងការអនុវត្តន៍អភិបាលកិច្ចល្អក្នុងការអនុវត្តន៍ចំណាយ និង ការវិភាជន៍ចំណាយ ការគ្រប់គ្រងការអនុវត្តន៍ថវិកា ការគ្រប់គ្រងការងារលទ្ធកម្មសាធារណៈ និង ការអនុវត្តឱ្យបានហ្មឺងម៉ាត់នូវរាល់ការងារកែទំរង់ហិរញ្ញវត្ថុសាធារណៈ ជាពិសេសការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។ ក្រសួង-ស្ថាប័នទាំងអស់ ទាំងនៅរដ្ឋបាលកណ្តាល ទាំងនៅខេត្ត-ក្រុងត្រូវប្រកាន់ខ្ជាប់ និង គោរពឱ្យបានហ្មឺងម៉ាត់បំផុតនូវវិន័យថវិកា និង នីតិវិធីចំណាយថវិកា ដើម្បីធានាឱ្យបាននូវតុល្យភាពថវិកា ជាពិសេសត្រូវអនុវត្តនូវវិធានការដូចខាងក្រោម៖

- ***ទីមួយៈ*** ត្រូវគោរពតាមឥណទានថវិកា ដែលត្រូវបានកំណត់ដោយច្បាប់ជាអាទិ៍ៈ

  \+ មិនត្រូវលើកសំណើចំណាយណាដែលគ្មានការគ្រោងទុកនៅក្នុងថវិកា ឬ គ្មានឥណទានថវិកានៅសល់ទំនេរ ។

  \+ មិនត្រូវអោយមានចំណាយលើសពីឥណទានថវិកាដែលមានលក្ខណៈកំរិតកំណត់ ។

  \+ មិនត្រូវអនុវត្តនូវសកម្មភាព ដែលនាំអោយមានការជ្រើសរើសបុគ្គលិកថ្មី ឬ បុគ្គលិកជាប់កិច្ចសន្យានៅក្នុងឆ្នាំដែលកំពុងអនុវត្ត ដោយគ្មានការគ្រោងទុកក្នុងថវិកា ឬ គ្មានសេចក្តីសំរេចពីរាជរដ្ឋាភិបាល។

  \+ មិនត្រូវលើកសំណើចំណាយបន្ថែមប្រសិនបើគ្មានការសន្សំសំចៃពីខ្ទង់ចំណាយដទៃទៀតមកធានា។

- ***ទីពីរៈ*** ត្រូវអនុវត្តន៍ទៅតាមកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសឱ្យបានហ្មត់ចត់ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវធ្វើកម្មវិធីចំណូល- ចំណាយជាក់ស្តែងប្រចាំត្រីមាស ដែលកម្មវិធីចំណូលចំណាយនេះនឹងត្រូវធ្វើការត្រួតពិនិត្យឡើងវិញប្រចាំត្រីមាស ដោយឈរលើមូលដ្ឋាននៃថវិកា ដែលត្រូវបានកំណត់ដោយច្បាប់ ហើយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអាចតម្រឹមចំណាយថវិកាទៅតាមសមិទ្ធិផលជាក់ស្តែងនៃការប្រមូលចំណូល ដើម្បីធានានូវតុល្យភាពថវិកា ធានាប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់ និង ធានាភាពជឿទុកចិត្តលើថវិកា ។

- ***ទីបីៈ*** ត្រូវគោរពនីតិវិធីក្នុងការគ្រប់គ្រងចំណាយថវិកាៈ

  \+ មិនត្រូវអនុញ្ញាតឱ្យមានការធានាចំណាយ និង ការផ្តល់ទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេ ប្រសិន បើគ្មានការស្នើសុំជាលាយលក្ខណ៍អក្សរពីអាណាប័កដើមខ្សែ ឬ អាណាប័កផ្ទេរសិទ្ធិ ទោះបីចំណាយនោះមានកត់ត្រាទុកនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុក៏ដោយ ។

  \+ មិនត្រូវអនុញ្ញាតឱ្យមានការលើកលែងគោលការណ៍នៃបរិបថចំណាយ ការសន្យាចំណាយ ការជំរះបញ្ជី ការធ្វើអាណត្តិបើកប្រាក់ និង ការទូទាត់ លើកលែងតែមានករណីដែលរាជរដ្ឋាភិបាលសំរេចដោយឡែក ។

  \+ មិនត្រូវធ្វើការធានាចំណាយ ប្រសិនបើគ្មានឥណទានថវិកានៅសល់ទំនេរ គឺត្រូវធ្វើការសន្យាចំណាយទៅតាមឥណទានថវិកាដែលមាន ។

  \+ ត្រូវផ្តល់ធានាចំណាយ និង ចេញអាណត្តិបើកប្រាក់ ទៅតាមកម្មវិធីចំណូល- ចំណាយដែលបានកំណត់ លើកលែងតែក្នុងករណីចាំបាច់ដែលមានការស្នើសុំពីក្រសួងចំណាយ និង មានការឯកភាពពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

  \+ មិនត្រូវអនុវត្តចំណាយណាដែលគ្មានលិខិតយុត្តិកម្មគ្រប់គ្រាន់សំរាប់បង្ហាញមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដើម្បីធ្វើជាមូលដ្ឋានគតិយុត្តិនៃសំណើចំណាយថវិកា ។

៩

+ មិនអាចធ្វើអាណត្តិបើកប្រាក់ និង មិនអាចបញ្ជូនអាណត្តិបើកប្រាក់នោះទៅរតនាគារជាតិបានឡើយ ប្រសិនបើលិខិតយុត្តិការផ្លូវការមានលក្ខណៈមិនគ្រប់គ្រាន់ ។

+ អាចផ្តល់ថវិកាបុរេប្រទានបាន តែក្នុងករណីចាំបាច់ជាបន្ទាន់ ហើយមានឥណទានសល់ទំនេរសំរាប់ចេញអាណត្តិទូទាត់បាន ក្រោយពីប្រតិបត្តិការចំណាយរួច ។

+ អាចផ្តល់មូលនិធិជួសជុល-ថែទាំផ្លូវថ្នល់បាន លុះត្រាតែមានឥណទានសល់ទំនេរនៅក្នុងគណនីមូលនិធិ ។

១០- ដើម្បីឱ្យការអនុវត្តន៍ចំណាយថវិការដ្ឋប្រព្រឹត្តទៅបានទាន់ពេលវេលា និង ជៀសវាងការចំណាយតិចនៅដើមឆ្នាំ ហើយទៅប្រមូលផ្តុំចំណាយច្រើននៅចុងឆ្នាំ និង ម្យ៉ាងវិញទៀត ដើម្បីរក្សាតុល្យភាពថវិកាឱ្យបានរឹងមាំផងនោះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញនៅតាមខេត្ត-ក្រុង ឱ្យដំណើរការអនុវត្តនីតិវិធីចំណាយ ដូចជាការស្នើសុំធានាចំណាយ និង អនុវត្តវិធីសាស្ត្រលទ្ធកម្មសាធារណៈដូចតទៅ÷

- រដ្ឋមន្ត្រីដែលជាអាណាប័កដើមខ្សែ ត្រូវប្រញាប់ប្រញាល់ធ្វើប្រកាសស្តីពីការតែងតាំងអាណាប័កផ្ទេរសិទ្ធិ និង ការផ្ទេរឥណទានថវិកាជូនអភិបាលខេត្ត-ក្រុង ដើម្បីឱ្យមន្ទីរជំនាញរបស់ខ្លួននៅតាមខេត្ត- ក្រុង អាចមានលទ្ធភាពអនុវត្តនូវនីតិវិធីចំណាយបានទាន់ពេលវេលា ។
- ចំណាយថវិការដ្ឋក្នុងការទិញសំភារៈ ជួលសេវា ជួសជុល និង សាងសង់ ត្រូវតែអនុវត្តឱ្យបានហ្មឹងម៉ាត់តាមគោលការណ៍ និង និតិវិធីលទ្ធកម្មសាធារណៈ ។ ចំពោះការអនុវត្តនីតិវិធីដេញថ្លៃសាធារណៈ ជាដំបូងក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវពិនិត្យមើលឥណទានថវិកាឆ្នាំ ២០០៦ របស់ខ្លួនមានប៉ុន្មាននៅជំពូកណាខ្លះ រួចលើកសំណើសុំគោលការណ៍ធានាចំណាយមួយឆមាសម្តង ក្នុងការផ្គត់ផ្គង់ទំនិញសេវាការជួសជុល ការសាងសង់ មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត-ក្រុងឱ្យបាននៅដើមឆ្នាំ និង ដើមឆមាស ទី២ ដើម្បីមានពេលវេលាគ្រប់គ្រាន់សំរាប់ធ្វើការងារដេញថ្លៃជាសាធារណៈ ។ កន្លងមក សាម៉ីក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង មានការយឺតយ៉ាវក្នុងការស្នើសុំធានាចំណាយ ដែលជាហេតុបណ្តាលឱ្យការងារលទ្ធកម្មត្រូវអូសបន្លាយ ហើយការងារទូទាត់ត្រូវពន្យារដល់ចុងឆ្នាំនាំឱ្យចំណាយកើនឡើងគំហុកនៅចុងឆ្នាំ ។ សូមបញ្ជាក់ថា ការស្នើសុំធានាចំណាយសំរាប់អនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ មិនទាក់ទងដល់កម្មវិធីចំណាយទេ គឺទាក់ទងតែដល់ឥណទានថវិកាដែលមានកំណត់នៅក្នុងសៀវភៅថវិកាតែប៉ុណ្ណោះ ។
- ការចេញអាណត្តិទូទាត់ ត្រូវធ្វើឡើងក្រោយពីការប្រគល់ទទួល ដែលបានកំណត់នៅក្នុងកិច្ចសន្យា ។ ក្នុងករណីតម្លៃកិច្ចសន្យាមានចំនួនទឹកប្រាក់ច្រើនដល់រាប់ពាន់លានរៀលនោះ ការចេញអាណត្តិទូទាត់ត្រូវធ្វើឡើងជាច្រើនជំហានទៅតាមលទ្ធភាពនៃសាច់ប្រាក់ ។

- តំលៃសរុបនៃកិច្ចសន្យាលទ្ធកម្ម មិនអនុញ្ញាតឱ្យលើសពីឥណទានថវិកាដែលបានផ្តល់ការធានាចំណាយ ឬ ចំនួនទឹកប្រាក់ដែលបានយល់ព្រមផ្តល់មុនបណ្តោះអាសន្នតាមអាណត្តិបើកប្រាក់ឡើយ ។
- មិនអនុញ្ញាតិឱ្យធ្វើការប្រគល់ទទួល (ទំនិញ-សំណង់) ដោយគ្មានកិច្ចសន្យាលទ្ធកម្មឡើយ លើកលែងតែមានការសំរេចដោយឡែកដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ព្រោះកិច្ចសន្យាជាមូលដ្ឋានសំខាន់ និងចាំបាច់បំផុតសំរាប់ធ្វើការទូទាត់ ព្រមទាំងធ្វើការផ្ទៀងផ្ទាត់លក្ខណៈបច្ចេកទេស គុណភាព តំលៃ រយៈពេលផ្គត់ផ្គង់ ឬ សាងសង់ ដែលភាគីទាំងពីរបានព្រមព្រៀងគ្នា ។
- ក្នុងករណីចាំបាច់ដែលតំរូវឱ្យមានការផ្លាស់ប្តូរបញ្ជីប៉ាន់តំលៃ ឬ លក្ខណៈបច្ចេកទេស (ទំនិញ ឬ សំណង់) ខុសពីឧបសម្ព័ន្ធនៃកិច្ចសន្យា ត្រូវតែមានការឯកភាពជាលាយលក្ខណ៍អក្សររបស់ភាគីទាំងពីរ និង មានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។
- ក្នុងករណីការងារដែលទទួលអនុវត្តដោយអង្គភាពរដ្ឋ ត្រូវរក្សាចំនួនទឹកប្រាក់ ១០% នៃតំលៃសរុបរបស់កិច្ចសន្យាទុកជាការធានាគុណភាពជំនួសប្រាក់កក់រហូតដល់ផុតរយៈពេលធានាគុណភាព ទើបធ្វើការទូទាត់ជូនបង្គ្រប់បញ្ចប់ បន្ទាប់ពីមានកំណត់ហេតុប្រគល់ទទួលបញ្ជាក់ថាបានអនុវត្តត្រឹមត្រូវតាមកិច្ចសន្យា ។
- មុនការអនុវត្តនីតិវិធីសាស្រ្តលទ្ធកម្ម សាមីក្រសួង-ស្ថាប័ន ត្រូវផ្ញើលិខិតអញ្ជើញ និង បញ្ជីប៉ាន់តំលៃមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ យ៉ាងយឺតបំផុតឱ្យបានមុនមួយសប្តាហ៍ ។

១១- ទន្ទឹមនឹងការអនុវត្តន៍ចំណាយទៅតាមកម្មវិធីចំណូល-ចំណាយ ដំណើរការទូទាត់អាណត្តិបើកប្រាក់ ត្រូវផ្តល់អាទិភាពទៅលើចំណាយចាំបាច់ជាប្រចាំ មានដូចជាប្រាក់បៀវត្ស ប្រាក់អាហារូបករណ៍ ប្រាក់ឧបត្ថម្ភតាមគោលនយោបាយសង្គមកិច្ច ប្រាក់របបអ្នកជំងឺ ការប្រាក់ សងបំណុល ទឹក ភ្លើង ទូរស័ព្ទ វិភាគទានឱ្យអង្គការអន្តរជាតិនានា និង ចំណាយបដិភាគរួមចំណែកជាមួយការវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ និងបន្ទាប់មកត្រូវផ្អែកលើការទូទាត់ដែលមានចែងក្នុងកិច្ចសន្យាលទ្ធកម្មសាធារណៈ ។ ទន្ទឹមនឹងនេះ ត្រូវអនុវត្តវិធានការមួយចំនួន ក្នុងគោលបំណងត្បិតត្បៀត សន្សំសំចៃលើចំណាយសំរាប់កិច្ចដំណើរការរបស់ក្រសួង-ស្ថាប័នជាពិសេសចំណាយលើការប្រើប្រាស់សំភារៈការិយាល័យ ប្រេងឥន្ទនៈ ទឹក ភ្លើង ទូរស័ព្ទ និង ចំណាយផ្សេងៗទៀតដែលមិនសូវចាំបាច់ ។ ម៉្យាងវិញទៀត ត្រូវពង្រឹងយន្តការដើម្បីធានាលើកកំពស់ប្រសិទ្ធភាពអនុវត្តចំណាយសំរាប់កម្មវិធីសកម្មភាពជាអាទិភាព ជាពិសេស សំរាប់វិស័យសុខាភិបាល អប់រំ កសិកម្ម ធនធានទឹក និង អភិវឌ្ឍន៍ជនបទ ។ ចំណែកឯចំណាយផ្សេងៗទៀត ដែលមានលក្ខណៈបន្ទាប់បន្សំត្រូវបើកផ្តល់ទៅតាមលទ្ធភាពសាច់ប្រាក់របស់រតនាគារជាតិ ។

១២- ចំពោះចំនួនក្របខ័ណ្ឌ និង ប្រាក់បៀវត្សរបស់មន្ត្រីរាជការស៊ីវិល មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត-ក្រុង ត្រូវតែពិនិត្យអនុវត្តតាមព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល អនុក្រឹត្យលេខ ៣៤

អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការកែសម្រួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និង ប្រាក់ក្នុងវិស័យអប់រំ អនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការកែប្រែតំលៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល អនុក្រឹត្យលេខ ៩៦ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការកែប្រែប្រាក់ បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និង តារាងទូទាត់ប្រាក់បៀវត្សតាមប្រព័ន្ធពត៌មានវិទ្យាដែលចេញដោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

III. ការរៀបចំគម្រោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស

១៣- ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង មានភារកិច្ចរៀបចំគំរោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសសំរាប់រយៈពេលពេញ ១ ឆ្នាំ ដែលមានបែងចែកលំអិតទៅតាមខែ ដោយឈរលើមូលដ្ឋាននៃឥណទានដែលត្រូវបានកំណត់ដោយច្បាប់ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ដើម្បីពិនិត្យ និង វាយតំលៃ ដោយផ្អែកទៅលើតំរូវការ និង លទ្ធផលចំណូល-ចំណាយជាក់ស្តែង ដើម្បីដាក់ចេញជាកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសសំរាប់ការអនុវត្តន៍ ។ ដោយឡែក មន្ទីរជំនាញខេត្ត-ក្រុង ត្រូវផ្ញើរមកក្រសួង-ស្ថាប័ន តាមខ្សែបណ្តោយរបស់ខ្លួននូវគំរោងកម្មវិធីចំណូល- ចំណាយប្រចាំត្រីមាសនេះមួយច្បាប់ ដើម្បីការគ្រប់គ្រង និង តាមដានការអនុវត្តន៍ ។

១៤- ដើម្បីឱ្យនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រៀបចំឱ្យបានល្អ និង ត្រឹមត្រូវនូវការបែងចែកឥណទានថវិកាតាមកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស និង អនុវត្តឱ្យបានសំរេចនូវការអនុវត្តន៍ចំណូល- ចំណាយថវិកាតាមទិសដៅរបស់រាជរដ្ឋាភិបាល ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញ ខេត្ត-ក្រុង ត្រូវអនុវត្តឱ្យបានហ្មឹងម៉ាត់នូវនីតិវិធីដូចខាងក្រោម៖

- ក្នុងរយៈពេលចាប់ពីថ្ងៃទី ១៥ ដល់ថ្ងៃទី ២០ នៃខែចុងត្រីមាសនីមួយៗ នាយកដ្ឋានពន្ធដារ ទីចាត់ការគយ និង រដ្ឋាករ រតនាគារ នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ក្រសួង-ស្ថាប័ន និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវផ្ញើមកនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នូវរបាយការណ៍អំពីលទ្ធផលនៃការអនុវត្តន៍កម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសកន្លងទៅ និង គំរោងកម្មវិធីចំណូល- ចំណាយប្រចាំត្រីមាសបន្ទាប់ ។
- នាយកដ្ឋានពន្ធដារ ទីចាត់ការគយ និង រដ្ឋាករ រតនាគារ នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ក្រសួង-ស្ថាប័ន និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត-ក្រុង ត្រូវផ្ញើរបាយការណ៍អំពីការអនុវត្តន៍ចំណូល- ចំណាយប្រចាំខែ មកនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និង ហិញ្ញវត្ថុអោយបានមុនថ្ងៃទី ១០ នៃខែបន្ទាប់ ។

K

• ក្នុងរយៈពេលចាប់ពីថ្ងៃទី ២០ ដល់ថ្ងៃទី ២៥ នៃខែចុងត្រីមាសនីមួយៗ នាយកដ្ឋានថវិកាត្រូវកោះប្រជុំពិភាក្សាជាមួយនាយកដ្ឋានពន្ធដារ ទីចាត់ការគយ និង រដ្ឋាករ រតនាគារជាតិ និង នាយកដ្ឋានពាក់ព័ន្ធ ក្រោមនិវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីរៀបចំកម្មវិធីចំណូល-ចំណាយថវិការដ្ឋសំរាប់ត្រីមាសបន្ទាប់ ។ ផ្អែកលើមូលដ្ឋាននៃកម្មវិធីចំណូល-ចំណាយនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុធ្វើប្រកាសប្រគល់កម្មវិធីចំណូល-ចំណាយសំរាប់ត្រីមាសបន្ទាប់ តាមជំពូកថវិកាក្នុងកំរិតឥណទានអតិបរមាជូនដល់ក្រសួង-ស្ថាប័ននីមួយៗ និងមន្ទីរជំនាញខេត្ត-ក្រុងនីមួយៗ ដោយចម្លងជូននាយកដ្ឋានហិរញ្ញកិច្ច រតនាគារជាតិ និង អភិបាលខេត្ត-ក្រុង ។

• អាណាប័កដើមខ្សែ ឬ អាណាប័កតាមការប្រទានសិទ្ធ ត្រូវចេញអាណត្តិបើកប្រាក់នៅក្នុងរង្វង់នៃកម្មវិធីចំណាយប្រចាំត្រីមាសរបស់ខ្លួន ហើយនាយកដ្ឋានហិរញ្ញកិច្ច និង រតនាគារជាតិ ត្រូវចុះទិដ្ឋាការលើអាណត្តិបើកប្រាក់ និង ត្រូវបើកជាសាច់ប្រាក់ តែនៅក្នុងកំរិតនៃកម្មវិធីប្រចាំត្រីមាសនេះតែប៉ុណ្ណោះ ។ ក្នុងករណីមានការចាំបាច់សុំបើកផ្តល់បន្ថែម សាមុីអង្គភាពត្រូវធ្វើសំណើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ហើយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនឹងធ្វើប្រកាសផ្តល់កម្មវិធីបន្ថែម នៅក្នុងក្របខ័ណ្ឌឥណទានថវិកាដែលមិនទាន់បែងចែកនៅក្នុងកម្មវិធីចំណាយ ។

• រតនាគារត្រូវបញ្ជូនមកនាយកដ្ឋានថវិកា នូវរបាយការណ៍បេឡាប្រចាំថ្ងៃ របាយការណ៍ចំណូល-ចំណាយថវិកាប្រចាំខែ ព្រមទាំងសាលាកប័ត្របង់ប្រាក់ និង តារាងតុល្យភាពប្រចាំខែ ដើម្បីតាមដានបូកសរុបចំណូល ចំណាយថវិកាប្រចាំខែ ប្រចាំត្រីមាស ព្រមទាំងធ្វើការសន្និដ្ឋាន វាយតំលៃនូវសភាពការណ៍អនុវត្ត ធៀបនឹងខែមុន ត្រីមាសមុន នៃឆ្នាំនេះ និង ប្រៀបធៀបទៅនឹងខែ ត្រីមាសដូចគ្នានៃឆ្នាំមុន ។

IV. វិធីចលនាឥណទានថវិកា

១៥- ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវប្រើប្រាស់ឥណទានថវិការបស់ខ្លួន ទៅតាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដូចមានលំអិតនៅក្នុងសៀវភៅថវិកា ។ ចាប់ពីដើមត្រីមាសទី ២ ទៅក្នុងករណីដែលមានខ្ទង់ចំណាយថវិកាណាមួយមានឥណទានមិនគ្រប់គ្រាន់តែចាំបាច់ត្រូវចំណាយ ត្រូវធ្វើសំណើសុំនិយ័តភាពមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពិនិត្យសំរេចជាមុនសិន ទើបលើកសំណើសុំខ្ទង់ចំណាយនោះបាន ។ បើក្រសួងស្ថាប័នមានសំណូមពរផ្តល់ឥណទានបន្ថែម ដូចជាចំណាយដំណើរការរដ្ឋបាល សំភារៈការជួសជុលតូច ការសាងសង់ និង ទុក្ខសំភារៈ ។ល។ ទៅឱ្យមន្ទីរជំនាញរបស់ខ្លួននៅខេត្ត-ក្រុង នោះគឺត្រូវធ្វើឡើងដោយប្រកាសផ្ទេរឥណទានរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីឱ្យអភិបាលខេត្ត-ក្រុង (អាណាប័កតាមការប្រទានសិទ្ធិ) ដែលជាខ្សែទទឹង និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចតាមដានការប្រើប្រាស់ឥណទានថវិកាបន្ថែមទាំងនោះបាន ។

V. វិធានការរក្សាគុណភាព និង ប្រសិទ្ធភាពថវិកា

១៦- នៅពេលដែលពិនិត្យឃើញថា ស្ថានភាពនៃការអនុវត្តន៍ថវិកានឹងមិនអាចសំរេចបានទៅតាមការគ្រោងទុក ដើម្បីរក្សាគុណភាព និង ប្រសិទ្ធភាពថវិកា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានវិធានការដូចខាងក្រោមៈ

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនឹងធ្វើការត្រួតពិនិត្យលើការអនុវត្តន៍ថវិកាពាក់កណ្ដាលឆ្នាំ ដើម្បីជាមូលដ្ឋានក្នុងការធ្វើថវិកាកែតំរូវក្នុងករណីចាំបាច់ ។
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបញ្ឈប់ និង មិនអនុញ្ញាតិអោយមានការបោះផ្សាយអាណត្តិគំកល់ទុកសំរាប់ចំណាយនៅឆ្នាំបន្ទាប់ទៀតទេ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសេចក្ដីសង្ឃឹមយ៉ាងមុតមាំថា ក្រសួង-ស្ថាប័ន និង ខេត្ត-ក្រុង ទាំងអស់នឹងរួមសហការក្នុងការអនុវត្តថវិកាឆ្នាំ ២០០៦ របស់យើង អោយសំរេចបានជោគជ័យតាមការគ្រោងទុក ដើម្បីបំពីអោយការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណរបស់សម្ដេចនាយករដ្ឋមន្ត្រី និង ឆ្លើយតបទៅនឹងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី ៣ ជាពិសេសយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។/.

ចំលងជូន

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  (ដើម្បីជូនជ្រាបជាពិតមាន)
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់ខេត្ត- ក្រុង
  (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ព្រះរាជាណាចក្រ កម្ពុជា

Kingdom Of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

Land Appraisal and Valuation Committee

លេខ ០០៧ សសរ.សហវ.ពដ.

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ ២០០៥

សេចក្តីសំរេច

ស្តីពី

ការកំណត់តម្លៃគិតពន្ធលើដីមិនបានប្រើប្រាស់

ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស,រកត.០៧០៤.១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២-នស-៩៤ ចុះថ្ងៃទី ២០ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១-នស-៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៤
- បានឃើញច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស-រកម-០២៩៧-០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ១៩៩៧
- បានឃើញអនុក្រឹត្យលេខ ៥៨-អនក្រ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ២២៤ ប្រក-សហវ-ពដ ចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ១៩៩៦ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ៧៤៤-ប្រក-សហវ-ពដ ចុះថ្ងៃទី២១ ខែវិច្ឆិកាឆ្នាំ ១៩៩៦ ស្តីពីការកំណត់មេគុណសម្រាប់អនុវត្តក្នុងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញសេចក្តីសំរេចលេខ ០០៤-សសរ-សហវ-ពដ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៩៨ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់

ផ្លូវទី, ដូនពេញ, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣-៤២៦ ៧៤៩
Street 92, Rukhak Vithei Daun Penh, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia Tel/Fax: 855-23 426 749

- បានឃើញប្រកាសលេខ ៣៩៣ ប្រក-សហវ-ពដ ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ១៩៩៩ ស្តីពីការកែប្រែសមាសភាពគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
- បានឃើញសេចក្តីសំរេចលេខ ០០១ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ ២០០៥ ស្តីពីការបង្កើតអនុគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
- យោងតាមសំណើបែងចែកតំបន់ក្នុងខេត្ត-ក្រុង និងតម្លៃដីក្នុងមួយម៉ែត្រក្រឡាតាមតំបន់នីមួយៗរបស់អនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់តាមបណ្តាខេត្ត-ក្រុង
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ ។

សំរេច

ប្រការ១ : ដីធ្លីមិនបានប្រើប្រាស់ស្ថិតក្នុងខេត្ត-ក្រុងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ។

ប្រការ២ : តម្លៃដីសម្រាប់ធ្វើជាមូលដ្ឋានគិតពន្ធលើដីធ្លីមិនបានប្រើប្រាស់ ត្រូវបានកំណត់ដោយគិតជាតម្លៃក្នុងមួយម៉ែត្រក្រឡាទៅតាមតំបន់នីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធ សម្រាប់ខេត្ត-ក្រុងនីមួយៗ ភ្ជាប់ជាមួយ ។

ប្រការ៣ : សេចក្តីសំរេចលេខ០០២ សសរ-សហវ-ពដ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៩ និង សេចក្តីសំរេចលេខ០០៦ សសរ-សហវ-ពដ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ ២០០១ ស្តីពីការកំណត់តម្លៃគិតពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវទុកជានិរាករណ៍ ។

ប្រការ៤ : សេចក្តីសំរេចនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

គង់ វិបុល

រដ្ឋលេខាធិការទី១ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាបជាពត៌មាន"
-គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
-អនុគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់នៅខេត្ត-ក្រុង
-គ្រប់អង្គភាពពន្ធដារ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រ កម្ពុជា
Kingdom Of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
Land Appraisal and Valuation Committee

ឧបសម្ព័ន្ធទី ១

ការកំណត់បែងចែកតំបន់ និង តម្លៃដីក្នុងមួយម៉ែត្រក្រឡា សម្រាប់គិតពន្ធលើដីធ្លីមិនបានប្រើប្រាស់ នៅភ្នំពេញ

ភ្ជាប់ជាមួយសេចក្តីសំរេចលេខ ០១៧ សសរ.សហវ.ពដ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

តំបន់ I : -ដីស្ថិតក្នុងខណ្ឌដូនពេញ
-ដីស្ថិតក្នុងខណ្ឌ៧មករា
-ដីស្ថិតក្នុងខណ្ឌចំការមន
-ដីស្ថិតក្នុងខណ្ឌទួលគោក
-ដីស្ថិតក្នុងតំបន់អភិវឌ្ឍន៍

ប្រភេទ១ :ដីដែលស្ថិតនៅជាប់ផ្លូវកៅស៊ូក្នុងខណ្ឌទាំងបួនតម្លៃគិតពន្ធ១៥០.០០០រ០០ ក្នុងមួយម៉ែត្រក្រឡា ។

ប្រភេទ២ :តម្លៃគិតពន្ធ ៦០.០០០រ០០ ក្នុងមួយម៉ែត្រក្រឡា ដីទាំងឡាយណាដែលស្ថិតនៅក្រៅពីប្រភេទ១ និងដីទាំងឡាយដែលសិតក្នុងតំបន់អភិវឌ្ឍន៍របស់ក្រុង ។

តំបន់ II : - ដីស្ថិតនៅក្នុងខណ្ឌឫស្សីកែវ ខណ្ឌមានជ័យ និង ខណ្ឌដង្កោ

ប្រភេទ១ :តម្លៃគិតពន្ធ៤០.០០០រ០០ ក្នុងមួយម៉ែត្រក្រឡា

- តាមបណ្តោយផ្លូវជាតិលេខ៣ ចាប់ពីថ្នល់បំបែកចោមចៅ ដល់ព្រំប្រទល់ខេត្តកណ្តាល ចម្ងាយពីផ្លូវជាតិ២០០ម ។
- ផ្លូវជាតិលេខ៣ ចាប់ពីផ្លូវបំបែកចោមចៅ ដល់ព្រំប្រទល់ខេត្តកណ្តាល ចម្ងាយពីផ្លូវជាតិត្រឹម២០០ម ។
- ផ្លូវជាតិលេខ២ ចាប់ពីក្បាលថ្នល់ដល់ព្រះនរាយណ៍ ចម្ងាយពីផ្លូវជាតិ២០០ម ។
- ផ្លូវជាតិលេខ១ ចាប់ពីស្ពានព្រះមុនីវង្សដល់ព្រំប្រទល់ខេត្តកណ្តាល ចម្ងាយពីផ្លូវជាតិ២០០ម ។
- ផ្លូវជាតិលេខ៦អា ចាប់ពីស្ពានជ្រោយចង្វា ដល់ព្រំប្រទល់ខេត្តកណ្តាល ចម្ងាយពីផ្លូវជាតិត្រឹម២០០ម ។
- ផ្លូវជាតិលេខ៥ ចាប់ពីព្រំប្រទល់ខណ្ឌដូនពេញដល់ព្រំប្រទល់ខេត្តកណ្តាល ចម្ងាយពីផ្លូវជាតិត្រឹម២០០ម ។
- តាមបណ្តោយផ្លូវវែង ស្រេង ចំងាយពីផ្លូវជាតិត្រឹម២០០ម។

ប្រភេទ២ :តម្លៃគិតពន្ធ ១៥.០០០រ០០ ក្នុងមួយម៉ែត្រក្រឡា

- ដីទាំងឡាយណាដែលស្ថិតក្នុងប្រភេទ១ មានចំងាយពីផ្លូវជាតិ និងផ្លូវវែងស្រេង ចាប់ពី២០១ម ដល់៥០០ម ។

ប្រភេទ៣ :តម្លៃគិតពន្ធ ៥.០០០រ០០ ក្នុងមួយម៉ែត្រក្រឡា

- ដីទាំងឡាយណាដែលស្ថិតនៅក្នុងប្រភេទទី១ មានចំងាយពីផ្លូវជាតិ និងផ្លូវវៀងស្រេង ចាប់ពី៥០១ម ដល់១.០០០ម
- ដីទាំងឡាយដែលស្ថិតនៅជាប់ផ្លូវលំ ក្នុងចំងាយ២០០ ម ។

ប្រភេទ៤ ៈតម្លៃគិតពន្ធ ២.០០០៛០០ ក្នុងមួយម៉ែត្រក្រឡា

- ដីទាំងឡាយដែលស្ថិតនៅក្រៅពីប្រភេទ ទី១ ទី២ និង ទី៣ ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ ធ្នូ ឆ្នាំ ២០០៥

ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

គង់ វិបុល

រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រ កម្ពុជា

Kingdom Of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

Land Appraisal and Valuation Committee

ឧបសម្ព័ន្ធទី ២

ការកំណត់បែងចែកតំបន់ និង តម្លៃដីក្នុងមួយម៉ែត្រក្រឡា សម្រាប់គិតពន្ធលើដីធ្លីមិនបានប្រើប្រាស់ នៅក្រុងព្រះសីហនុ

ភ្ជាប់ជាមួយសេចក្តីសំរេចលេខ ០០៣ សសរ.សហវ.ពដ ចុះថ្ងៃទី២៨ ខែ [illegible] ឆ្នាំ ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

តំបន់ I តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡាសំរាប់ ថ្នាក់លេខ ១ = ៦០.០០០៛០០

ថ្នាក់លេខ ២ = ៤០.០០០៛០០

ថ្នាក់លេខ ៣ = ២០.០០០៛០០

រួមមាន : តំបន់ទេសចរណ៍: ស្ថិតនៅក្នុងតំបន់អូរឈើទាល ក្នុងនោះចែកចេញជាបីថ្នាក់ទៅតាម ដីមុខ និងដីក្រោយជាប់មាត់សមុទ្រនិងថ្នាក់បន្តបន្ទាប់ ។

តំបន់ពាណិជ្ជកម្ម: រាប់ពីរង្វង់មូលរូបតោអមផ្លូវប្រវែងពីឡូត៍សង្វាងផ្លូវរហូតដល់អនុវិទ្យាល័យសម្តេចឪ តំបន់ជុំវិញមហោស្រព និង ជុំវិញផ្សារលើ ក្នុងនោះចែកជាបីថ្នាក់ដូចគ្នា ។

តំបន់ស្នាក់នៅ : តំបន់ស្ថិតនៅក្រៅពីតំបន់ពាណិជ្ជកម្ម និងតំបន់ស្នាក់នៅក្នុងក្រុង ក្នុងនោះចែកជាបីថ្នាក់ដូចគ្នា ។

តំបន់ II តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡាសំរាប់ ថ្នាក់លេខ ១ = ១០.០០០៛០០

ថ្នាក់លេខ ២ = ៦.០០០,០០

ថ្នាក់លេខ ៣ = ៣.០០០,០០

រួមមាន :

- តំបន់រដ្ឋបាលជុំវិញសាលាក្រុងជុំវិញភ្នំ១០៨ក្នុងនោះចែកចេញជាបីថ្នាក់
- តំបន់ស្នាក់នៅទីប្រជុំជនខ័ណ្ឌមិត្តភាព ដីតាមផ្លូវលំធំក្នុងខ័ណ្ឌជុំវិញផ្សារនិងដីស្នាក់នៅប្រជុំជនខ័ណ្ឌព្រៃបន់ និងខ័ណ្ឌស្ទឹងហាវ ក្នុងនោះចែកចេញជាបីថ្នាក់ដូចគ្នា ។
- ចាប់ពីផ្លូវបំបែករ៉ារហូតដល់ស្ពានព្រែកក្រែងស្តាំដៃចំងាយពីផ្លូវ២០០ម៉ែត្រ ថ្នាក់លេខ១ ថ្នាក់លេខ២ ពី ២០០ម៉ែត្រ ដល់៤០០ម៉ែត្រ ពី៤០០ម៉ែត្រឡើងទៅ ថ្នាក់លេខ៣ ។
- ចាប់ពីស្ពានព្រែកក្រែង រហូតដល់រោងចក្រប្រេងកាត ស្តាំដៃចំងាយពីផ្លូវ ២០០ម៉ែត្រ ថ្នាក់លេខ២ ពី២០០ម៉ែត្រ ដល់ ៤០០ម៉ែត្រ ថ្នាក់លេខ៣ ។
- ចាប់ពីផ្លូវបំបែករ៉ារហូតដល់អូត្រាវសងខាងផ្លូវចំងាយ២០០ម៉ែត្រថ្នាក់លេខ១ ពី២០០ម៉ែត្រដល់៤០០ម៉ែត្រ ថ្នាក់លេខ២ ពី៤០០ម៉ែត្រដល់៦០០ម៉ែត្រថ្នាក់លេខ៣ ។
- ពីរោងចក្រប្រេងកាតដល់ផ្លូវរថភ្លើង រោងចក្រត្រីជីសង្កាត់អូព្រេះ សងខាងផ្លូវចំងាយ ៣០០ម៉ែត្រថ្នាក់

លេខ២ ពី ៣០០ម៉ែត្រដល់៦០០ម៉ែត្រថ្នាក់លេខ៣ ។

-តំបន់អូត្រេះចាស់ចាប់ពីភ្នំ៣៩ តាមបណ្តោយមាត់សមុទ្រ រហូតដល់ព្រែកអូត្រេះចម្ងាយពីចំណើសមុទ្រ ២០០ ម៉ែត្រ ថ្នាក់លេខ២ ។

តំបន់ III តំលៃគិតពន្ធក្នុងមួយម៉ែត្រទកឡាសំរាប់ ថ្នាក់លេខ ១ = ៥០០៛០០

ថ្នាក់លេខ ២ = ៣០០៛០០

ថ្នាក់លេខ ៣ = ១០០៛០០

រួមមាន :

- ដីដែលស្ថិតនៅក្រៅតំបន់ I និងតំបន់ II ខាងលើ ចាត់ទុកជាដីក្នុងតំបន់ III ។
- ដីអមសងខាងដងផ្លូវជាតិ និងផ្លូវលំជាយក្រុងចំងាយ ៥០០ម៉ែត្រ ថ្នាក់លេខ១ ចាប់ពី៥០០ម៉ែត្រដល់ ១០០០ម៉ែត្រ ថ្នាក់លេខ២ ចាប់ពី១០០០ម៉ែត្រ ឡើងទៅថ្នាក់លេខ៣ ។

រាជធានីភ្នំពេញថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥

ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

កែ ប៊ុល

រដ្ឋលេខាធិការទី ១ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រ កម្ពុជា
Kingdom Of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
Land Appraisal and Valuation Committee

ឧបសម្ព័ន្ធទី ៣

ការកំណត់បែងចែកតំបន់ និង តម្លៃដីក្នុងមួយម៉ែត្រក្រឡា
សម្រាប់គិតពន្ធលើដីធ្លីមិនបានប្រើប្រាស់
ខេត្តសៀមរាប

ភ្ជាប់ជាមួយសេចក្តីសំរេចលេខ ០០៧ សសរ.សហវ.ពដ ចុះថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

តំបន់ I ដីក្នុងស្រុកសៀមរាប

១- តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ៨០.០០០៛០០ គឺដីគ្រប់ប្រភេទក្នុងអតីតប្រព័ន្ធការពារក្រុងសៀមរាប និងដីសងខាងផ្លូវជាតិលេខ៦ ចម្ងាយ២៥០ម៉ែត្រ ។

២- តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ៤.០០០៛០០ គឺដីសង់លំនៅដ្ឋានក្រៅពីតំបន់ I ខាងលើ

៣- តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ១,០០០៛០០ គឺដីស្រែក្រៅពីតំបន់I.១និងតំបន់ I.២ខាងលើ

តំបន់ II ដីស្រុកផ្សេងៗក្រៅពីស្រុកសៀមរាប

១- តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ២.០០០៛០០ គឺដីអមសងខាងផ្លូវជាតិលេខ៦ ចម្ងាយ១០០ម៉ែត្រសងខាងផ្លូវក្នុងស្រុកពួក និប្រាសាទបាគង ។

២- តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ១,០០០៛០០ គឺដីអមសងខាងផ្លូវជាតិលេខ៦ ចម្ងាយ១០០ម ក្រៅពីតំបន់ II.១ខាងលើ។

៣- តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ៥០០៛០០ គឺដីក្រៅពីតំបន់ II.១និង II.២ខាងលើ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ ២០០៥
ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

ទិបុល
រដ្ឋលេខាធិការ -ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រុក្ខវិថី, ដូនពេញ, - សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣-៤២៦ ៧៤៩
Street. 92, Rukhak Vithei Daun Penh, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia Tel/Fax: 855-23 426 749

ព្រះរាជាណាចក្រ កម្ពុជា

Kingdom Of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

Land Appraisal and Valuation Committee

ឧបសម្ព័ន្ធទី ៤

ការកំណត់បែងចែកតំបន់ និង តម្លៃដីក្នុងមួយម៉ែត្រក្រឡា

សម្រាប់គិតពន្ធលើដីធ្លីមិនបានប្រើប្រាស់

ខេត្តកណ្តាល

ភ្ជាប់ជាមួយសេចក្តីសំរេចលេខ ០០៧ សសវ.សហវ.ពដ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

I. ដីលំនៅដ្ឋាន

តំបន់ I : រួមមាន :

-ស្រុកតាខ្មៅ

-ស្រុកអង្គស្នួល (ចាប់ពីព្រំប្រទល់រាជធានីភ្នំពេញទៅដល់ផុតឃុំបែកចាន)

-ស្រុកកៀនស្វាយ (ចាប់ពីព្រំប្រទល់រាជធានីភ្នំពេញទៅដល់ផុតឃុំគគីរ)

-ស្រុកមុខកំពូល (ចាប់ពីព្រំប្រទល់រាជធានីភ្នំពេញទៅដល់ផុតឃុំបាក់ខែង)

ត្រូវបែងចែកជា ៣ ប្រភេទ ដូចខាងក្រោមនេះ

ប្រភេទ ១ : តំលៃគិតពន្ធ២៥.០០០រ០០ ក្នុងមួយម៉ែត្រក្រឡា(ចាប់ពីផ្លូវជាតិទៅដល់ចំងាយ ២០០ម)

ប្រភេទ ២ : តំលៃគិតពន្ធ១៥.០០០រ០០ ក្នុងមួយម៉ែត្រក្រឡា(ចាប់ពី២០១ម ទៅដល់ចំងាយ ៥០០ម ពីផ្លូវជាតិ)

ប្រភេទ ៣ : តំលៃគិតពន្ធ១០.០០០រ០០ ក្នុងមួយម៉ែត្រក្រឡា(ចាប់ពី៥០១ម ឡើងទៅគិតពីផ្លូវជាតិ)

តំបន់ II : រួមមាន : - ស្រុកកណ្តាលស្ទឹង

- ស្រុកពញាឮ

- តំបន់ទួលក្រសាំងជាប់ផ្លូវលេខ ២១

- ស្រុកកៀនស្វាយ(ចាប់ពីឃុំដីឥដ្ឋទៅដល់ព្រំប្រទល់ស្រុកលើកដែក)

- ស្រុកអង្គស្នួល

ត្រូវបែងចែកជា ៣ ប្រភេទ ដូចខាងក្រោមនេះ

ប្រភេទ ១ : តំលៃគិតពន្ធ១០.០០០រ០០ ក្នុងមួយម៉ែត្រក្រឡា(ចាប់ពីផ្លូវជាតិទៅដល់ចំងាយ ២០០ម)

ប្រភេទ ២ : តំលៃគិតពន្ធ៨.០០០រ០០ ក្នុងមួយម៉ែត្រក្រឡា(ចាប់ពី២០១ម ទៅដល់ចំងាយ ៥០០ម ពីផ្លូវជាតិ)

ប្រភេទ ៣ : តំលៃគិតពន្ធ៥.០០០រ០០ ក្នុងមួយម៉ែត្រក្រឡា(ចាប់ពី៥០១ម ឡើងទៅគិតពីផ្លូវជាតិ)

តំបន់ III : ស្រុកទាំងឡាយណាដែលមិនបានចែងក្នុងតំបន់ I និង II ខាងលើហើយត្រូវបែងចែកជា ៣ ប្រភេទ

ប្រភេទ ១ : តំលៃគិតពន្ធ៨.០០០រ០០ ក្នុងមួយម៉ែត្រក្រឡា(ចាប់ពីផ្លូវជាតិទៅដល់ចំងាយ ២០០ម)

ប្រភេទ ២ : តំលៃគិតពន្ធ៥.០០០រ០០ ក្នុងមួយម៉ែត្រក្រឡា(ចាប់ពី២០១ម ទៅដល់ចំងាយ ៥០០ម ពីផ្លូវជាតិ)

ប្រភេទ ៣ : តំលៃគិតពន្ធ៣.០០០រ០០ ក្នុងមួយម៉ែត្រក្រឡា(ចាប់ពី៥០១ម ឡើងទៅគិតពីផ្លូវជាតិ)

II . ដីស្រែចំការ

តំបន់ I : រួមមាន :

-ស្រុកតាខ្មៅ

-ស្រុកអង្គស្នួល

-ស្រុកកៀនស្វាយ

-ស្រុកមុខកំពូល

ត្រូវបែងចែកជា ៤ ប្រភេទ ដូចខាងក្រោមនេះ

ប្រភេទ ១ : តំលៃគិតពន្ធ៣.០០០រ០០ ក្នុងមួយម៉ែត្រក្រឡា(ចាប់ពីផ្លូវជាតិទៅដល់ចំងាយ ២០០ម)

ប្រភេទ ២ : តំលៃគិតពន្ធ១.៥០០រ០០ ក្នុងមួយម៉ែត្រក្រឡា(ចាប់ពី២០១ម ទៅដល់ចំងាយ ៥០០ម ពីផ្លូវជាតិ ឬមាត់ទន្លេ)

ប្រភេទ ៣ : តំលៃគិតពន្ធ១.០០០រ០០ ក្នុងមួយម៉ែត្រក្រឡា(ចាប់ពី៥០១ម ឡើងទៅដល់១.០០០ម ពីផ្លូវជាតិ ឬមាត់ទន្លេ)

ប្រភេទ ៤ : តំលៃគិតពន្ធ ៧០០រ០០ ក្នុងមួយម៉ែត្រក្រឡា(ចាប់ពី១០០១រ០០ ឡើងទៅគិតពីផ្លូវជាតិឬមាត់ទន្លេ)

តំបន់ II ដីទាំងឡាយណាដែលនៅក្រៅពីតំបន់ I ហើយត្រូវបែងចែកជាបួនប្រភេទដូចខាងក្រោម :

ប្រភេទ ១ : តំលៃគិតពន្ធ១.៦០០រ០០ ក្នុងមួយម៉ែត្រក្រឡា(ចាប់ពីផ្លូវជាតិទៅដល់ចំងាយ ២០០ម)

ប្រភេទ ២ : តំលៃគិតពន្ធ ៨០០រ០០ ក្នុងមួយម៉ែត្រក្រឡា(ចាប់ពី២០១ម ទៅដល់ចំងាយ ៥០០ម ពីផ្លូវជាតិ ឬមាត់ទន្លេ)

ប្រភេទ ៣ : តំលៃគិតពន្ធ ៦០០រ០០ ក្នុងមួយម៉ែត្រក្រឡា(ចាប់ពី៥០១ម ឡើងទៅដល់១.០០០ម ពីផ្លូវជាតិ ឬមាត់ទន្លេ)

ប្រភេទ ៤ : តំលៃគិតពន្ធ ៤០០រ០០ ក្នុងមួយម៉ែត្រក្រឡា(ចាប់ពី១០០១ម ឡើងទៅគិតពីផ្លូវជាតិឬមាត់ទន្លេ)

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០៥

ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

គង់ វិបុល

រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រ កម្ពុជា

Kingdom Of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

Land Appraisal and Valuation Committee

ឧបសម្ព័ន្ធទី ៥

ការកំណត់បែងចែកតំបន់ និង តម្លៃដីក្នុងមួយម៉ែត្រក្រឡា

សម្រាប់គិតពន្ធលើដីធ្លីមិនបានប្រើប្រាស់

នៅខេត្តកំពង់ស្ពឺ

ភ្ជាប់ជាមួយសេចក្តីសំរេចលេខ០០៧ សសរ.សហវ.ពដ ចុះថ្ងៃទី២៩ ខែ ៨ ឆ្នាំ ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

I. **ដីលំនៅដ្ឋាន**

តំបន់ I តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ២០.០០០រ០០ គិតទីប្រជុំជន :

-ផ្សារកំពង់ស្ពឺ ស្រុកច្បារមន

-ផ្សារឧដុង្គ ស្រុក ឧដុង្គ

-ផ្សារត្រាំខ្នា ស្រុកគងពិសី

តំបន់ II តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ១៥.០០០រ០០ គិតទីប្រជុំជន :

- ផ្សារបាត់ដឹង ស្រុក ឧដុង្គ
- ផ្សារព្រៃភ្លៅ ស្រុកសំរោងទង
- ផ្សារត្រពាំងក្រឡឹង ស្រុក ភ្នំស្រួច
- ផ្សារ ថ្នល់បត់ ស្រុកបសេដ្ឋ
- ផ្សារបាំងកេសី ស្រុកបសេដ្ឋ
- ផ្សារដើមកោរ ស្រុកគងពិសី

តំបន់ III តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ៦.០០០រ០០

ក្រៅពី តំបន់ I និង II គ្រប់ស្រុកទូទាំងខេត្ត ចាត់ចូលក្នុង តំបន់ III

II. **ដីស្រែចំការ**

តំបន់ I តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ២.៥០០រ០០

ចំងាយពីផ្លូវជាតិដល់ជំរៅ២០០ម

- ស្រុកសំរោងទង
- ស្រុកច្បារមន
- ផ្លូវ៥១ ស្រុកឧដុង្គ

ដោយឡែក - តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា ២.០០០រ០០

- ស្រុកភ្នំស្រួច ស្រុកគងពិសី ស្រុកបសេដ្ឋ

តំបន់ II តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ១.៥០០រ០០ មានជំរៅពី២០១ម ដល់ ៦០០ម

- ស្រុកសំរោងទង
- ស្រុកច្បារមន
- ផ្លូវ ៥១

ចំពោះស្រុកគងពិសី ស្រុកភ្នំស្រួច និងស្រុកបសេដ្ឋ តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ១.០០០រ០០

តំបន់ III តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ៥០០រ០០ ចំពោះដីដែលស្ថិតនៅក្រៅពី តំបន់ I និង II ខាងលើ គ្រប់ស្រុកទូទាំងខេត្ត ចាត់ចូលក្នុង តំបន់ III

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០៥

ប្រធានគណៈកម្មការទារពន្ធលើដីមិនបានប្រើប្រាស់

គង់ វិបុល

រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រ កម្ពុជា

Kingdom Of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

Land Appraisal and Valuation Committee

ឧបសម្ព័ន្ធទី ៦

ការកំណត់បែងចែកតំបន់ និង តម្លៃដីក្នុងមួយម៉ែត្រក្រឡា

សម្រាប់គិតពន្ធលើដីធ្លីមិនបានប្រើប្រាស់

ខេត្តកំពង់ចាម

ភ្ជាប់ជាមួយសេចក្តីសំរេចលេខ ០០៣ សសរ.សហវ.ពជ ចុះថ្ងៃទី ២៩ ខែ ៨ ឆ្នាំ ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

I . <u>ដីលំនៅដ្ឋាន</u>

តំបន់ I តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ១០.០០០៛០០ គឺដីដែលស្ថិតនៅក្រុងកំពង់ចាម គិតជុំវិញផ្សារធំចម្ងាយ១.០០០ម

តំបន់ II តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ៥.០០០៛០០ គឺដីដែលស្ថិតនៅ :

- ស្រុកកំពង់ចាម ដីក្រៅពីតំបន់ I
- ស្រុកត្បូងឃ្មុំ គិតជុំវិញផ្សារសួងចម្ងាយ ១.០០០ម
- ស្រុកព្រៃឈរ គិតជុំវិញផ្សារព្រៃទទឹង ចម្ងាយ ៧០០ម
- ស្រុកកំពង់សៀម គិតតាមសងខាងផ្លូវជាតិលេខ៧ ចម្ងាយ ៣០០ម(គិតចាប់ពីព្រំប្រទល់ស្រុកកំពង់ចាមរហូតដល់ភ្នំប្រុស)
- គិតចម្ងាយ៥០០ម ជុំវិញផ្សារមាន :
  . ផ្សារស្គន់ស្រុកជើងព្រៃ
  . ផ្សារផ្អាវស្រុកបាធាយ
  . ផ្សារមេមត់ ស្រុកមេមត់
  . ផ្សារស្ទឹងស្រុកពញាក្រែក
  . ផ្សារអូរាំងឪ ស្រុកអូរាំងឪ
  . ផ្សារថ្នល់បែក ស្រុកចំការលើ
  . ផ្សារស្ទឹងត្រង់ ស្រុកស្ទឹងត្រង់

តំបន់ III តំលៃគិតពនក្នុងមួយម៉ែត្រក្រឡា = ៣.០០០៛០០

-គិតចំងាយ៥០០ម ជុំវិញផ្សារមាន:
  . ផ្សារពាមជីកង ស្រុកកងមាស
  . ផ្សារព្រៃកពោធិ ស្រុកស្រីសន្ធរ
  . ផ្សារជីហែរ ស្រុកកោះសូទិន
  . ផ្សារក្រូចឆ្មារ ស្រុកក្រូចឆ្មារ

. ស្រុកតំបែរ គិតចម្ងាយ៥០០ម ជុំវិញសាលាស្រុក

. ដីលំនៅដ្ឋានក្រៅពី តំបន់ I និងបន់ II

II . <u>ដីស្រែចំការ</u> :

ប្រភេទលេខ I តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា =១.០០០៛០០ :

-ដីស្រែចំការដែលស្ថិតនៅចំងាយ ៣០០ម សងខាងផ្លូវជាតិ

ប្រភេទលេខ II តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា =៤០០៛០០ :

- ដីស្រែចំការដែលស្ថិតនៅចំងាយលើសពី៣០០ម ដល់១០០០ម សងខាងផ្លូវជាតិ និង ចម្ងាយ៥០០ម សងខាងផ្លូវខេត្ត

- ដីស្រែចំការដែលស្ថិតនៅសងខាងដងទន្លេចម្ងាយ ៥០០ម

ប្រភេទលេខ III តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា =២០០៛០០

គឺដីស្រែចំការដែលឋិតនៅក្រៅពីប្រភេទលេខ I និងប្រភេទលេខ II ត្រូវចាត់ទុកជាតំបន់ III ។

រាជធានីភ្នំពេញថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

[illegible] វិបុល

រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រ កម្ពុជា

Kingdom Of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

Land Appraisal and Valuation Committee

ឧបសម្ព័ន្ធទី ៧

ការកំណត់បែងចែកតំបន់ និង តម្លៃដីក្នុងមួយម៉ែត្រក្រឡា សម្រាប់គិតពន្ធលើដីធ្លីមិនបានប្រើប្រាស់

ខេត្តស្វាយរៀង

ភ្ជាប់ជាមួយសេចក្តីសំរេចលេខ០០៧ សសរ.សហវ.ពដ ចុះថ្ងៃទី២៩ខែ ១២ ឆ្នាំ ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

តំបន់ I :តំលៃគិតពន្ធ១០.០០០៛០០ មួយម៉ែត្រក្រលាចំពោះដី :

-ស្ថិតជាប់ដងផ្លូវនានាក្នុងទីរួមខេត្ត :

-ស្ថិតជាប់សងខាងផ្លូវជាតិលេខ១ដល់២០០មគិតចាប់ពីមាត់ច្រកទ្វារអន្តរជាតិបាវិតមកដល់ពីរចំណុចខាងក្រោមនេះ :

. ខាងជើងផ្លូវជាតិលេខ១ ដល់ផ្លូវលំចូលវត្តសាលាកណ្តាល(ធ្លក) ក្នុងឃុំច្រកម្ទេស ស្រុកស្វាយទាប ។

. ខាងត្បូងផ្លូវជាតិលេខ១ ដល់ផ្លូវលំចូលវត្តព្រៃគគីរ ឃុំព្រៃអង្គុញស្រុកចន្ទ្រា(ដែលតែងហៅថាផ្លូវត្រពាំងសេមាន់) ។

តំបន់ II :តំលៃគិតពន្ធ៣.០០០៛០០ មួយម៉ែត្រក្រលាចំពោះដី :

-ដីស្ថិតជាប់សងខាងផ្លូវជាតិលេខ១ ដល់២០០ម ផុតការកំណត់ក្នុងតំបន់ ១ ។

តំបន់ III:តំលៃគិតពន្ធ១.០០០៛០០ មួយម៉ែត្រក្រលាចំពោះដី :

-ដីស្ថិតស្របសងខាងផ្លូវជាតិលេខ១ លើស ២០០ម ដល់៤០០ម ។

-ដីស្ថិតស្របសងខាងផ្លូវដល់ ២០០ម គិតចាប់ពីច្រកទ្វារទេ្វភាគីព្រៃវល្លិ៍មកដល់ វត្តព្រៃវល្លិ៍ឃុំថ្មី ស្រុកកំពង់រោទិ៍។

តំបន់ IV:តំលៃគិតពន្ធ ៥០០៛០០ មួយម៉ែត្រក្រលាចំពោះដី :

- ដីស្ថិតជាប់សងខាងផ្លូវខេត្តដល់ ២០០ម ដែលមានចំនួន៥ខ្សែគឺ:

.ពីទីរួមខេត្តឆ្លងកាត់សាលាស្រុករំដួល ទៅកាន់សាលាស្រុករមាសហែក និងច្រកទ្វារទេ្វភាគីបុសមន ។

.ពីទីរួមខេត្តឆ្លងកាត់សាលាឃុំចេក-ឃុំដូនស(ស្រុកស្វាយជ្រុំ) ឆ្ពោះទៅកាន់សាលាស្រុករមាសហែក ។

.ពីទីរួមស្រុកស្វាយទាប ឆ្លងកាត់សាលាស្រុកកំពង់រោទិ៍ ដល់វត្តព្រៃវល្លិ៍ឃុំថ្មី ។

.ពីផ្សារជីភូឆ្ពោះទៅកាន់សាលាស្រុកចន្ទ្រា

.ពីផ្សារជីភូឆ្លងកាត់សាលាឃុំពពែត -ព្រៃតាអី និងគគីរសោម ឆ្ពោះទៅកាន់សាលាស្រុករំដួល ។

តំបន់ V :តំលៃគិតពន្ធ ៣០០៛០០ មួយម៉ែត្រក្រលាចំពោះដី :

-ស្ថិតជាប់សងខាងផ្លូវផ្សេងៗទៀតក្រៅពីកំណត់ក្នុងតំបន់ ៤ ។

តំបន់ VI:តំលៃគិតពន្ធ ២០០៛០០ មួយម៉ែត្រក្រលាចំពោះដី :

- ស្ថិតស្របសងខាងផ្លូវជាតិលេខ ១ លើស ៤០០ម ដល់ ៦០០ម

- ស្ថិតស្របសងខាងផ្លូវខេត្តលើស ២០០ម ដល់៤០០ម ដូចមានចែងក្នុងតំបន់៤ ។

តំបន់ VII:តំលៃគិតពន្ធ ១៥០៛០០ មួយម៉ែត្រក្រលាចំពោះដី :

ចំពោះដីដែលនមានទីតាំងស្ថិតនៅក្រៅតំបន់ I-II-III-IV-V-VI ខាងលើ ។

រាជធានីភ្នំពេញថ្ងៃទី២៩ ខែ ៨ ឆ្នាំ ២០០៥

ប្រធានគណៈកម្មការទាយតំលៃដីមិនបានប្រើប្រាស់

[illegible] ចិបុល

រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រ កម្ពុជា

Kingdom Of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
Land Appraisal and Valuation Committee

ឧបសម្ព័ន្ធទី ៨

ការកំណត់បែងចែកតំបន់ និង តម្លៃដីក្នុងមួយម៉ែត្រក្រឡា
សម្រាប់គិតពន្ធលើដីធ្លីមិនបានប្រើប្រាស់
ខេត្តតាកែវ

ភ្ជាប់ជាមួយសេចក្តីសំរេចលេខ០០៧ សសរ.សហវ.ពដ ចុះថ្ងៃទី២៩ខែធ្នូ ឆ្នាំ ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

I . ដីលំនៅដ្ឋាន

តំបន់ I : តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា =៤.០០០រ០០ គិតទីប្រជុំជន

-ផ្សារតាកែវក្នុងស្រុកដូនកែវ

-ផ្សារអង្គតាសោមក្នុង ស្រុកត្រាំកក់

-ផ្សារសំរោងយ៉ោង និងផ្សារត្រាំខ្នារក្នុងស្រុកបាទី

-ផ្សារទន្លាប់ក្នុងស្រុកគីរីវង់

តំបន់ II : តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ២.០០០រ០០ គិតទីប្រជុំជន

- ផ្សារត្រាំកក់ ក្នុងស្រុកត្រាំកក់
- ផ្សារថ្នល់បត់ ក្នុងស្រុកសំរោង
- ផ្សារចុំងកាសី ក្នុងស្រុកសំរោង
- ផ្សារដើមកោរ និងផ្សារចំបក់ ក្នុងស្រុកបាទី
- ផ្សាររវៀង និង ផ្សារស្វាយព្រៃ ក្នុងស្រុកសំរោង

តំបន់ III: តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ១.០០០រ០០

ក្រៅពីតំបន់ I និងតំបន់ II គ្រប់ស្រុកទូទាំងខេត្ត ចាត់ចូលក្នុងតំបន់ III

II . ដីស្រែចំការ

តំបន់ I : តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ១.០០០រ០០ចំងាយ ៣០០ម អមសងខាងផ្លូវជាតិ :

-ស្រុកបាទី

-ស្រុកសំរោង

-ស្រុកត្រាំកក់

-ស្រុកដូនកែវ

-ស្រុកទ្រាំង

-ស្រុកកោះអណ្តែត

-ស្រុកគិរីវង់

តំបន់ II : តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ៥.០០៛០០ ចំងាយចាប់ពី៣០០មដល់៦០០មតាមដងផ្លូវជាតិ និងចំងាយ៣០០មតាមដងផ្លូវខេត្ត ។

-ស្រុកបាទី

-ស្រុកសំរោង

-ស្រុកត្រាំកក់

-ស្រុកទ្រាំង

-ស្រុកកោះអណ្ដែត

-ស្រុកគិរីវង់

-ស្រុកព្រៃកប្បាស

-ស្រុកអង្គរបូរិ

តំបន់ III : តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ៣០០៛០០ ដីដែលឋិតនៅក្រៅពីតំបន់ I និងតំបន់ II ខាងលើ គ្រប់ស្រុកទូទាំងខេត្ត ចាត់ចូលជាតំបន់ III ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ [illegible] ឆ្នាំ ២០០៥

ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

គង់ វិបុល

រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រ កម្ពុជា

Kingdom Of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

Land Appraisal and Valuation Committee

ឧបសម្ព័ន្ធទី ៩

ការកំណត់បែងចែកតំបន់ និង តម្លៃដីក្នុងមួយម៉ែត្រក្រឡា

សម្រាប់គិតពន្ធលើដីធ្លីមិនបានប្រើប្រាស់

បាត់ដំបង

ភ្ជាប់ជាមួយសេចក្តីសំរេចលេខ០៧៣ សសរ.សហវ.ពជ ចុះថ្ងៃទី២៩ខែធ្នូ ឆ្នាំ ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

I . <u>ដីលំនៅដ្ឋាន</u>

តំបន់ I : តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ១២.០០០៛០០

- ដីលំនៅដ្ឋានស្ថិតនៅស្រុកខេត្តបាត់ដំបង
- ដីលំនៅដ្ឋានស្ថិតនៅសងខាងផ្លូវជាតិលេខ៥ ចំងាយ២០០ម
- ស្រុកមោងឫស្សី : ខាងកើតទល់និងបន្ទាយទាហាន ខាងលិចទល់និងផ្លូវចូលទៅរលួស
- ស្រុកសង្កែ : ខាងកើតទល់និងស្វាយកង់ ខាងលិចទល់និងព្រំប្រទល់ស្រុកបាត់ដំបង
- ស្រុកថ្មគោល : ខាងត្បូងទល់និងមន្ទីរពេទ្យស្រុក ខាងជើងទល់និងមន្ទីរពេទ្យចាស់

តំបន់ II : តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ៧.០០០៛០០

- ដីលំនៅដ្ឋានស្រុកបាណន់ទាំងមូល ក្នុងរង្វង់កាំ ៥០០ម ពីសាលាស្រុក
- ដីលំនៅដ្ឋានស្រុករតនមណ្ឌលទាំងមូល ក្នុងរង្វង់កាំ ៥០០ម ពីសាលាស្រុក
- ដីលំនៅដ្ឋានស្រុកឯកភ្នំទាំងមូល ក្នុងរង្វង់កាំ ៥០០ម ពីសាលាស្រុក
- ដីលំនៅដ្ឋានស្រុកបវេលទាំងមូល ក្នុងរង្វង់កាំ ៥០០ម ពីសាលាស្រុក

តំបន់ III: តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ៥.០០០៛០០

- ដីលំនៅដ្ឋានដែលឆ្ងាយផុតពីតំបន់ I និងតំបន់ II
- ដីលំនៅដ្ឋានស្រុកសំឡូតទាំងមូល
- ដីលំនៅដ្ឋានស្រុកគាស់ក្រឡទាំងមូល
- ដីលំនៅដ្ឋាននៅស្រុកសំពៅលូនទាំងមូល
- ដីលំនៅដ្ឋាននៅស្រុកភ្នំព្រឹកទាំងមូល
- ដីលំនៅដ្ឋាននៅស្រុកកំរៀងទាំងមូល

ផ្លូវទី៩២, រុក្ខវិថីដូនពេញ, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣-៤២៦ ៧៤៩
Street. 92, Rukhak Vithei Daun Penh, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia Tel/Fax: 855-23 426 749

II . ដីស្រែ

តំបន់ I : តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ២០០៛០០

-ដីស្រែដែលស្ថិតនៅតាមបណ្តោយសងខាងផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវស្រុក គិតចំងាយ៥០០ម

-ដីស្រែដែលស្ថិតនៅសងខាងស្ទឹងក្នុងខេត្តដោយគិតចំងាយ៥០០ម

តំបន់ II : តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ១០០៛០០

-ដីស្រែដែលនៅឆ្ងាយផុតពីការកំណត់តំបន់ I

III . ដីចំការ

តំបន់ I : តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ១.០០០៛០០

- ដីចំការដែលស្ថិតនៅតាមបណ្តោយសងខាងផ្លូវជាតិ ផ្លូវខេត្ត និង ផ្លូវស្រុក គិតចំងាយដល់ ៥០០ម៉ែត្រ

- ដីចំការដែលស្ថិតនៅសងខាងស្ទឹងក្នុងខេត្តដោយគិតចំងាយ៥០០ម

តំបន់ II : តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ៥០០៛០

-ដីចំការដែលនៅឆ្ងាយផុតពីការកំណត់ក្នុងតំបន់ I

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៥

ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

[illegible]

រដ្ឋលេខាធិការទី ១ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រ កម្ពុជា

Kingdom Of Cambodia

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
Land Appraisal and Valuation Committee

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

ឧបសម្ព័ន្ធទី ១០

ការកំណត់បែងចែកតំបន់ និង តម្លៃដីក្នុងមួយម៉ែត្រក្រឡា
សម្រាប់គិតពន្ធលើដីធ្លីមិនបានប្រើប្រាស់
ពោធិ៍សាត់

ភ្ជាប់ជាមួយសេចក្តីសំរេចលេខ ០០៧ សសរ.សហវ.ពដ ចុះថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

I . ដីលំនៅដ្ឋាន

តំបន់ I : តំលៃគិតពន្ធអប្បបរមា ៤.000៛00 ក្នុងមួយម៉ែត្រក្រឡា

តំលៃគិតពន្ធអតិបរមា១០.000៛00 ក្នុងមួយម៉ែត្រក្រឡា

-ជុំវិញផ្សារទីរួមខេត្ត

-តាមបណ្តោយផ្លូវជាតិលេខ៥ ចាប់ពីសាលាគរុដល់ស្ពានស្វាយអាត់

តំបន់ II : តំលៃគិតពន្ធអប្បបរមា ២.000៛00 ក្នុងមួយម៉ែត្រក្រឡា

តំលៃគិតពន្ធអតិបរមា ៤.000៛00 ក្នុងមួយម៉ែត្រក្រឡា

- តំបន់ជាយក្រុង ទីប្រជុំជនស្រុកសំពៅមាស
- តំបន់ជុំវិញផ្សារស្រុកក្រគរ ស្រុកបាកាន ស្រុកភ្នំក្រវាញ ស្រុកកណ្តៀង

តំបន់ III : តំលៃគិតពន្ធអប្បបរមា ១.000៛00 ក្នុងមួយម៉ែត្រក្រឡា

តំលៃគិតពន្ធអតិបរមា ២.000៛00 ក្នុងមួយម៉ែត្រក្រឡា

ដីក្រៅពីតំបន់ I និងតំបន់ II ។

II . ដីស្រែចំការ

តំបន់ I : តំលៃគិតពន្ធអប្បបរមា ២00៛00 ក្នុងមួយម៉ែត្រក្រឡា

តំលៃគិតពន្ធអតិបរមា ៥00៛00 ក្នុងមួយម៉ែត្រក្រឡា

-ដីតាមបណ្តោយស្ទឹងពោធិ៍សាត់ ចាប់ពីស្រុកកណ្តៀង ដល់ស្រុកភ្នំក្រវាញ

តំបន់ II : តំលៃគិតពន្ធអប្បបរមា ១00៛00 ក្នុងមួយម៉ែត្រក្រឡា

តំលៃគិតពន្ធអតិបរមា ២00៛00 ក្នុងមួយម៉ែត្រក្រឡា

-ដីក្នុងស្រុកបាកាន

-ដីក្នុងស្រុកកណ្តៀង

តំបន់ III : តំលៃគិតពន្ធអប្បបរមា ៥០៖០០ ក្នុងមួយម៉ែត្រក្រឡា

តំលៃគិតពន្ធអតិបរមា ១០០៖០០ ក្នុងមួយម៉ែត្រក្រឡា

ដីដែលឋិតនៅក្រៅពីតំបន់ I និងតំបន់ II ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០៥

ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

គង់ វិបុល

រដ្ឋលេខាធិការ [illegible] ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រ កម្ពុជា

Kingdom Of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

Land Appraisal and Valuation Committee

ឧបសម្ព័ន្ធទី ១១

ការកំណត់បែងចែកតំបន់ និង តម្លៃដីក្នុងមួយម៉ែត្រក្រឡា សម្រាប់គិតពន្ធលើដីធ្លីមិនបានប្រើប្រាស់

ខេត្តកំពត

ភ្ជាប់ជាមួយសេចក្តីសំរេចលេខ០០៧ សសរ.សហវ.ពដ ចុះថ្ងៃទី២៦ ខែ ៨ ឆ្នាំ ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

I . ដីលំនៅដ្ឋាន

តំបន់ I តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ៧.០០០៛០០ -១០.០០០៛០០គឺដីដែលស្ថិតនៅទីប្រជុំជន :

-ផ្សារសាមគ្គីក្នុងស្រុកកំពង់បាយ(តំលៃគិតពន្ធមួយម៉ែត្រក្រលា១០.០០០៛០០)

-ដីអមផ្លូវក្រាលកៅស៊ូតាមឃុំទាំង៤ គឺ ឃុំកំពង់បាយ.ក្រាំងអំពិល. កំពង់កណ្តាល.អណ្តូងខ្មែរ ក្នុងស្រុកកំពង់បាយ(តំលៃគិតពន្ធមួយម៉ែត្រក្រលា ៧.០០០៛០០) ។

តំបន់ II តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ៣.០០០៛០០ -៥.០០០៛០០គឺដីដែលស្ថិតនៅទីប្រជុំជន:

- ផ្សារទីរួមស្រុកឈូក (តំលៃគិតពន្ធមួយម៉ែត្រក្រលា ៥.០០០៛០០)
- ផ្សារទីរួមស្រុកកំពង់ត្រាច
- ផ្សារទីរួមស្រុកបន្ទាយមាស
- ផ្សារទីរួមស្រុកអង្គរជ័យ

(តំលៃគិតពន្ធមួយម៉ែត្រក្រលា ៣.០០០៛០០)

តំបន់ III តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ២.០០០៛០០ ដីដែលឋិតនៅក្រៅតំបន់ I និងតំបន់ II គ្រប់ស្រុកទូទាំងខេត្ត ចាត់ទុកជាតំបន់ III ។

II . ដីស្រែចំការ

តំបន់ I តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា =១.០០០៛០០ -២.០០០៛០០ គឺដីដែលស្ថិតអមសងខាងផ្លូវកៅស៊ូចំងាយចាប់ពី៣០០ម :

-ស្រុកកំពង់បាយ
-ស្រុកឈូក
-ស្រុកកំពត

(តំលៃគិតពន្ធមួយម៉ែត្រក្រលា ២.០០០៛០០)

-ស្រុកកំពង់ត្រាច
-ស្រុក បន្ទាយមាស
-ស្រុកអង្គរជ័យ
-ស្រុកដងទង
-ស្រុកជុំគិរី

(តំលៃគិតពន្ធមួយម៉ែត្រក្រលា ១.០០០៛០០)

រុក្ខវិថី, ដូនពេញ, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣-៤២៦ ៧៤៩

Street. 92, Rukhak Vithei Daun Penh, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia Tel/Fax: 855-23 426 749

តំបន់ II តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា =៥០០រ០០ គឺដីដែលស្ថិតអមសងខាងផ្លូវកៅស៊ូចំងាយចាប់ពី៣០០ម ដល់៦០០ម :

-ស្រុកកំពត

-ស្រុកកំពង់ត្រាច

-ស្រុក បន្ទាយមាស

-ស្រុកអង្គរជ័យ

-ស្រុកឈូក

-ស្រុកដងទុង

-ស្រុកជុំគិរី

តំបន់ III តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា =២០០រ០០ ដីដែលឋិតនៅក្រៅតំបន់ I និងតំបន់ II ខាងលើ គ្រប់ស្រុកទូទាំងខេត្ត លើកលែងស្រុកកំពង់បាយ ចាត់ទុកជាតំបន់ III ។

រាជធានីភ្នំពេញថ្ងៃទី២៩ខែ ធ្នូ ឆ្នាំ ២០០៥

ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

ប៊ុល

រដ្ឋលេខាធិការទី-១-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រ កម្ពុជា
Kingdom Of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
Land Appraisal and Valuation Committee

ឧបសម្ព័ន្ធទី ១២

ការកំណត់បែងចែកតំបន់ និង តម្លៃដីក្នុងមួយម៉ែត្រក្រឡា សម្រាប់គិតពន្ធលើដីធ្លីមិនបានប្រើប្រាស់ នៅខេត្តបន្ទាយមានជ័យ

ភ្ជាប់ជាមួយសេចក្តីសំរេចលេខ០០៧សសរ.សហវ.ពដ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

I. ស្រុកមង្គលបូរី

១-តំបន់ I តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា :

- ៤០.០០០៛០០
- ២០.០០០៛០០
- ១០.០០០៛០០

ដីពីគល់ស្ពានព្រំដែនទៅសាលាស្រុកចំងាយ ៥០០ម៉ែត្រ សងខាងផ្លូវជាតិលេខ៥

២-តំបន់ II តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា :

១- ១០.០០០៛០០
២- ៥.០០០៛០០
៣- ៥០០៛០០

ចាប់ពីសាលាស្រុក ដល់គល់ស្ពានព្រំដែនចំងាយ១០០០ម ដីសងខាងផ្លូវជាតិលេខ៥ (ក្រៅពីតំបន់ I) ។

៣- តំបន់ III តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា :

១- ២០.០០០៛០០
២- ១០.០០០៛០០
៣- ៥.០០០៛០០
៤- ៥០០៛០០

ចាប់ពីសាលាស្រុកដល់កូនដីចំងាយ៥០០ម ដីសងខាងផ្លូវជាតិលេខ៥ ។

៤- តំបន់ IV តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា :

១- ៤.០០០៛០០
២- ២.០០០៛០០
៣- ១.០០០៛០០
៤- ៥០០៛០០

វិថី, ដូនពេញ, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ ទូរស័ព្ទ/ហ្វាក់: ៨៥៥-២៣-៤២៦ ៧៤៩
Street. 92, Rukhak Vithei Daun Penh, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia Tel/Fax: 855-23 426 749

៥- ១០០៖០០

៦- ៥០៖០០

ដីក្នុងឃុំប៉ោយប៉ែត ឃុំអូរបីជាន់ ឃុំនិមិត្តក្រៅពីតំបន់ I II III ។

II-ស្រុកសិរីសោភ័ណ ថ្មពួក ស្វាយចេក ភ្នំស្រុក ព្រះនេត្រព្រះ មង្គលបូរី ៖

១- តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា ៖

១- ២.០០០៖០០

២- ១.០០០៖០០

៣- ៥០០៖០០

៤- ១០០៖០០

៥- ៥០៖០០

ដីក្នុងស្រុកសេរីសោភ័ណ ថ្មពួក ស្វាយចេក ភ្នំស្រុក ព្រះនេត្រព្រះ មង្គលបូរី

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ [illegible] ឆ្នាំ ២០០៥

ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

គាត ឈន់

រដ្ឋលេខាធិការទី ១ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រ កម្ពុជា

Kingdom Of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

Land Appraisal and Valuation Committee

ឧបសម្ព័ន្ធទី ១៣

ការកំណត់បែងចែកតំបន់ និង តម្លៃដីក្នុងមួយម៉ែត្រក្រឡា

សម្រាប់គិតពន្ធលើដីធ្លីមិនបានប្រើប្រាស់

នៅខេត្តក្រចេះ

ភ្ជាប់ជាមួយសេចក្តីសំរេចលេខ ០០៧ សសរ.សហវ.ពជ ចុះថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

តំបន់ I តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ២.០០០៛០០ ទៅ ៣.០០០៛០០ គឺដីនៅទីរួមខេត្ត

- គិតចាប់ពីអុងកូទល់ស្ពានអណ្តែងដូន ក្នុងជំរៅ១០០ម ពីផ្លូវក្រោយទីរួមខេត្ត
- ចាប់ពីរង្វង់មូលរហូតដល់វិមានសពក្នុងជំរៅ១០០ម សងខាងផ្លូវជាតិ

តំបន់ II តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ១.០០០៛០០ ទៅ ១.៨០០៛០០

- ដីទីរួមខេត្តដែលមានជំរៅលើសពី១០០ម ពីផ្លូវក្រោយទីរួមខេត្ត
- ដីទីរួមស្រុកទាំង៥ដែលមានជំរៅ១០០ម ពីផ្លូវក្រោយនៃស្រុកនីមួយៗ

តំបន់ III តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ៥០០៛០០ ទៅ ៨០០៛០០

- ដីទីរួមស្រុកក្នុងជំរៅលើសពី១០០ម ពីផ្លូវក្រោយនៃស្រុកនីមួយៗ
- ដីស្ថិតនៅសងខាងផ្លូវជាតិលេខ៧ មានជំរៅលើសពី ៥០០ម
- ដីស្ថិតនៅតាមផ្លូវលំនានា និងតាមផ្លូវមាត់ទន្លេ

តំបន់ IV តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ១០០៛០០ ទៅ ២០០៛០០

- ដីដែលស្ថិតនៅក្រៅតំបន់ I+II+III ខាងលើ គឺចាត់ទុកជាដីក្នុងតំបន់ IV ។

រាជធានីភ្នំពេញថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០៥

ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

គង់ វិបុល

រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

វិថីទី, ដូនពេញ, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣-៤២៦ ៧៤៩

Street. 92, Rukhak Vithei Daun Penh, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia Tel/Fax: 855-23 426 749

ព្រះរាជាណាចក្រ កម្ពុជា

Kingdom Of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

Land Appraisal and Valuation Committee

ឧបសម្ព័ន្ធទី ១៤

ការកំណត់បែងចែកតំបន់ និង តម្លៃដីក្នុងមួយម៉ែត្រក្រឡា

សម្រាប់គិតពន្ធលើដីធ្លីមិនបានប្រើប្រាស់

ខេត្តព្រៃវែង

ភ្ជាប់ជាមួយសេចក្តីសំរេចលេខ ០១៧ សសរ.សហវ.ពដ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

១-តំលៃគិតពន្ធ អប្បបរមា ៣០០៛០០ ក្នុងមួយម៉ែត្រក្រឡា

-តំលៃគិតពន្ធ អតិបរិមា ១០.០០០៛០០ ក្នុងមួយម៉ែត្រក្រឡា អនុវត្តក្នុងស្រុកកំពង់លាវ ។

២- តំលៃគិតពន្ធ អប្បបរមា ៣០០៛០០ ក្នុងមួយម៉ែត្រក្រឡា

- តំលៃគិតពន្ធ អតិបរិមា ១២.០០០៛០០ ក្នុងមួយម៉ែត្រក្រឡា អនុវត្តក្នុងស្រុកពាមរក៏ ។

៣- តំលៃគិតពន្ធ អប្បបរមា ២០០៛០០ ក្នុងមួយម៉ែត្រក្រឡា

- តំលៃគិតពន្ធ អតិបរិមា ៨.០០០៛០០ ក្នុងមួយម៉ែត្រក្រឡាអនុវត្តក្នុងស្រុកព្រៃវែង ស្រុកកំពង់ត្របែក និងស្រុកបាភ្នំ ។

៤- តំលៃគិតពន្ធ អប្បបរមា ១០០៛០០ ក្នុងមួយម៉ែត្រក្រឡា

- តំលៃគិតពន្ធ អតិបរិមា ៦.០០០៛០០ ក្នុងមួយម៉ែត្រក្រឡា

អនុវត្តក្នុងស្រុកព្រះស្តេច ស្រុកពាមជរ ស្រុកស្វាយអន្ទរ ស្រុកកំចាយមារ ស្រុកកញ្ជ្រៀច ស្រុកពារាំង និងស្រុកស៊ីធរកណ្តាល។

រាជធានីភ្នំពេញថ្ងៃទី ២៩ ខែ ៥ ឆ្នាំ ២០០៥

ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

រដ្ឋលេខាធិការទី ១ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រុក្ខវិថី, ដូនពេញ, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣-៤២៦ ៧៤៩

Street. 92, Rukhak Vithei Daun Penh, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia Tel/Fax: 855-23 426 749

ព្រះរាជាណាចក្រ កម្ពុជា

Kingdom Of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

Land Appraisal and Valuation Committee

ឧបសម្ព័ន្ធទី ១៥

ការកំណត់បែងចែកតំបន់ និង តម្លៃដីក្នុងមួយម៉ែត្រក្រឡា សម្រាប់គិតពន្ធលើដីធ្លីមិនបានប្រើប្រាស់ នៅខេត្តកោះកុង

ភ្ជាប់ជាមួយសេចក្ដីសំរេចលេខ ០០៧ សសរ.សហវ.៣ដ ចុះថ្ងៃទី ២៩ខែ ៥ ឆ្នាំ ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

តំបន់ I តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡាសំរាប់ ថ្នាក់លេខ ១ = ៥.០០០៛០០

ថ្នាក់លេខ ២ = ៣.០០០៛០០

ថ្នាក់លេខ ៣ = ២.៥០០៛០០

- ដីស្ថិតនៅក្នុងប្រជុំជនស្រុកស្មាច់មានជ័យ ស្រុកស្រែអំបិល
- អមផ្លូវពីគល់ស្ពានកោះប៉ោ ដល់ ក្រុមហ៊ុន ឌូធីហ្វ្រីសប
- ដីកំពង់ផែម៉ុងឫទ្ធី (ជាប់មាត់សមុទ្រ)

តំបន់ II តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡាសំរាប់ ថ្នាក់លេខ១ = ២.០០០៛០០

ថ្នាក់លេខ ២ = ១.៥០០៛០០

ថ្នាក់លេខ ៣ = ១.០០០៛០០

- ដីសង្ខាងផ្លូវថ្នល់បំបែកសាលាស្រុក មណ្ឌលសីមាដល់ប៉ាក់ខ្លង
- ដីក្រោយសាលាស្រុកមណ្ឌលសីមា
- ដីជាយស្រុកស្មាច់មានជ័យ និងស្រុកស្រែអំបិល

តំបន់ III តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡាសំរាប់ ថ្នាក់លេខ ១ =៨០០៛០០

ថ្នាក់លេខ ២ =៥០០៛០០

ថ្នាក់លេខ ៣ =២០០៛០០

- ដីស្រុកមណ្ឌលសីមា ស្រុកស្មាច់មានជ័យ ស្រុកស្រែអំបិល ស្រុកកំពង់សីលា
- ដីចំការ ស្រុកគិរីសាគរ ស្រុកបូទុមសាគរ ស្រុកថ្មបាំង ស្រុកកោះកុង ។
- ដីសង្ខាងផ្លូវជាតិលេខ ៤៨

រាជធានីភ្នំពេញ ថ្ងៃទី ២៩ខែ ៥ ឆ្នាំ ២០០៥

ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

គាត់ ឈន់

[illegible] សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រ កម្ពុជា

Kingdom Of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

Land Appraisal and Valuation Committee

ឧបសម្ព័ន្ធទី ១៦

ការកំណត់បែងចែកតំបន់ និង តម្លៃដីក្នុងមួយម៉ែត្រក្រឡា សម្រាប់គិតពន្ធលើដីធ្លីមិនបានប្រើប្រាស់ នៅខេត្តកំពង់ធំ

ភ្ជាប់ជាមួយសេចក្តីសំរេចលេខ ០០៧ សសរ.សហវ.ពដ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

១-ដីលំនៅដ្ឋាន

តំបន់ I : តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ៦.០០០៛០០

រួមមាន :

១-ស្រុកស្ទឹងសែន

- ដីទីប្រជុំជនស្រុកស្ទឹងសែន
- ដីតាមបណ្តោយផ្លូវជាតិលេខ៦ពីឃុំអាចារ្យលាក់ដល់ឃុំត្បូងក្រពើ១០០ម ពីផ្លូវជាតិ

២-ស្រុកសន្ទុក

- ដីទីប្រជុំជនស្រុកសន្ទុក
- ដីតាមបណ្តោយផ្លូវជាតិលេខ៦ពីឃុំកកោះដល់ឃុំកំពង់ថ្ម១០០មពីផ្លូវជាតិ

៣-ស្រុកបារាយណ៍

- ដីទីប្រជុំជនកំពង់ថ្ម បារាយណ៍ រំលង និងតាំងគោក
- ដីតាមបណ្តោយផ្លូវជាតិលេខ៦ពីឃុំកំពង់ថ្ម ដល់ឃុំសូយោង
- ដីពីគល់ស្ពានកំពង់ថ្ម ដល់ទំនប់១មករា១០០ម ពីផ្លូវជាតិ

៤-ស្រុកកំពង់ស្វាយ

- ដីតាមបណ្តោយផ្លូវជាតិលេខ៦ពីឃុំត្រពាំងឫស្សី ដល់ឃុំសាន់គរ១០០ម ពីផ្លូវជាតិ

៥-ស្រុកស្ទោង

- ដីទីប្រជុំជនស្រុកស្ទោង
- ដីតាមបណ្តោយផ្លូវជាតិលេខ៦ ពីឃុំចំណារលើដល់វិទ្យាល័យស្ទឹសោភ័ណស្ទោង១០០ម ពីផ្លូវជាតិ ។

តំបន់ II : តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ៤.០០០៛០០

រួមមាន:

រុក្ខវិថី, ដូនពេញ, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣-៤២៦ ៧៤៩
Street. 92, Rukhak Vithei Daun Penh, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia Tel/Fax: 855-23 426 749

១-ស្រុកប្រាសាទបល្ល័ង្គ

- ដីទីប្រជុំជនស្រុកប្រាសាទបល្ល័ង្គ
- ដីតាមបណ្តោយផ្លូវជាតិលេខ ៦៤ ពីឃុំសាលាវិស័យដល់ព្រំប្រទល់ខេត្តព្រះវិហារ

២-ស្រុកប្រាសាទសំបូរ

- ដីទីប្រជុំជនភូមិកំពង់ឈើទាល ឃុំសំបូរ
- ដីទីប្រជុំជនភូមិ ឈូក ឃុំឈូក

៣-ស្រុកសណ្តាន់

- ដីទីប្រជុំជនភូមិមានជ័យ ឃុំមានជ័យ
- ដីទីប្រជុំជន់ភូមិឈើទាល ឃុំឈើទាល
- ដីទីប្រជុំជន់ភូមិសណ្តាន់ ឃុំសណ្តាន់

តំបន់ III : ដីស្រែតំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ២០០៖០០

រាជធានីភ្នំពេញ ថ្ងៃទី២៨ខែ ៨ ឆ្នាំ ២០០៥

ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

គង់ វិបុល

រដ្ឋលេខាធិការទី ១ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រ កម្ពុជា

Kingdom Of Cambodia

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
Land Appraisal and Valuation Committee

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

ឧបសម្ព័ន្ធទី ១៧

ការកំណត់បែងចែកតំបន់ និង តម្លៃដីក្នុងមួយម៉ែត្រក្រឡា សម្រាប់គិតពន្ធលើដីធ្លីមិនបានប្រើប្រាស់

ខេត្តកំពង់ឆ្នាំង

ភ្ជាប់ជាមួយសេចក្តីសំរេចលេខ០០៧ សសរ.សហវ.ពដ ចុះថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

I . ដីលំនៅដ្ឋាន

តំបន់ I : តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា ៥.០០០៛០០

១-ស្រុកសាមគ្គីមានជ័យ : ដីនៅតាមផ្លូវជាតិលេខ៥ ដែលមានជំរៅ ២០០ម ចេញពីថ្នល់ជាតិ ចាប់ពី ផ្សារក្រោច ដល់បន្ទាយចុំាចាស់ ។

២-ស្រុកកំពង់ត្រឡាច : ដីនៅតាមផ្លូជាតិលេខ៥ ដែលមានជំរៅ ២០០ម ចេញពីថ្នល់ជាតិ ចាបពីវត្តតាកុល មកដល់មាត់ភូមិច្រករមៀត ។

៣-ស្រុករលាប្អៀរ : ដីនៅតាមផ្លូវជាតិលេខ៥ ដែលមានជំរៅ ២០០ម ចេញពីថ្នល់ជាតិចាបពីវត្តត្រពាំងស្នោរ បែកខាងត្បូងមកដល់ដីរីស និង ចាប់ពីសាលារៀនស្ទឹងជ្រុំដល់រោងចក្រផលិតសាជូបែកខាងជើង ។

៤-ស្រុកកំពង់ឆ្នាំង : ដីនៅតាមផ្លូវជាតិលេខ៥ ដែលមានជំរៅ ២០០ម ចេញពីថ្នល់ជាតិ ចាប់ពីដីរីស ដល់ទួលក្រាំង និងក្នុងទីប្រជុំជន ស្រុកកំពង់ឆ្នាំង ។

៥-ស្រុកបរិបូណ៌ : ដីនៅតាមផ្លូវជាតិលេខ៥ ដែលមានជំរៅ ២០០ម ចេញពីថ្នល់ជាតិ ចាប់ពីវិទ្យាល័យស្រុកបរិបូណ៌ ដល់ចុងភូមិកែវឡាត ។

តំបន់ II : តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា ៤.០០០៛០០

- ដីដែលនៅតាមផ្លូវជាតិលេខ៥ ដែលមានជំរៅចេញពីតំបន់ I ប្រវែង ៥០០ម ។

តំបន់ III : តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា ២.០០០៛០០

- ដីនៅតាមផ្លូវជាតិលេខ៥ ដែលមានជំរៅចេញពីតំបន់ IIទៅ ។

II . ដីស្រែចំការ

តំបន់ I : តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា ១.០០០៛០០

-ដីនៅតាមដងទន្លេសាប ដែលមានជំរៅចេញពីមាត់ទន្លេ ២០០ម៉ែត្រ ។

-ដីនៅតាមដងផ្លូវជាតិលេខ៥ ចាប់ពីព្រំប្រទល់រវាងខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំងដល់ព្រំប្រទល់

ខេត្តកំពង់ឆ្នាំង រវាងខេត្តពោធិសាត់ដែលមានជំរៅ២០០មចេញពីផ្លូវជាតិ ក្រៅពីតំបន់ I
ដីលំនៅដ្ឋាន ។

តំបន់ II : តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា ៥០០៛០០

-ដីតភ្ជាប់ពីតំបន់ I ខាងលើមិនលើសពី ៥០០ម

តំបន់ III: តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា ៣០០៛០០

ដីទាំងឡាយណាដែលពុំមាននៅក្នុងតំបន់ I និង II ខាងលើត្រូវចាត់ចូលតំបន់ III ទាំងអស់។

រាជធានីភ្នំពេញ ថ្ងៃទី៧ ៩ខែ ៨ ឆ្នាំ ២០០៥

ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

គង់ វិបុល

រដ្ឋលេខាធិការទី ១ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រ កម្ពុជា

Kingdom Of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

Land Appraisal and Valuation Committee

ឧបសម្ព័ន្ធទី ១៨

ការកំណត់បែងចែកតំបន់ និង តម្លៃដីក្នុងមួយម៉ែត្រក្រឡា

សម្រាប់គិតពន្ធលើដីធ្លីមិនបានប្រើប្រាស់

ក្រុងកែប

ភ្ជាប់ជាមួយសេចក្តីសំរេចលេខ សសរ.សហវ.៣៨ ចុះថ្ងៃទី ខែ ឆ្នាំ ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

តំបន់ I : សង្កាត់កែប និង ព្រៃធំ :

១- ថ្នាក់ទី១: តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ៥.០០០៛០០ ដោយគិតចម្ងាយ១០០ម៉ែត្រ សងខាងផ្លូវជាតិលេខ 33A ពីសាលាបឋមសិក្សាស្មរ ដល់សាលាបឋមសិក្សាកែប ។

២- ថ្នាក់ទី២: តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ៣.០០០៛០០ ដោយគិតចម្ងាយ១០០ម ដល់២០០ម សងខាងផ្លូវជាតិលេខ 33A ពីសាលាបឋមសិក្សាស្មរ ដល់សាលាបឋមសិក្សាកែប ។

៣-ថ្នាក់ទី៣: តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ១,០០០៛០០ ដីក្រៅពីថ្នាក់ទី១ និងថ្នាក់ទី ២ ខាងលើ ។

តំបន់ II : សង្កាត់អូរក្រសា ពងទឹកនិង អង្កោល

១- ថ្នាក់ទី១: តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ៥០០៛០០ ដោយគិតចម្ងាយ៥០០ម៉ែត្រសងខាងផ្លូវជាតិ និងផ្លូវគ្រួសក្រហមទៅស្ពានដែក។

២- ថ្នាក់ទី២: តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ៣០០៛០០ ដោយគិតចម្ងាយ៥០១មដល់១.០០០មសងខាងផ្លូវជាតិ និង ផ្លូវលំគ្រួសក្រហមទៅស្ពានដែក ។

៣-ថ្នាក់ទី៣: តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ២០០៛០០ ដីក្រៅពីថ្នាក់១ និងថ្នាក់ ២ ខាងលើ ។

តំបន់ II : តំបន់អភិវឌ្ឍន៍ភ្នំវល្លិ៍ :

-តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា ១០០៛០០ ។

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ ៦ ឆ្នាំ ២០០៥

ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

គាត ឈន់

រដ្ឋលេខាធិការទី ១ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

វិថីទី, ដូនពេញ, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣-៤២៦ ៧៤៩

Street 92, Rukhak Vithei Daun Penh, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia Tel/Fax: 855-23 426 749

ព្រះរាជាណាចក្រ កម្ពុជា

Kingdom Of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

Land Appraisal and Valuation Committee

ឧបសម្ព័ន្ធទី ១៩

ការកំណត់បែងចែកតំបន់ និង តម្លៃដីក្នុងមួយម៉ែត្រក្រឡា

សម្រាប់គិតពន្ធលើដីធ្លីមិនបានប្រើប្រាស់

ក្រុងប៉ៃលិន

ភ្ជាប់ជាមួយសេចក្តីសំរេចលេខ សសរ.សហវ.ពជ ចុះថ្ងៃទី ខែ ឆ្នាំ ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

I . ដីលំនៅដ្ឋាន

តំបន់ I តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ៥.០០០៛០០ ចំពោះដីទាំងឡាយណាដែលស្ថិតនៅទីប្រជុំជន និងចំងាយ៣០០ម ពីផ្លូវជាតិ ។

-ពីអូរតាប្រាង រហូតដល់ភូមិអូរច្រា ក្នុងខណ្ឌប៉ៃលិន

-ពីអូររអិល ទៅផ្សារព្រំដែន ក្នុងខណ្ឌ សាលាក្រៅ

តំបន់ II តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ៣.០០០៛០០ ចំពោះដីទាំងឡាយណាដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ១០ និង ថ្នល់លំ តាមខណ្ឌនីមួយៗចំងាយពីផ្លូវចំនួន ៣០០ម ។

- ពីព្រំប្រទល់ខេត្តបាត់ដំបង រហូតដល់អូរតាប្រាង
- ពីភូមិចំការកាហ្វេ រហូតដល់ អូររអិល
- ពីភូមិអូរច្រា ដល់បតាំងស៊ូ
- ពីភូមិសួនអំពៅ ដល់ភូមិតាង៉ែនលើ

តំបន់ III តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ១.០០០៛០០ ចំពោះដីទាំងឡាយណាចំងាយពីផ្លូវចំនួន ៣០០ម ។

- ចាប់ពីភូមិថេក្រោះឆេះ រហូតដល់ស្ទឹងភ្នំកុយ ក្នុងខណ្ឌសាលាក្រៅ

II . ដីស្រែចំការ

តំបន់ IV តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា = ២០០៛០០ ចំពោះដីទាំងឡាយណាដែលស្ថិតនៅក្រៅពីតំបន់ I តំបន់ II តំបន់ III ត្រូវចាត់ទុកជាប្រភេទដីតំបន់ IV

រាជធានីភ្នំពេញថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

[illegible] ទិមុល

រដ្ឋលេខាធិការទី ១ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

វិថីរុក្ខវិថី, ដូនពេញ, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣-៤២៦ ៧៤៩
Street. 92, Rukhak Vithei Daun Penh, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia Tel/Fax: 855-23 426 749

ព្រះរាជាណាចក្រ កម្ពុជា

Kingdom Of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

Land Appraisal and Valuation Committee

ឧបសម្ព័ន្ធទី ២០

ការកំណត់បែងចែកតំបន់ និង តម្លៃដីក្នុងមួយម៉ែត្រក្រឡា សម្រាប់គិតពន្ធលើដីធ្លីមិនបានប្រើប្រាស់ នៅខេត្តស្ទឹងត្រែង

ភ្ជាប់ជាមួយសេចក្តីសំរេចលេខ ០០៧សសរ.សហវ.ពដ ចុះថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

I . ដីលំនៅដ្ឋាន

តំបន់ I

- តំលៃគិតពន្ធអប្បបរមា ១.៥០០៛០០ ក្នុងមួយម៉ែត្រក្រឡា
- តំលៃគិតពន្ធអតិបរមា ២.៥០០៛០០ ក្នុងមួយម៉ែត្រក្រឡា

រួមមាន : ដីជុំវិញផ្សារទីរួមខេត្ត តាមបណ្តោយសងខាងផ្លូវពីព្រលានយន្តហោះមកទីរួមខេត្ត តាមបណ្តោយផ្លូវជាតិលេខ៧ ពីទីរួមខេត្តដល់បង្គោលគីឡូម៉ែត្រលេខ៤ ។

តំបន់ II

- តំលៃគិតពន្ធអប្បបរមា ១.០០០៛០០ ក្នុងមួយម៉ែត្រក្រឡា
- តំលៃគិតពន្ធអតិបរមា ១.៣០០៛០០ ក្នុងមួយម៉ែត្រក្រឡា

រួមមាន : ដីជាយក្រុងស្រុកស្ទឹងត្រែង តំបន់ទីប្រជុំស្រុកថាឡាបរិវ៉ាត់ ទីប្រជុំស្រុកសៀមបូក ទីប្រជុំស្រុកសេសាន ទីប្រជុំស្រុកសៀងប៉ាង ទីប្រជុំឃុំអូរពងមាន់ ។

តំបន់ III

- តំលៃគិតពន្ធអប្បបរមា ២០០៛០០ ក្នុងមួយម៉ែត្រក្រឡា
- តំលៃគិតពន្ធអតិបរមា ៥០០៛០០ ក្នុងមួយម៉ែត្រក្រឡា

រួមមាន : ដីដែលស្ថិតនៅក្រៅតំបន់ I+II ខាងលើគឺចាត់ទុកជាដីក្នុងតំបន់ III ។

I . ដីស្រែចំការ

តំបន់ I

- តំលៃគិតពន្ធអប្បបរមា ៥០០៛០០ ក្នុងមួយម៉ែត្រក្រឡា
- តំលៃគិតពន្ធអតិបរមា ១.០០០៛០០ ក្នុងមួយម៉ែត្រក្រឡា

រួមមាន : ដីតាមបណ្តោយសងខាងផ្លូវជាតិលេខ៧ ជំរៅ៥០០ម គិតចាប់ ពីបង្គោលគីឡូម៉ែត្រ លេខ៤ដល់ផ្លូវបំបែកអូរពងមាន់។ តាមបណ្តោយផ្លូវសងខាងជំរៅត្រឹម ៥០០ពីព្រលានយន្តហោះមកទីរួមស្រុកស្ទឹងត្រែង ។

តំបន់ II

- តំលៃគិតពន្ធអប្បបរមា ៣០០៖០០ ក្នុងមួយម៉ែត្រក្រឡា
- តំលៃគិតពន្ធអតិបរមា ៥០០៖០០ ក្នុងមួយម៉ែត្រក្រឡា

រួមមាន : ដីតាមបណ្តោយសងខាងផ្លូវជាតិលេខ៧ ជំរៅលើសពី៥០០ម គិតចាប់ពីបង្គោលគីឡូម៉ែត្រលេខ៤ដល់ផ្លូវបំបែកអូរពងមាន់ តាមបណ្តោយទន្លេមេគង្គជំរៅ៥០០ម របស់ស្រុកស្ទឹងត្រែង ស្រុកសៀមបូក និងស្រុកថាឡាបរិវ៉ាត។

តាមបណ្តោយទន្លេសេសាន និងទន្លេសេកុង ជំរៅ៥០០ម របស់ស្រុកសេសាន និងស្រុកសៀមប៉ាង ។

តំបន់ III

- តំលៃគិតពន្ធអប្បបរមា ១០០៖០០ ក្នុងមួយម៉ែត្រក្រឡា
- តំលៃគិតពន្ធអតិបរមា ២០០៖០០ ក្នុងមួយម៉ែត្រក្រឡា

គឺដីដែលស្ថិតនៅក្រៅតំបន់ I+II ខាងលើ គឺចាត់ទុកជាដីក្នុងតំបន់ III ។

រាជធានីភ្នំពេញថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៥

ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

គាត ឈន់

រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រ កម្ពុជា
Kingdom Of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
Land Appraisal and Valuation Committee

ឧបសម្ព័ន្ធទី ២១

ការកំណត់ចែងចែកតំបន់ និង តម្លៃដីក្នុងមួយម៉ែត្រក្រឡា សម្រាប់គិតពន្ធលើដីធ្លីមិនបានប្រើប្រាស់

ខេត្តរតនគិរី

ភ្ជាប់ជាមួយសេចក្តីសំរេចលេខ សសរ.សហវ.៣៨ ចុះថ្ងៃទី ខែ ឆ្នាំ ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

តំបន់ I : ដីស្ថិតនៅក្នុងទីប្រជុំជនរបស់ទីរួមខេត្តគិតពីបឹងកំសាន្ត ដល់វត្តថ្មីពីជើងភ្នំស្វាយដល់វិរ: ៧៩អមសងខាងផ្លូវ១៥០ម តំលៃគិតពន្ធអប្បរមា ២.៥០០រ០០-អតិបរមា ៥.០០០រ០០ ក្នុងមួយម៉ែត្រក្រឡា ។

តំបន់ 2 : ចុះពីផ្លូវ ១.៥០០ម តំលៃគិតពន្ធ អប្បបរមា ៦០០រ០០-អតិបរិមា ៨០០រ០០ ក្នុងមួយម៉ែត្រក្រឡា ជាប្រភេទដី ផលិតកម្មកសិកម្ម ។ លើសពី ១.៥០០ម ជាតំបន់៣ ប្រភេទដីកសិកម្ម តំលៃគិតពន្ធអប្បបរមា ៣០០រ០០-អតិបរមា ៥០០រ០០ ក្នុងមួយម៉ែត្រក្រឡា ។

⩽ ចំពោះស្រុកកូនមុំ-ស្រុកលំផាត់-ស្រុកវើនសៃ ក្នុងទីរួមស្រុកគឺស្ថិតនៅក្នុង តំបន់២របស់ខេត្ត ក្នុងទីប្រជុំជនរបស់ស្រុកបណ្តោយ ផ្លូវ១.០០០ម អមសងខាងផ្លូវ១០០ម ជាប្រភេទដីសាងសង់ តំលៃគិតពន្ធ អប្បរមា ៦០០រ០០-អតិបរមា ៨០០រ០០ ក្នុងមួយម៉ែត្រក្រឡា ។

-ចេញពីផ្លូវ ១៥០០ម ឡើងទៅជាតំបន់៣ របស់ស្រុក តំលៃគិតពន្ធ អប្បរមា ៣០០រ០០-អតិបរមា ៥០០រ០០ ក្នុងមួយម៉ែត្រក្រឡា ។

⩽ ស្រុកអូជុំ-តាវែង អណ្តូងមាស-បកែវ និងស្រុកអូរយ៉ាដាវ ទីប្រជុំជនស្រុក បណ្តោយផ្លូវ១៥០០ម និងសងខាង១០០ម តំលៃគិតពន្ធ អប្បរមា ៦០០រ០០-អតិបរមា ៨០០រ០០ ក្នុងមួយម៉ែត្រក្រឡា ។

ចេញពីផ្លូវ១៥០០ម ឡើងទៅជាតំបន់៣ របស់ស្រុក តំលៃគិតពន្ធ អប្បរមា ៣០០រ០០-អតិបរមា ៥០០រ០០ ក្នុងមួយម៉ែត្រក្រឡា ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ ៦ ឆ្នាំ ២០០៥

ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

គង់ ទិត្យ

រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

វិថីរុក្ខវិថី, ដូនពេញ, សង្កាត់វត្តភ្នំ, ខ័ណ្ឌដូនពេញ, រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣-៤២៦ ៧៤៩
Street. 92, Rukhak Vithei Daun Penh, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia Tel/Fax: 855-23 426 749

ព្រះរាជាណាចក្រ កម្ពុជា

Kingdom Of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

Land Appraisal and Valuation Committee

ឧបសម្ព័ន្ធទី ២២

ការកំណត់បែងចែកតំបន់ និង តម្លៃដីក្នុងមួយម៉ែត្រក្រឡា

សម្រាប់គិតពន្ធលើដីធ្លីមិនបានប្រើប្រាស់

ខេត្តមណ្ឌលគិរី

ភ្ជាប់ជាមួយសេចក្តីសំរេចលេខ០០៧ សសរ.សហវ.ពដ ចុះថ្ងៃទី២៩ ខែ ៦ ឆ្នាំ ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

I .ដីលំនៅឋាន

តំបន់ I : តំលៃគិតពន្ធ ២០០០រ០០ក្នុងមួយម៉ែត្រក្រលា រួមមាន :

-ដីទីរួមខេត្តពីផ្លូវជំរៅ ១០០ម

-ចាប់ពីទីរួមខេត្តតាមបណ្តោយផ្លូវរហូតដល់ព្រំប្រទល់ខេត្តក្រចេះ តាមបណ្តោយផ្លូវលេខ ៧៦ សងខាងផ្លូវជំរៅ១០០ម

- ចាប់ពីទីរួមខេត្តតាមបណ្តោយផ្លូវសាមលិញ (SL) ទល់និងផ្លូវជាតិ លេខ ៧៦ សងខាងផ្លូវជំរៅ១០០ម

-ចាប់ពីទីរួមខេត្តតាមបណ្តោយផ្លូវជាតិ៣៨៣ រហូតដល់ព្រំប្រទល់វៀតណាមច្រកប៊ូប្រាំង សងខាងផ្លូវជំរៅ១០០ម(ស្រុកអូររាំង)

-ចាប់ពីទីរួមខេត្តតាមបណ្តោយផ្លូវជាតិ ៣៨៤ រហូតដល់ព្រំប្រទល់ វៀតណាមច្រកដាក់ប៉ែរ សងខាងផ្លូវជំរៅ ១០០ម (ស្រុកពេជ្រាដា) ។

- ចាប់ពីទីរួមខេត្តតាមបណ្តោយផ្លូវជាតិ ៧៦ រហូតដល់ព្រំប្រទល់ខេត្ត រតនៈគិរី សងខាងផ្លូវលេខ ៧៦ ជំរៅ ១០០ម (ស្រុកកោះញែក) ។

តំបន់ 2 : តំលៃគិតពន្ធ ១០០០រ០០ក្នុងមួយម៉ែត្រក្រលា ក្នុងមួយឆ្នាំ រួមមាន :

-ដីក្រៅពីតំបន់១ ខាងលើចាត់ទុកជាតំបន់ ២។

II .ដីស្រែចំការ

តំបន់ I : តំលៃគិតពន្ធ ១០០០រ០០ក្នុងមួយម៉ែត្រក្រលា ក្នុងមួយឆ្នាំ រួមមាន :

-ដីទីរួមខេត្ត ជំរៅចាប់ពី ១០០ម ដល់ ៥០០ម

-ដីទីរួមស្រុក ជំរៅចាប់ពី ១០០ម ដល់ ៥០០ម

-ចាប់ពីទីរួមខេត្តដល់ព្រំប្រទល់ខេត្តក្រចេះ តាមបណ្តោយផ្លូវលេខ ៧៦ ចាប់ពីជំរៅ ១០០ម ដល់៥០០ម ។

-ចាប់ពីទីរួមខេត្តតាមបណ្តោយផ្លូវសាមលិញ (SL) ទល់និងផ្លូវជាតិ លេខ ៧៦ សងខាងផ្លូវជំរៅ១០០ម ដល់៥០០ម ។

-ចាប់ពីទីរួមខេត្តតាមបណ្តោយផ្លូវជាតិ ៣៨៣ រហូតដល់ព្រំប្រទល់ វៀតណាមច្រកប៊ូប្រាំង សងខាងផ្លូវជំរៅ ១០០ម ដល់ ៥០០ម(ស្រុកអូររាំង) ។

-ចាប់ពីទីរួមខេត្តតាមបណ្តោយផ្លូវជាតិ ៣៨៤ រហូតដល់ព្រំប្រទល់ វៀតណាមច្រកដាក់ប៉ែរ សងខាងផ្លូវជំរៅ ១០០ម ដល់៥០០ម(ស្រុកពេជ្រាដា) ។

-ចាប់ពីទីរួមខេត្តតាមបណ្តោយផ្លូវជាតិ ៧៦ រហូតដល់ព្រំប្រទល់ខេត្ត រតនៈគិរី ចាប់ពីជំរៅ ១០០ម ដល់ ៥០០ម (ស្រុកកោះញែក) ។

តំបន់ 2 : តំលៃគិតពន្ធ ៥០០.៩០០ក្នុងមួយម៉ែត្រក្រលា ក្នុងមួយឆ្នាំ រួមមាន :

-ដីក្រៅពីតំបន់១ ខាងលើចាត់ទុកជាតំបន់ ២។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ ២០០៥

ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

គាត ឆ័ន

រដ្ឋលេខាធិការ [illegible] ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រ កម្ពុជា

Kingdom Of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

Land Appraisal and Valuation Committee

ឧបសម្ព័ន្ធទី ២៣

ការកំណត់បែងចែកតំបន់ និង តម្លៃដីក្នុងមួយម៉ែត្រក្រឡា

សម្រាប់គិតពន្ធលើដីធ្លីមិនបានប្រើប្រាស់

ខេត្តព្រះវិហារ

ភ្ជាប់ជាមួយសេចក្តីសំរេចលេខ ០០៧ សសរ.សហវ.ពដ ចុះថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

I . <u>ដីលំនៅដ្ឋាន</u>

តំបន់ I តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា :

អប្បបរមា ២,៥០០/មួយម៉ែត្រក្រឡា

-អតិបរមា ២០,០០០/មួយម៉ែត្រក្រឡា

ដីក្នុងទីប្រជុំជនខេត្ត ចាប់ពីមាត់ស្ទឹងខាងត្បូង ទៅដល់ព្រលានយន្តហោះធំ - ដីនៅតំបន់ភូមិខ្សុងហោង ។

តំបន់ II តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា :

-អប្បបរមា ១,០០០/មួយម៉ែត្រក្រឡា

-អតិបរមា ៣,០០០/មួយម៉ែត្រក្រឡា

ដីស្ថិតក្នុងទីប្រជុំជនបណ្តាស្រុក ។

តំបន់ III តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា :

-អប្បបរមា ៥០០/មួយម៉ែត្រក្រឡា

-អតិបរមា ៨០០/មួយម៉ែត្រក្រឡា

ដីនៅក្រៅពីតំបន់១ និងតំបន់ ២ ខាងលើ ។

II . <u>ដីស្រែចំការ</u>

តំបន់ I តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា :

- ដីស្រែ : -អប្បបរមា ១០០/មួយម៉ែត្រក្រឡា

-អតិបរមា ១៥០/មួយម៉ែត្រក្រឡា

- ដីចំការ : -អប្បបរមា ២០០/មួយម៉ែត្រក្រឡា

-អតិបរមា ៣០០/មួយម៉ែត្រក្រឡា

ដីស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៦៤ ។

រុក្ខវិថី, ដូនពេញ, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣-៤២៦ ៧៤៩
Street. 92, Rukhak Vithei Daun Penh, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia Tel/Fax: 855-23 426 749

តំបន់ II តំលៃគិតពន្ធក្នុងមួយម៉ែត្រក្រឡា :

- ដីស្រែ : -អប្បបរមា ៥០/មួយម៉ែត្រក្រឡា
  -អតិបរមា ៨០/មួយម៉ែត្រក្រឡា
- ដីចំការ : -អប្បបរមា ១០០/មួយម៉ែត្រក្រឡា
  -អតិបរមា ១៥០/មួយម៉ែត្រក្រឡា

ដីនៅក្រៅតំបន់១ ខាងលើ ។

រាជធានីភ្នំពេញថ្ងៃទី២៨ខែ៧ ឆ្នាំ ២០០៥

ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

ហ៊ាង ម៉ីភូល

រដ្ឋលេខាធិការទី ១ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៚៙៛

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
លេខ ៦៧៨ ស.អ.យ.

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៥

ប្រកាស
ស្ដីពី
នីតិវិធីអនុវត្តរបបឧបត្ថម្ភគោលនយោបាយ ចំពោះជនពលី ជនមរណៈ ជនពិការ និងអ្នកជន ជនបាត់បង់ សមត្ថភាពការងារ និងគ្រួសារ

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ ០៧/នស/៩៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការរៀបចំនិងប្រព្រឹត្តទៅ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញសេចក្ដីសំរេចលេខ ២០ សសរ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្ដីពីរបបគោលនយោបាយចំពោះជនពលី ពិការ និងលិខិតលេខ ៥១៥ សជណ អវ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩១ របស់រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី./.

- បានឃើញអនុក្រឹត្យលេខ ១០ អនក្រ បក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៩៦ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ និងអនុក្រឹត្យលេខ៣២ អនក្រ បក ចុះថ្ងៃទី០៦ ខែមិនា ឆ្នាំ២០០០ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីវិសោធនកម្មមាត្រា ៤ ១៤
- និង ១៥ នៃអនុក្រឹត្យលេខ ១០ អនក្រ បក ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ៤៦ អនក្រ បក ចុះថ្ងៃទី១៨ ខែ វិច្ឆិកា ឆ្នាំ១៩៩៦ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្គូស្លាប់ បាត់ខ្លួន និងពិការ និងអនុក្រឹត្យលេខ០២ អនក្រ បក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៥ ស្តីពីការកែតម្រូវឡើងវិញ មាត្រា ៣ មាត្រា ៦ និងមាត្រា ៧ នៃអនុក្រឹត្យលេខ៤៦ អនក្រ បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៦ របស់រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសារាចរអន្តរក្រសួងលេខ ០៤ សកអ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៤ របស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ក្រសួងសុខាភិបាល ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ស្តីពីរបៀបបំពេញសំណុំលិខិត និងសំរេចទទួលស្គាល់ជនពលីពិការ
- បានឃើញសារាចរអន្តរក្រសួងលេខ០០២/៩៧ សរចអ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៧ របស់ក្រសួងការពារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ស្តីពីការណែនាំអនុវត្តន៍ របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ និងសារាចរអន្តរក្រសួង លេខ ០១/២០០១ សរចអ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០០១ របស់ក្រសួងការពារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន ស្តីពីវិសោធនកម្មលើចំណុច ៤ ក្នុង (I) ចំណុច (III) និងចំណុចលេខ ៥ ក្នុង-(IV) នៃសារាចរអន្តរក្រសួង លេខ០០២/៩៧ សរចអ ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ១៩៩៧ ស្តីពីការណែនាំអនុវត្តន៍ របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញសារាចរណែនាំអន្តរក្រសួងលេខ ០២ សរណ អក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៥ របស់ក្រសួងការពារជាតិ ក្រសួងសេដកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការអនុវត្តន៍ អនុក្រឹត្យលេខ ៤៦ អនក្រ បក ចុះថ្ងៃទី១៨ ខែវិច្ឆិកាឆ្នាំ ១៩៩៦ ស្តីពីរបបឧបត្ថម្ភចំពោះយោធិន ពលី មរណៈ បង្គូស្លាប់ បាត់ខ្លួន និងពិការ និងអនុក្រឹត្យលេខ ០២ អនក្រ បក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៥ ស្តីពីការកែតម្រូវឡើងវិញ មាត្រា៣ មាត្រា៦ និងមាត្រា៧ នៃអនុក្រឹត្យលេខ៤៦ អនក្រ បក។

សំរេច

ជំពូកទី ១

បទបញ្ញត្តិទូទៅ

ប្រការ១: ប្រកាសនេះមានគោលបំណង កំណត់នូវបែបបទនិងនីតិវិធី នៃការអនុវត្តរបបឧបត្ថម្ភគោលនយោបាយ ចំពោះគ្រួសារ

ជនពលី-ជនមរណៈ ជនពិការ និងគ្រួសារ ជាអតីតយោធិននៃកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ មន្ត្រីរាជការស៊ីវិល កងសេនាជននិងប្រជាជន ដែលបានបូជាជីវិតដើម្បីប្រទេសជាតិ និងចំពោះនិវត្តជន ជនបាត់បង់សមត្ថភាពការងារ ជាអតីតយោធិន នៃកងយោធពលខេមរភូមិន្ទ។

ប្រការ២: ប្រកាសនេះកំណត់ នីតិវិធីអនុវត្តជាក់ស្តែង នូវច្បាប់ អនុក្រឹត្យ សារាចរ សេចក្តីណែនាំ សេចក្តីជូនដំណឹង ស្តីពីគោលរបបឧបត្ថម្ភចំពោះគ្រួសារជនពលី-ជនមរណៈ ជនពិការនិងគ្រួសារ និងបានរៀបចំបញ្ចូលបន្ថែម នូវគោលការណ៍ បែបបទ និងនីតិវិធី នៃការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ។

ជំពូកទី ២

ប្រាក់ឧបត្ថម្ភប្រចាំខែរបស់គ្រួសារជនពលី-ជនមរណៈ

ប្រការ៣: គ្រួសារជនពលី ត្រូវបានទទួលប្រាក់ឧបត្ថម្ភ តាមកំណត់ដូចតទៅ:

ក-កូនបង្កើតក្នុងម្នាក់១ ៤.០០០ រៀល

ខ-ប្រពន្ធ ឬប្តីស្របច្បាប់ ៣.២០០ រៀល

គ-ឪពុកបង្កើត ៣.២០០ រៀល

ឃ-ម្តាយបង្កើត ៣.២០០ រៀល

ប្រការ៤: កូនជនមរណៈ ត្រូវបានទទួលប្រាក់ឧបត្ថម្ភ ក្នុងម្នាក់១ ៤.០០០រៀល។

ជំពូកទី ៣

ប្រាក់ជូនដំណឹងពលី មរណៈ និងប្រាក់ឧបត្ថម្ភមួយលើកជូនគ្រួសារ

ប្រការ៥: គ្រួសារសពនគរបាល មន្ត្រីរាជការស៊ីវិល ពលី ឧបត្ថម្ភជាប្រាក់ចំនួន១៥ខែ នៃប្រាក់បៀវត្សសរុបប្រចាំខែ (ប្រាក់ជូនដំណឹងពលីចំនួន ៣ខែ និងប្រាក់ឧបត្ថម្ភមួយលើកចំនួន១២ ខែ) ដោយផ្អែកតាម លិខិតបញ្ជាក់ប្រាក់បៀវត្ស ឬប្រាក់ឧបត្ថម្ភផ្សេងៗ របស់ក្រសួងស្ថាប័នដើម ។

ប្រការ៦: គ្រួសារសព កងសេនាជន និងប្រជាជន ពលី ឧបត្ថម្ភជាប្រាក់ចំនួន ១៥ខែ នៃប្រាក់បៀវត្សឋានន្តរសក្តិសរុបផ្ទាល់ខ្លួន របស់យុទ្ធជនពលទោ (ប្រាក់ជូនដំណឹងពលី ចំនួន៣ខែ និង ប្រាក់ឧបត្ថម្ភមួយលើកចំនួន ១២ខែ)។

ប្រាក់បៀវត្សសរុបផ្ទាល់ខ្លួន របស់យុទ្ធជនមានឋានន្តរសក្តិពលទោ សំរាប់ឧបត្ថម្ភជនពលី ឬជនមរណៈ ជាកងសេនាជន និងប្រជាជន ឬជូនគ្រួសារ រួមមាន: ប្រាក់បៀវត្សឋានន្តរសក្តិ ប្រាក់ម្ហូប ប្រាក់តំបន់ (បើមាន) និងប្រាក់បន្ថែមភាគរយ។

ជំពូកទី ៤

ប្រាក់ឧបត្ថម្ភប្រចាំខែ ចំពោះជនពិការ និងគ្រួសារ

ឃ្លាការពេះអត្ថន័យអក្សរប្រើប្រាស់ក្នុងរូបមន្ត ដើម្បីគិតប្រាក់ឧបត្ថម្ភជូនជនពិការ មានដូចតទៅ:

-បស =ប្រាក់បៀវត្សសរុបចុងក្រោយរបស់យោធិន ឬ នគរបាលពិការ (ក្របខ័ណ្ឌរដ្ឋក្នុងកងកម្លាំងប្រដាប់អាវុធ) រួមមាន:

-ប្រាក់បៀវត្សឋានន្តរសក្តិ

-ប្រាក់ម្ហូប

-ប្រាក់តំបន់ (បើមាន)

-ប្រាក់ប្រពន្ធ ឬ ប្តី (ប្រ)

-ប្រាក់កូន (ក)

-ចំពោះប្រាក់បៀវត្សសរុបចុងក្រោយ (បស) របស់ជនពិការ ជាក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល រួមមាន:

-ប្រាក់បៀវត្សមូលដ្ឋាន ឬប្រាក់បៀវត្សសុទ្ធសាធ

-ប្រាក់តំបន់ (បើមាន)

-ប្រាក់កូន (ក)

-ប្រាក់ប្រពន្ធឬ ប្តី (ប្រ)

-និងប្រាក់ឧបត្ថម្ភផ្សេងៗ (បើមាន)

-បផ =ប្រាក់បៀវត្សឋានន្តរសក្តិសរុបផ្ទាល់ខ្លួនចុងក្រោយ រួមមាន:

-ប្រាក់បៀវត្សឋានន្តរសក្តិ

-ប្រាក់ម្ហូប

-ប្រាក់តំបន់ (បើមាន)

-ប%=ប្រាក់បន្ថែមភាគរយ គិតលើប្រាក់បៀវត្សមូលដ្ឋាន ឬលើប្រាក់បៀវត្សសុទ្ធសាធ ឬលើប្រាក់បៀវត្សឋានន្តរសក្តិសុទ្ធសាធ ។ ប្រាក់នេះត្រូវបានឧបត្ថម្ភ ដោយផ្អែកតាមការកំណត់ របស់រាជរដ្ឋាភិបាល ហើយមានការណែនាំដោយឡែក ។

-កំ=កំរិតភាគរយ នៃប្រាក់ឧបត្ថម្ភជនពិការតាមកំរិតថ្នាក់ពិការ ដែលមានកំណត់ដូចតទៅ:

ចំពោះ កំ ប្រភេទ (ក) គិតលើប្រាក់បៀវត្សសរុបប្រចាំខែចុងក្រោយ សំរាប់ជនពិការ ជាក្របខ័ណ្ឌមន្ត្រីរាជការនិងលើប្រាក់បៀវត្សឋានន្តរសក្តិសរុបផ្ទាល់ខ្លួន របស់យុទ្ធជនពលទោ សំរាប់ជនពិការក្រៅក្របខ័ណ្ឌមន្ត្រីរាជការ មានកំណត់ដូចតទៅ:

-ថ្នាក់ ទី ១ កំ = ១០០

-ថ្នាក់ ទី ២ កំ = ៨០

-ថ្នាក់ ទី ៣ កំ = ៦០

-ថ្នាក់ ទី ៤ កំ = ៤០

ចំពោះ កំ ប្រភេទ (ខ) គិតលើប្រាក់បៀវត្សឋានន្តរសក្តិសរុបផ្ទាល់ខ្លួនចុងក្រោយ សំរាប់ជនពិការជាអតីតយោធិននៃកងយោធពលខេមរភូមិន្ទ មានកំណត់ដូចតទៅ:

- ថ្នាក់ទី១ កំ =៩០
- ថ្នាក់ទី២ កំ =៨០
- ថ្នាក់ទី៣ កំ = ៧០

-ជំ=ប្រាក់ជំនួយមុខរបួស

-បំ១=ប្រាក់ឧបត្ថម្ភអ្នកបំរើជនពិការប្រភេទ (ក) ថ្នាក់ទី ១ ។

-សបឧ =សរុបប្រាក់ឧបត្ថម្ភប្រចាំខែ

ប្រការ៨:របៀបគណនាប្រាក់ឧបត្ថម្ភ ជនពិការប្រភេទ (ក) ជាក្របខ័ណ្ឌមន្ត្រីរាជការ មានដូចតទៅ :

ក-ការគិតប្រាក់ជំនួយមុខរបួស(ជំ) ត្រូវយកប្រាក់បៀវត្សសរុបចុងក្រោយ (បស) គុណនឹងកំរិតភាគរយ នៃប្រាក់ឧបត្ថម្ភជនពិការតាមកំរិតថ្នាក់ពិការ (កំ) ចែកនឹង១០០ មានរូបមន្តដូចតទៅ:

ជំ = បស x កំ / ១០០

ខ-ការសរុបប្រាក់ឧបត្ថម្ភប្រចាំខែ (សបឧ) ត្រូវយកប្រាក់បៀវត្សសរុបចុងក្រោយ (បស) បូកជាមួយប្រាក់បន្ថែមភាគរយ (ប%) បូកជាមួយប្រាក់ជំនួយមុខរបួស (ជំ) និងបើជនពិការថ្នាក់ទី១ ត្រូវបូកជាមួយប្រាក់ឧបត្ថម្ភអ្នកបំរើ (បំ១) ដែលមានរូបមន្តដូចតទៅ:

ជនពិការថ្នាក់ទី ១ = សបឧ = បស + ប% + ជំ + បំ១

ជនពិការថ្នាក់ទី ២ ៣ ៤ = សបឧ = បស + ប% + ជំ

ប្រការ៩:របៀបគណនាប្រាក់ឧបត្ថម្ភ ជនពិការប្រភេទ (ខ) គ្រប់ថ្នាក់ ជាអតីតយោធិនមានដូចតទៅ:

ក-ការគិតប្រាក់ជំនួយមុខរបួស (ជំ) ត្រូវយកប្រាក់បៀវត្សឋានន្តរសក្តិសរុបផ្ទាល់ខ្លួនចុងក្រោយ (បផ) គុណនឹងកំរិតភាគរយនៃប្រាក់ឧបត្ថម្ភជនពិការ តាមកំរិតថ្នាក់ពិការ (កំ) ចែកនឹង ១០០ មានរូបមន្តដូចតទៅ : ជំ = បផ x កំ / ១០០

ខ-ការសរុបប្រាក់ឧបត្ថម្ភប្រចាំខែ (សបឧ) ត្រូវយកប្រាក់បន្ថែមភាគរយ (ប%) បូកជាមួយប្រាក់ជំនួយមុខរបួស (ជំ) បូកជាមួយប្រាក់កូន(ក)និងបូកជាមួយប្រាក់ប្រពន្ធឬប្តី (ប្រ) មានរូបមន្ត ដូចតទៅ: សបឧ = ជំ + ប% + ក + ប្រ

ប្រការ១០:ជនពិការប្រភេទ (ខ)ជាអតីតយោធិន ត្រូវបានកែសំរួលប្រាក់ឧបត្ថម្ភ តាមការកំណត់របស់ប្រកាសនេះ ។

មូលដ្ឋានប្រាក់បៀវត្សឋានន្តរសក្តិ និងប្រាក់ឧបត្ថម្ភផ្សេងៗ ដើម្បីគិតប្រាក់ឧបត្ថម្ភ ត្រូវអនុវត្តតាម សេចក្តីណែនាំលេខ ០៤/៩២ សណន ចុះថ្ងៃទី១៣ខែកក្កដាឆ្នាំ១៩៩២ របស់ក្រសួងការពារប្រទេស ស្តីពីការអនុវត្តនៃ អនុក្រឹត្យលេខ២៣ អនក្រ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការសំរួលបៀវត្ស របស់កងទ័ពប្រជាជនកម្ពុជា ។

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ត្រូវលើកជាសំណើកែសម្រួល សុំសេចក្តីសំរេចពី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

ប្រការ១១:ជនពិការប្រភេទ (ខ) ជាកងកម្លាំងនគរបាលជាតិ ដែលក្រសួងមហាផ្ទៃ បានបញ្ចេញពីក្របខ័ណ្ឌ នគរបាលជាតិផ្ទេរជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ហើយត្រូវបានក្រុមប្រឹក្សាវាយតម្លៃ ប្រភេទថ្នាក់ពិការ

ធ្វើការវាយតម្លៃ មានកំរិតបាត់បង់សមត្ថភាពការងារ លើសពី ២០ភាគរយ ទៅដល់ ១០០ ភាគរយ ត្រូវបានគិតប្រាក់ឧបត្ថម្ភជូនជារៀងរាល់ខែ ស្មើនឹង៦៥ភាគរយ នៃប្រាក់បៀវត្សឋានន្តរសក្តិសរុបផ្ទាល់ខ្លួន។ ចំពោះ កូនប្រពន្ធឬប្តី ត្រូវបានទទួលប្រាក់ឧបត្ថម្ភ ដូចពេលកំពុងធ្វើការរដ្ឋដែរ មានរូបមន្ត អនុវត្តដូចតទៅ:

$$\text{សបឧ} = \left(\frac{\text{បផ} \times ៦៥}{១០០}\right) + \text{ប\%} + \text{ក} + \text{ប្រ}$$

ប្រការ១២: ការគិតប្រាក់ឧបត្ថម្ភជនពិការប្រភេទ(ក) គ្រប់ថ្នាក់ក្រៅក្របខ័ណ្ឌមន្ត្រីរាជការ (កងសេនាជនប្រជាជន) មានដូចតទៅ :

ក-ការគិតប្រាក់ជំនួយមុខរបួស(ជំ) ត្រូវយកប្រាក់បៀវត្សសរុបផ្ទាល់ខ្លួន របស់យុទ្ធជនមានឋានន្តរសក្តិពលទោ(បផ) គុណនឹងកំរិតភាគរយនៃប្រាក់ឧបត្ថម្ភជនពិការ តាមកំរិតថ្នាក់ពិការ(កំ) ចែកនឹង១០០មានរូបមន្ត : $\text{ជំ} = \frac{\text{បផ} \times \text{កំ}}{១០០}$

ខ-ការសរុបប្រាក់ឧបត្ថម្ភប្រចាំខែ(សបឧ) ត្រូវយកប្រាក់បន្ថែមភាគរយ(ប%) បូកជាមួយប្រាក់ជំនួយមុខរបួស(ជំ) បូកជាមួយប្រាក់កូន (ក) បូកជាមួយប្រាក់ប្រពន្ធឬប្តី (ប្រ) និងចំពោះជនពិការថ្នាក់ទី១ ត្រូវបានបន្ថែមប្រាក់អ្នកបំរើម្នាក់ (បំ) មានរូបមន្តដូចតទៅ:

ជនពិការថ្នាក់ទី១ = ជំ + ប% + បំ១ + ក + ប្រ

ជនពិការថ្នាក់ទី ២ ៣ ៤ = ជំ + ប% + ក + ប្រ

ជំពូកទី ៥

ប្រាក់សោធននិវត្តន៍និងសោធននិវត្តន៍បាត់បង់សមត្ថភាពការងារប្រចាំខែនិងគ្រួសារ

ប្រការ១៣: អត្ថន័យនៃអក្សរប្រើប្រាស់ កំណត់ប្រាក់សោធននិវត្តន៍មានដូចតទៅ:

-សន៥០ =ប្រាក់សោធននិវត្តន៍អប្បបរមាប្រចាំខែផ្ទាល់ខ្លួន៥០ភាគរយ នៃប្រាក់បៀវត្សឋានន្តរសក្តិប្រចាំខែ

-សន៥០ប្រ =ប្រាក់សោធននិវត្តន៍អប្បបរមា ៥០ ភាគរយសរុបប្រចាំខែ

-សន៨០ =ប្រាក់សោធននិវត្តន៍អតិបរមាប្រចាំខែផ្ទាល់ខ្លួន៨០ភាគរយ នៃប្រាក់បៀវត្សឋានន្តរសក្តិប្រចាំខែ

-សន៨០ប្រ = ប្រាក់សោធននិវត្តន៍អតិបរមា ៨០ ភាគរយសរុបប្រចាំខែ

$-\frac{២(៤^{\text{ឆ}-៣}+៦^{\text{ឆ}-៥})}{១០០}$ =រូបមន្តនៃអត្រាប្រាក់បន្ថែម ២ភាគរយ នៃប្រាក់បៀវត្សឋានន្តរសក្តិសុទ្ធសាធ ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំទី៤ និងឆ្នាំទី៦ នៃរយៈពេលបំរើការងារយោធា និងស៊ីវិល ដែល (ឆ)ជាចំនួនឆ្នាំបំរើការងារ ហើយលេខ(៣) និងលេខ(៥) ជាចំនួនដក

-បអន= ប្រាក់បៀវត្សឋានន្តរសក្តិអប្បបរមា របស់នាយទាហានប្រចាំខែ (នាយចំណង់) រួមមាន:

-ប្រាក់បៀវត្សឋានន្តរសក្តិ (ប)

-ប្រាក់ម្ហូប និងអង្ករ (ហ)

-ប្រាក់បន្ថែមភាគរយ (ប%) គិតលើប្រាក់បៀវត្សឋានន្តរសក្តិសុទ្ធសាធ

-ប្រាក់បំណាច់មុខងារ (ម) (បើមាន)

-បអនប្រ=ប្រាក់សោធននិវត្តន៍ អប្បបរិមាប្រចាំខែរបស់នាយទាហាន

-តំ = ប្រាក់តំបន់ (បើមាន)

-អភ១៥ឬ២០=ប្រាក់អាទិភាព១៥ឬ២០ភាគរយ នៃប្រាក់បៀវត្សឋានន្តរសក្តិសុទ្ធសាធ សំរាប់យោធិនបំរើការងារមុនឆ្នាំ ១៩៧៩ ឬមុនឆ្នាំ ១៩៧០

-សភ១៥=ប្រាក់បំណាច់ប៉ះពាល់សុខភាព ត្រូវបានអត្រាបន្ថែម១៥ភាគរយ នៃប្រាក់បៀវត្សឋានន្តរសក្តិសុទ្ធសាធ

-ប្រ = ប្រាក់ប្រពន្ធ ឬ ប្តី

-ក = ប្រាក់កូន

-(បរ+កព)=ប្រាក់អ្នកបើកបរនិងកងការពារ សំរាប់និវត្តជន ឬជនបាត់បង់សមត្ថភាពការងារ មានឋានន្តរសក្តិជាឧត្តមសេនីយ ឬវីរជន

-បផ=ប្រាក់បៀវត្សឋានន្តរសក្តិផ្ទាល់ខ្លួន រួមមាន :

- ប្រាក់បៀវត្សឋានន្តរសក្តិ (ប)
- ប្រាក់បន្ថែមភាគរយ (ប%)
- ប្រាក់ម្ហូប និងអង្ករ (ហ)
- ប្រាក់បំណាច់មុខងារ (ម) (បើមាន)

ប្រការ១៤:របៀបគណនា ប្រាក់សោធននិវត្តន៍អប្បបរមា ៥០ភាគរយ (សន៥០) មានដូចតទៅ:

១-រូបមន្តប្រាក់សោធននិវត្តន៍ អប្បបរមាប្រចាំខែផ្ទាល់ខ្លួន ៥០ភាគរយ (សន៥០) មានរូបមន្តដូចខាងក្រោម:

$$\text{សន៥០} = \left[\frac{(\text{បផ} \times ៥០)}{១០០} + \frac{២\,(៤^{\text{ន}-៣} + ៦^{\text{ន}-៥})}{១០០} \right]$$

-ប្រាក់សោធននិវត្តន៍អប្បបរមាផ្ទាល់ខ្លួន ប្រចាំខែ៥០ភាគរយ(សន៥០) មិនត្រូវលើសពី៨០ភាគរយ នៃប្រាក់សោធននិវត្តន៍អតិបរមា ឬក៏មិនត្រូវទាបជាង ប្រាក់បៀវត្សឋានន្តរសក្តិអប្បបរមា របស់នាយទាហាន (នាយចំណង់) ករណីទាបជាងត្រូវដំឡើងអោយស្មើ (បអន) ។

២- រូបមន្តប្រាក់សោធននិវត្តន៍អប្បបរមា ៥០ភាគរយសរុបប្រចាំខែ(សន៥០ប្រ) មានដូចតទៅ:

$$\text{សន៥០ប្រ} = \text{សន៥០} + \text{តំ} + \text{អភ១៥ឬ២០} + \text{សភ១៥} + \text{ប្រ} + \text{ក}$$

ករណីប្រាក់សោធននិវត្តន៍អប្បបរមាផ្ទាល់ខ្លួន ប្រចាំខែ៥០ភាគរយ(សន៥០) មានកំរិតទាប ហើយត្រូវបានគេដំឡើងឱ្យស្មើប្រាក់បៀវត្សឋានន្តរសក្តិអប្បបរមា របស់នាយទាហាន (បអន) ប្រាក់សោធននិវត្តន៍អប្បបរមា ៥០ភាគរយសរុបប្រចាំខែ (សន៥០ប្រ) ត្រូវអនុវត្តតាមរូបមន្តដូច្នេះវិញ:

$$\text{បអនប្រ} = \text{បអន} + \text{តំ} + \text{អភ១៥ឬ២០} + \text{សភ១៥} + \text{ប្រ} + \text{ក}$$

ប្រការ១៥:របៀបគណនា ប្រាក់សោធននិវត្តន៍អតិបរមា៨០ភាគរយ (សន៨០) មានដូចតទៅ:

១-រូបមន្តប្រាក់សោធននិវត្តន៍ អតិបរមាផ្ទាល់ខ្លួនប្រចាំខែ៨០ភាគរយ នៃបៀវត្សឋានន្តរសក្តិប្រចាំខែ មានដូចតទៅ:

$$\text{សន៨០} = \frac{\text{បផ} \times ៨០}{១០០}$$

ប្រាក់សោធននិវត្តន៍អតិបរមា៨០ ភាគរយផ្ទាល់ខ្លួនប្រចាំខែ (សន៨០) មិនត្រូវទាបជាងប្រាក់បៀវត្សឋានន្តរសក្តិអប្បបរមារបស់នាយទាហានឡើយ បើមានករណីទាបជាងត្រូវដំឡើងអោយស្មើ (បអន)។

២-រូបមន្តប្រាក់សោធននិវត្តន៍អតិបរមាសរុបប្រចាំខែ ៨០ ភាគរយ (សន៨០ប្រ) មានដូចតទៅ:

សន៨០ប្រ = សន៨០ + គឺ+ អភ១៥ឬ២០ + សភ១៥ + ប្រ + ក

ករណីប្រាក់សោធននិវត្តន៍អតិបរមា៨០ ភាគរយផ្ទាល់ខ្លួនប្រចាំខែ (សន៨០) មានកំរិតទាប ហើយត្រូវបានគេដំឡើងឱ្យស្មើប្រាក់បៀវត្សឋានន្តរសក្តិអប្បបរមា របស់នាយទាហាន (បអន) ប្រាក់សោធននិវត្តន៍អតិបរមា ៨០ភាគរយ សរុបប្រចាំខែ (សន៨០ប្រ) ត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម:

បអនប្រ = បអន+ គឺ + អភ១៥ឬ២០ + សភ១៥ + ប្រ + ក

ប្រការ១៦: ប្រាក់សោធននិវត្តន៍អប្បបរមា៥០ភាគរយ (សន៥០) និងប្រាក់សោធននិវត្តន៍អតិបរមា ៨០ភាគរយ (សន៨០) របស់និវត្តជន ដែលមានឋានន្តរសក្តិ ជាឧត្តមសេនីយ ឬជាវីរជន ត្រូវបានបន្ថែមប្រាក់ អ្នកបើកបរនិងកងការពារ ផ្អែកតាមសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល មានរូបមន្តបន្ថែម (+បរ +កព) ។

ប្រការ១៧: អត្ថន័យនៃអក្សរប្រើប្រាស់ កំណត់ប្រាក់សោធនបាត់បង់សមត្ថភាពការងារ មានដូចតទៅ:

-សប៥០=ប្រាក់សោធនបាត់បង់សមត្ថភាពការងារអប្បបរមាប្រចាំខែផ្ទាល់ខ្លួនស្មើនឹង៥០ភាគរយនៃប្រាក់បៀវត្សឋានន្តរសក្តិប្រចាំខែចុងក្រោយ ។

-សប៥០ប្រ = ប្រាក់សោធនបាត់បង់សមត្ថភាពការងារអប្បបរមា សរុបប្រចាំខែស្មើនឹង៥០ភាគរយ

-សបចំប្រ = ប្រាក់សោធនបាត់បង់សមត្ថភាពការងារ ចំណាត់ថ្នាក់សរុបប្រចាំខែ

-$១.៥\left(\frac{៤^{ឆ-៣} + ៦^{ឆ-៥}}{១០០}\right)$ = រូបមន្តអត្រាប្រាក់បន្ថែម១.៥ ភាគរយ គិតលើប្រាក់បៀវត្សឋានន្តរសក្តិសុទ្ធសាធក្នុង ១ឆ្នាំ ចាប់ពីឆ្នាំទី៤ និងឆ្នាំទី ៦ នៃរយៈពេលបំរើការងារក្នុងយោធានិងស៊ីវិល ដែល (ឆ) ជាចំនួនឆ្នាំបំរើការហើយលេខ(៣) និងលេខ(៥) ជាចំនួនដក។

-អវី១០=ប្រាក់អត្រាបន្ថែម ១០ភាគរយ គិតលើប្រាក់បៀវត្សឋានន្តរសក្តិសុទ្ធសាធ សំរាប់ជនបាត់បង់សមត្ថភាពការងារមានងារជាវីរជន។

-បំ១=ប្រាក់ឧបត្ថម្ភប្រចាំខែសំរាប់អ្នកជំនួយកិច្ចការ របស់ជនបាត់បង់សមត្ថភាពការងារថ្នាក់ទី១ ត្រូវបានឧបត្ថម្ភស្មើ នឹងប្រាក់បៀវត្សឋានន្តរសក្តិសរុបផ្ទាល់ខ្លួន របស់យុទ្ធជនពលទោ។

-កំ=កំរិតភាគរយ នៃប្រាក់សោធនបាត់បង់សមត្ថភាពការងារចំណាត់ថ្នាក់ គិតលើប្រាក់បៀវត្សឋានន្តរសក្តិផ្ទាល់ខ្លួនដែលមានកំណត់ដូចតទៅ%

- ថ្នាក់ទី១ កំ = ១០០
- ថ្នាក់ទី២ កំ = ៨០
- ថ្នាក់ទី៣ កំ = ៦០

-ចំពោះ បអន សភ១៥ បជ ក ប្រ មានអត្ថន័យដូចមានកំណត់ក្នុងប្រការ ១៣ ជំពូកទី ៥

-បអន៥០=ប្រាក់សោធនបាត់បង់សមត្ថភាពការងារ អប្បបរមា៥០ភាគរយ របស់នាយទាហាន(នាយចំណង់)

-បអន៥០ប្រ= ប្រាក់សោធនបាត់បង់សមត្ថភាពការងារ អប្បបរមាសរុបប្រចាំខែ៥០ភាគរយ របស់នាយទាហាន

ប្រការ១៨: របៀបគណនា ប្រាក់សោធនបាត់បង់សមត្ថភាពការងារ ៥០ភាគរយ(សប៥០) មានដូចតទៅ៖

១-រូបមន្តប្រាក់សោធនបាត់បង់សមត្ថភាពការងារផ្ទាល់ខ្លួន ៥០ភាគរយ

$$\text{សប៥០} = \left[\frac{(\text{បផ} \times \text{៥០})}{\text{១០០}} + \frac{\text{១,៥}(\text{៤}^{\text{ន-៣}} + \text{៦}^{\text{ន-៥}})}{\text{១០០}} \right]$$

ប្រាក់សោធនបាត់បង់សមត្ថភាពការងារ ផ្ទាល់ខ្លួន៥០ភាគរយនេះ (សប៥០) សរុបមិនឱ្យលើសពី៦០ភាគរយ នៃប្រាក់សោធនបាត់បង់សមត្ថភាពការងារឡើយ ឬមិនឱ្យទាបជាង៥០ភាគរយ នៃប្រាក់បៀវត្សឋានន្តរសក្តិអប្បបរមា របស់នាយទាហានឡើយ ករណីទាបជាងត្រូវដំឡើងឱ្យស្មើ តាមមានរូបមន្ត $\text{បអន៥០} = \frac{\text{បអន} \times \text{៥០}}{\text{១០០}}$

២-រូបមន្តប្រាក់សោធនបាត់បង់សមត្ថភាពការងារ ៥០ភាគរយ សរុបប្រចាំខែមាន:

$$\text{សប៥០ប្រ} = \text{សប៥០} + \text{គំ} + \text{សភ១៥} + \text{ប្រ} + \text{ក}$$

ឬករណីប្រាក់សោធនបាត់បង់សមត្ថភាពការងារផ្ទាល់ខ្លួន ៥០ ភាគរយនេះ (សប៥០) មានកំរិតទាប ហើយត្រូវបានគេដំឡើងឱ្យស្មើ៥០ភាគរយ នៃប្រាក់បៀវត្សឋានន្តរសក្តិអប្បបរមា របស់នាយទាហាន ប្រាក់សោធនបាត់បង់សមត្ថការងារ ៥០ភាគរយសរុបប្រចាំខែ ត្រូវបានអនុវត្តតាមរូបមន្តដូចតទៅ :

$$\text{បអន៥០ប្រ} = \text{បអន៥០} + \text{គំ} + \text{សភ១៥} + \text{ប្រ} + \text{ក}$$

ប្រការ១៩: របៀបគណនាប្រាក់សោធនបាត់បង់សមត្ថភាពការងារចំណាត់ថ្នាក់

ការគណនាប្រាក់សោធនបាត់បង់សមត្ថភាពការងារចំណាត់ថ្នាក់ ត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោមនេះ:

$$\text{- ថ្នាក់ទី១} = \text{សបចំប្រ} = \frac{(\text{បផ} \times \text{កំ})}{\text{១០០}} + \text{គំ} + \text{សភ១៥} + \text{ប្រ} + \text{ក} + \text{បំ១}$$

$$\text{- ថ្នាក់ទី ២, ៣} = \text{សបចំប្រ} = \frac{(\text{បផ} \times \text{កំ})}{\text{១០០}} + \text{គំ} + \text{សភ១៥} + \text{ប្រ} + \text{ក}$$

ប្រការ២០: ចំពោះជនបាត់បង់សមត្ថភាពការងារ មានងារជាវីរជន ត្រូវទទួលបានអត្រាប្រាក់បន្ថែម ១០ ភាគរយនៃប្រាក់បៀវត្សឋានន្តរសក្តិសុទ្ធសាធមានរូបមន្ត(+អវី១០) ។

ជំពូកទី ៦

ការកែតម្រូវប្រាក់ឧបត្ថម្ភខុសសញ្ញា

ប្រការ២១: ត្រូវត្រួតពិនិត្យ ផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវ ប្រាក់ឧបត្ថម្ភគ្រួសារជនពលី-ជនមរណៈ ជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ គ្រប់ប្រភេទ គ្រប់ថ្នាក់ និងគ្រួសារ។ ក្នុងករណីមានការខុសឆ្គង ត្រូវកែសំរួលឱ្យបានសមស្រប និងត្រឹមត្រូវតាមគោលរបបកំណត់។ បើមានករណីប្តឹងតវ៉ា អំពីការគិតប្រាក់គោលនយោបាយខុស លើសឬខ្វះ កាត់បន្ថយ ឬសងវិញ ត្រូវគិតចាប់ពីថ្ងៃ ខែ ឆ្នាំដែលបានគិតខុសនោះ ។

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តក្រុង ត្រូវធ្វើសំណើសុំសេចក្តីសំរេច កែសម្រួលរបបឧបត្ថម្ភគោលនយោបាយដែលបានគិតខុសនោះ ពីរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីអនុវត្ត ។

ជំពូកទី ៧

ប្រាក់ឧបត្ថម្ភចំពោះជនពលី ជនមរណៈ ដោយបូសសើរី ដោយជម្ងឺ ឬគ្រោះថ្នាក់ធម្មតា

ប្រការ២២: ជនពិការប្រភេទ(ក)និង(ខ) និវត្តជន ជនបាត់បង់សមត្ថភាពការងារគ្រប់ថ្នាក់ បានមរណៈដោយបូសសើរីឬ ដោយជម្ងឺឬគ្រោះថ្នាក់ធម្មតា ត្រូវបានកំណត់ប្រាក់ឧបត្ថម្ភជូន តាមស្ថានភាពជម្ងឺ ឬតាមស្ថានភាពគ្រោះថ្នាក់ ។

ប្រការ២៣: ប្រាក់បូជា ឬបញ្ចុះសពជនពលីជាអតីតយោធិនពិការ បានពលីដោយបូសសើរី ឧបត្ថម្ភជាប្រាក់ចំនួន៩ខែ នៃប្រាក់ឧបត្ថម្ភគោលនយោបាយប្រចាំខែ របស់អតីតសាមីជនពិការ ។

ប្រការ២៤: ប្រាក់បូជាឬបញ្ចុះសពជនពលី ជាអតីតនគរបាលមន្ត្រីរាជការស៊ីវិលពិការ បានពលីដោយបូសសើរី ឧបត្ថម្ភជាប្រាក់ចំនួន៣ខែនៃអតីតប្រាក់បៀវត្សសរុបប្រចាំខែ របស់សាមីជនពិការ ។

ប្រការ២៥: ប្រាក់បូជា ឬបញ្ចុះសពជនពលី ជាអតីតកងសេនាជន ប្រជាជន ពិការ បានពលីដោយបូសសើរី ឧបត្ថម្ភជាប្រាក់ចំនួន៣ខែនៃប្រាក់បៀវត្សរ៍ថ្នាក់នន្តរសក្តិសរុបផ្ទាល់ខ្លួន របស់យុទ្ធជនពលីនោះ ។

ប្រការ២៦: គ្រួសារសពយោធិនពលី ឧបត្ថម្ភជាប្រាក់មួយលើកចំនួន១៥ខែ នៃប្រាក់ឧបត្ថម្ភគោលនយោបាយប្រចាំខែ របស់អតីតសាមីជនពិការ ។

ប្រការ២៧: គ្រួសារសពជនពលី ជានគរបាល មន្ត្រីរាជការស៊ីវិល ពលី ឧបត្ថម្ភជាប្រាក់មួយលើកចំនួន១៥ខែ នៃអតីតប្រាក់បៀវត្សសរុបប្រចាំខែ របស់សាមីជនពិការ(ប្រាក់ជូនដំណឹងពលីចំនួន៣ខែ និងប្រាក់ឧបត្ថម្ភមួយលើកចំនួន១២ខែ) ។

ប្រការ២៨: គ្រួសារសពជនមរណៈ ជានគរបាល មន្ត្រីរាជការស៊ីវិល កងសេនាជន និងប្រជាជន ឧបត្ថម្ភជាប្រាក់មួយលើកចំនួន៦ខែ នៃប្រាក់ឧបត្ថម្ភគោលនយោបាយប្រចាំខែ របស់សាមីជនពិការ ។

ប្រការ២៩: និវត្តជន និងជនបាត់បង់សមត្ថភាពការងារ បានមរណភាពដោយជម្ងឺ ឬប្រការផ្សេងៗ ត្រូវបានទទួលប្រាក់ធានារ៉ាប់រងសំរាប់គ្រួសារតែម្តងគត់ ស្មើនឹងប្រាក់បៀវត្ស និងប្រាក់បំណាច់របស់សាមីជន គុណនឹងចំនួន១២ខែ ។

ប្រការ៣០: គ្រួសារជនពលី ត្រូវបានទទួលប្រាក់ឧបត្ថម្ភជារៀងរាល់ខែ ដូចមានចែងក្នុងចំណុច ក ខ គ ឃ នៃប្រការ៣ ជំពូកទី២ ឯគ្រួសារជនមរណៈ ត្រូវបានទទួលប្រាក់ឧបត្ថម្ភប្រចាំខែ ដូចមានចែងក្នុងប្រការ៤ ជំពូកទី ២ ។

ប្រការ៣១: ការបំពេញបែបបទ និងសំរេចទទួលស្គាល់ជាជនពលី ជនមរណៈ និងផ្តល់ប្រាក់ឧបត្ថម្ភជូន មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ត្រូវបំពេញតាមនីតិវិធី និងបែបបទ ដូចតទៅ :

ក-ត្រូវមានលិខិតបញ្ជាក់ជាជនពលី ឬជាជនមរណៈ ពីអាជ្ញាធរឃុំសង្កាត់ ស្រុកខ័ណ្ឌ ឬពីមន្ទីរពេទ្យរដ្ឋ ផ្នែកស៊ីវិល ឬយោធា ឬនគរបាល ។

ខ-ធ្វើលិខិតស្នើសុំលុបឈ្មោះជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារ ពីបញ្ជីបើកប្រាក់ឧបត្ថម្ភប្រចាំខែ ដោយបញ្ជាក់កាលបរិច្ឆេទលុប ឱ្យបានច្បាស់លាស់មានបញ្ជីរាយនាម និងតារាងបញ្ជាក់ប្រាក់ឧបត្ថម្ភភ្ជាប់ ។

គ-ធ្វើលិខិតស្នើសុំប្រាក់ ឧបត្ថម្ភជូនជនពលី ជនមរណៈ និងគ្រួសារ ដោយមានបញ្ជីរាយនាមភ្ជាប់ ។

ឃ-ត្រូវភ្ជាប់មកជាមួយនូវសំណុំលិខិតដូចខាងក្រោម :

- លិខិតទទួលស្គាល់ជា ជនពលី ឬ ជនមរណៈ ២ ច្បាប់
- ប្រវត្តិរូបសង្ខេប ២ ច្បាប់
- តារាងបញ្ជាក់ប្រាក់ឧបត្ថម្ភប្រចាំខែ ២ ច្បាប់

ប្រការ៣២:សិទ្ធិសំរេចលុបឈ្មោះជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារនិងទទួលស្គាល់ ជាជនពលីឬជនមរណៈ និងផ្តល់របបឧបត្ថម្ភជូន ជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

ប្រការ៣៣:គ្រួសារពលី-ជនមរណៈ ជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារ មានសិទ្ធិទទួលប្រាក់ឧបត្ថម្ភប្រចាំខែមានរយៈពេល៣ខែ បន្ទាប់ពីថ្ងៃខែឆ្នាំ អស់សុពលភាពទទួលរបបឧបត្ថម្ភ ត្រូវបានលុបឈ្មោះចេញពីបញ្ជីបើកប្រាក់ ។

ជំពូកទី ៤

ការគ្រប់គ្រងគ្រួសារជនពលី-ជនមរណៈ ជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារ

ប្រការ៣៤:មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តក្រុង ត្រូវធ្វើការត្រួតពិនិត្យឡើងវិញ គ្រួសារជនពលី -ជនមរណៈ ជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារ ដែលមានឈ្មោះក្នុងសេចក្តីសំរេច ប្រកាសទទួលស្គាល់កន្លងមក ហើយដែលបាននឹងកំពុងទទួល ប្រាក់ឧបត្ថម្ភជារៀងរាល់ខែ នៅតាមបណ្តាការិយាល័យ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្រុក ខណ្ឌ ក្រោមការគ្រប់គ្រងរបស់ខ្លួន ។

ប្រការ៣៥:ការត្រួតពិនិត្យ ជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារ ត្រូវអនុវត្តដូចតទៅ :

- វត្តមានពិតប្រាកដរបស់មុខសញ្ញាផ្ទាល់
- វត្តមានពិតប្រាកដរបស់គ្រួសារ(មានឬមិនមានមនុស្សពិតប្រាកដ ដែលត្រូវជា ប្រពន្ធ ប្តីឬកូន)
- កូនមានអាយុពី ១៥ឆ្នាំ ឬ ១៨ឆ្នាំ កំពុងសិក្សា ឬមិនបានសិក្សា ។
- កូនទើបកើតថ្មី
- មុខសញ្ញាទើបតែរៀបអាពាហ៍ពិពាហ៍លើកដំបូង ហើយប្រពន្ធ ឬប្តីនោះ មិនទាន់បានបញ្ចូលឈ្មោះក្នុងបញ្ជីបើកប្រាក់ឧបត្ថម្ភប្រចាំខែ។

ប្រការ៣៦:ការត្រួតពិនិត្យ គ្រួសារជនពលី -ជនមរណៈ ត្រូវអនុវត្តដូចតទៅ:

- វត្តមានទាំងស្រុង (មានឬមិនមាន ឪពុក ម្តាយកូន ប្រពន្ធ ឬប្តី) នៃគ្រួសារជនពលី -មរណៈ
- ឪពុក ម្តាយបង្កើត បានស្លាប់
- ប្រពន្ធ ឬប្តី មានប្តីឬប្រពន្ធ ថ្មីទៀត
- កូនមានអាយុពី១៥ឆ្នាំ ឬ១៨ឆ្នាំ កំពុងសិក្សាឬមិនបានសិក្សា ។

ប្រការ៣៧:ក្រោយពីបានត្រួតពិនិត្យស្រាវជ្រាវឃើញមាន គ្រួសារពលី-មរណៈ ជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារ មិនពិតប្រាកដ កូនលើសអាយុមិនសិក្សា ឬផុតសិទ្ធិទទួលប្រាក់ឧបត្ថម្ភ ត្រូវធ្វើសំណើសុំលុបឈ្មោះ ចេញពីបញ្ជី

បើកប្រាក់ឧបត្ថម្ភប្រចាំខែ ។

បែបបទ និងនីតិវិធី នៃការលុបឈ្មោះមានដូចតទៅ :

១- លុបឈ្មោះ កូន និងបន្ទុក

២- លុបឈ្មោះមុខសញ្ញា និងគ្រួសារទាំងស្រុង

ត្រូវមានសំណុំលិខិដូចតទៅ:

១-លិខិតស្នើសុំលុបឈ្មោះ ដោយបញ្ជាក់កាលបរិច្ឆេទលុប ឱ្យបានច្បាស់លាស់

២-បញ្ជីរាយនាមមុខសញ្ញា និង គ្រួសារ ។

ប្រការ៣៨: ចំពោះការស្នើសុំបញ្ចូល ប្រាក់ឧបត្ថម្ភកូនមុខសញ្ញាទើបកើតថ្មី ឬមុខសញ្ញាទើបរៀបអាពាហ៍ពិពាហ៍គ្រាដំបូង ត្រូវមានសំណុំលិខិតដូចតទៅ:

១-លិខិតស្នើសុំបញ្ចូលឈ្មោះកូន ឬបន្ទុក (ប្រពន្ធ ឬប្តី)

២-បញ្ជីរាយនាមមុខសញ្ញានិងគ្រួសារ

៣-សំបុត្រកំណើត ១សន្លឹក (ច្បាប់ចម្លងសំរាប់កូន) ឬលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ ១សន្លឹក (ច្បាប់ចម្លងសំរាប់ប្រពន្ធ ឬប្តី)

ប្រការ៣៩: កូនរបស់មុខសញ្ញា កំពុងទទួលប្រាក់ឧបត្ថម្ភជារៀងរាល់ខែ មានអាយុពី១៥ឆ្នាំ ឬ១៨ឆ្នាំឡើងទៅ កំពុងបន្តការសិក្សា ត្រូវមានលិខិតបញ្ជាក់ពីសាលា ដែលកូននោះកំពុងសិក្សាហើយការប្រមូលយកលិខិតនេះ ត្រូវធ្វើជារៀងរាល់ឆ្នាំនៅត្រីមាសទី៤នៃឆ្នាំដើម្បីរក្សាទុកជាឯកសារ ។

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តក្រុង ត្រូវធ្វើលិខិតជូនដំណឹងឱ្យបានមុន ក្នុងអំឡុងត្រីមាស ទី៣នៃ ឆ្នាំ ផុតត្រីមាសទី៤ កូនដែលគ្មានលិខិតបញ្ជាក់ការសិក្សា ត្រូវលើកជាសំណើសុំលុបឈ្មោះចេញពីបញ្ជីបើកប្រាក់ឧបត្ថម្ភប្រចាំខែ ចាប់ពីខែមករានៃឆ្នាំបន្ទាប់ ។

ជំពូកទី ៥

លក្ខណសម្បត្តិទទួលរបបឧបត្ថម្ភគោលនយោបាយ

នៃគ្រួសារជនពលី-ជនមរណៈ ជនពិការ និងអ្នកជំងឺ ជនបាត់បង់សមត្ថភាពការងារ

ប្រការ៤០: មុខសញ្ញា និងគ្រួសារដែលបានផ្ទេរ ពីក្រសួងស្ថាប័ននានា មកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីទទួលប្រាក់ឧបត្ថម្ភ ត្រូវមានការពិនិត្យ និងកំណត់ប្រាក់ឧបត្ថម្ភ អោយបានត្រឹមត្រូវ តាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន ។

ប្រការ៤១: នាយកដ្ឋានសោធនអតីតយុទ្ធជន ត្រូវពិនិត្យបញ្ជីឈ្មោះកូនក្នុងប្រវត្តិរូបសង្ខេប មានអាយុលើសពី១៥ ឬ១៨ឆ្នាំ ហើយបញ្ជាក់ថានៅរៀន ត្រូវស្នើប្រាក់ឧបត្ថម្ភជូន តែបើមិនមានបញ្ជាក់ថារៀនទេ មិនត្រូវស្នើប្រាក់ឧបត្ថម្ភជូនឡើយ ។ ចំពោះកូននិវត្តជន ជនបាត់បង់សមត្ថភាពការងារ ដែលកើតបាន៣០០ថ្ងៃ ក្រោយពីក្រសួងការពារជាតិ ប្រកាសដាក់ឱ្យចូលនិវត្តន៍ ឬចូលបាត់បង់សមត្ថភាពការងារ ពុំទាន់បានទទួលប្រាក់ឧបត្ថម្ភ ត្រូវកំណត់ជូនតាមគោលការណ៍ និង

របបកំណត់ តែតម្រូវឱ្យកូនទាំងនោះ មានសំបុត្របញ្ជាក់កំណើត ពីអាជ្ញាធរមានសមត្ថកិច្ច។

ប្រការ៤២:មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តក្រុង ត្រូវធ្វើសំណើសុំលុបឈ្មោះកូន ដែលពុំមានលិខិតបញ្ជាក់ការសិក្សា។

ប្រការ៤៣:កូន ឬបន្ទុកគ្រួសាររបស់មុខសញ្ញា (លើកលែងឪពុកម្ដាយបង្កើតរបស់ជនពលី) ដែលមានឈ្មោះ ក្នុងប្រវត្តិរូបសង្ខេប អាចកំណត់ប្រាក់ឧបត្ថម្ភជូនបាន លុះត្រាតែស្ថានភាព ប្រវត្តិរូបសង្ខេបស្របគ្នា ជាមួយស្ថានភាព នៃលិខិតផ្ដល់ហិរញ្ញវត្ថុ ឬលិខិតបញ្ជាក់ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភប្រចាំខែ ។ ករណីផ្ទុយគ្នា កូនឬបន្ទុកទាំងនោះ មិនត្រូវកំណត់ប្រាក់ឧបត្ថម្ភជូនទេ តែបើមានការតវ៉ា ដោយសាមីជននោះ មានសំបុត្រកំណើត ឬលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ ឬសាលក្រមតុលាការ ត្រូវកំណត់ប្រាក់ឧបត្ថម្ភជូន តាមច្បាប់និងលិខិតបទដ្ឋានជាធរមាន។

ប្រការ៤៤:គ្រួសាររបស់ជនពលី ជនមរណៈ ជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ បានពិនិត្យស្រាវជ្រាវឃើញមានតែឈ្មោះ តែពុំមានមនុស្សពិតប្រាកដ ត្រូវលើកសំណើសុំលុបឈ្មោះ ចេញពីបញ្ជីបើកប្រាក់។

ជំពូកទី ១០

រូបមន្តគណនាប្រាក់ឧបត្ថម្ភគ្រួសារពលី-ជនមរណៈ ជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារ ការដកចេញ និងបន្ថែមចូល

ប្រការ៤៥:គ្រួសារជនពលី-ជនមរណៈ ជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារ ដែលផុតសិទ្ធិទទួលប្រាក់ឧបត្ថម្ភ ត្រូវបានគណនាដកប្រាក់ឧបត្ថម្ភចេញ ឯមុខសញ្ញាដែលមានលក្ខណៈសម្បត្តិកំណើនថ្មី ត្រូវបានគណនាប្រាក់ឧបត្ថម្ភបន្ថែមចូល ក្នុងបញ្ជីបើកប្រាក់ឧបត្ថម្ភប្រចាំខែ។

ប្រការ៤៦:ខ្ទង់ប្រាក់ឧបត្ថម្ភគ្រួសារជនពលី -ជនមរណៈ ត្រូវដកចេញ មានដូចតទៅ:

-កូនជនពលី មរណៈ ក្នុងម្នាក់ៗ ៤០០០រៀល

-ប្រពន្ធឬប្ដីជនពលី ៣២០០រៀល

-ឪពុកម្ដាយបង្កើតជនពលីក្នុងម្នាក់ៗ ៣២០០រៀល

ប្រការ៤៧:ខ្ទង់ប្រាក់ឧបត្ថម្ភជនពិការប្រភេទ (ក) ជាអតីតក្របខ័ណ្ឌរដ្ឋ ត្រូវដកចេញតាមរូបមន្តដូចតទៅ:

- ថ្នាក់ទី១ សបឧ = បស +ប%+ជំ +បំ១

- ថ្នាក់ទី ២,៣,៤ សបឧ = បស +ប%+ជំ

ប្រការ៤៨:ខ្ទង់ប្រាក់ឧបត្ថម្ភជនពិកាប្រភេទ (ក) ក្រៅក្របខ័ណ្ឌរដ្ឋ ត្រូវដកចេញតាមរូបមន្តដូចតទៅ:

- ថ្នាក់ទី១ សបឧ = ប%+ជំ +បំ១ +ក +ប្រ

- ថ្នាក់ទី ២,៣,៤ សបឧ = ប%+ជំ+ក+ ប្រ

ប្រការ៤៩:ខ្ទង់ប្រាក់ឧបត្ថម្ភជនពិការប្រភេទ (ខ) គ្រប់ថ្នាក់ជាអតីតយោធិន ត្រូវដកចេញតាមរូបមន្តដូចតទៅ :

សបឧ = ជំ +ប% +ក +ប្រ

ចំពោះជនពិការប្រភេទ (ខ) ជាអតីតនគរបាល ខ្ទង់ប្រាក់ត្រូវដកចេញ តាមរូបមន្តដូចតទៅ:

$$\text{សបឧ} = \frac{(\text{បធ} \times ៦៥)}{១០០} + \text{ប\%} + \text{ក} + \text{ប្រ}$$

ប្រការ៥០:ខ្វង់ប្រាក់របស់និវត្តជន ដែលទទួលរបបសោធននិវត្តន៍អប្បបរមា៥០ភាគរយ ត្រូវដកចេញតាមរូបមន្តដូចតទៅ:

$$\text{សន៥០ប្រ} = \text{សន៥០} + \text{តំ} + \text{អភ១៥ឬ២០} + \text{សភ១៥} + \text{ប្រ} + \text{ក}$$

ឬ

$$\text{បអនប្រ} = \text{បអន} + \text{តំ} + \text{អភ១៥ឬ២០} + \text{សភ១៥} + \text{ប្រ} + \text{ក}$$

ប្រការ៥១:ខ្វង់ប្រាក់ឧបត្ថម្ភរបស់និវត្តជន ដែលទទួលរបបសោធននិវត្តន៍អតិបរមា៨០ភាគរយត្រូវដកចេញ តាមរូបមន្តដូចតទៅ:

$$\text{សន៨០ប្រ} = \text{សន៨០} + \text{តំ} + \text{អភ១៥ឬ២០} + \text{សភ១៥} + \text{ប្រ} + \text{ក}$$

ឬ

$$\text{បអនប្រ} = \text{បអន} + \text{តំ} + \text{អភ១៥ឬ២០} + \text{សភ១៥} + \text{ប្រ} + \text{ក}$$

ប្រការ៥២:ខ្វង់ប្រាក់ឧបត្ថម្ភរបស់និវត្តជន មានឋានន្តរសក្តិជាឧត្តមសេនីយ ឬជាវីរជន ដែលមានរបបអ្នកបើកបរ និងកងការពារ ខ្វង់ប្រាក់ត្រូវដកចេញបន្ថែមតាមរូបមន្តរូបមន្តដូចតទៅ: (-បរ + កព) ។

ប្រការ៥៣:ខ្វង់ប្រាក់ឧបត្ថម្ភ របស់ជនបាត់បង់សមត្ថភាពការងារ ៥០ភាគរយ ត្រូវដកចេញ តាមរូបមន្តដូចតទៅ :

$$\text{សប៥០ប្រ} = \text{សប៥០} + \text{តំ} + \text{សភ១៥} + \text{ប្រ} + \text{ក}$$

ឬ

$$\text{បនអ៥០ប្រ} = \text{បអន៥០} + \text{តំ} + \text{សភ១៥} + \text{ប្រ} + \text{ក}$$

ប្រការ៥៤:ខ្វង់ប្រាក់ឧបត្ថម្ភ របស់ជនបាត់បង់សមត្ថភាពការងារចំណាត់ថ្នាក់ ត្រូវដកចេញតាមរូបមន្តដូចតទៅ:

- ថ្នាក់ទី១ $= \text{សបធំ} = \frac{(\text{បធ} \times \text{កំ})}{១០០} + \text{តំ} + \text{សភ១៥} + \text{ប្រ} + \text{ក} + \text{បំ១}$
- ថ្នាក់ទី ២, ៣ $= \text{សបធំ} = \frac{(\text{បធ} \times \text{កំ})}{១០០} + \text{តំ} + \text{សភ១៥} + \text{ប្រ} + \text{ក}$

ប្រការ៥៥:ខ្វង់ប្រាក់ឧបត្ថម្ភ របស់ជនបាត់បង់សមត្ថភាពការងារ មានងារជាវីរជន ត្រូវបានកាត់បន្ថែមអត្រា១០ ភាគរយនៃប្រាក់បៀវត្សឋានន្តរសក្តិសុទ្ធសាធ តាមរូបមន្តដូចតទៅ: (-អវី១០) ។

ប្រការ៥៦:ការដក ឬបញ្ចូលប្រាក់ឧបត្ថម្ភកូន ឬបន្ទុក របស់ជនពិការគ្រប់ប្រភេទគ្រប់ថ្នាក់ ត្រូវអនុវត្តតែក្នុងខ្វង់ប្រាក់ជំនួយមុខរបួស (ជំ) និងក្នុងខ្វង់ប្រាក់ឧបត្ថម្ភកូន (ក) ឬបន្ទុក (ប្រ) របស់ជនពិការតែប៉ុណ្ណោះ តាមវិធានដូចខាងក្រោម

ក-កូនជនពិការក្របខ័ណ្ឌរដ្ឋ ត្រូវកាត់ចេញឬបញ្ចូលបន្ថែមតាមរូបមន្ត : $\frac{(\text{ក} \times \text{កំ})}{១០០} + \text{ក}$

ខ-ប្រពន្ធ ឬប្តី របស់ជនពិការក្របខ័ណ្ឌរដ្ឋ ត្រូវកាត់ចេញ ឬ បញ្ចូលបន្ថែមតាមរូបមន្ត: $\frac{(\text{ប្រ} \times \text{កំ})}{១០០} + \text{ប្រ}$

គ-ចំពោះកូន(ក) និងបន្ទុក(ប្រ) របស់ជនពិការប្រភេទ (ក) ក្រៅក្របខ័ណ្ឌរដ្ឋឬរបស់ជនពិការប្រភេទ (ខ) និងនិវត្តជន ជនបាត់បង់សមត្ថភាពការងារ ការដកប្រាក់ឬបញ្ចូលប្រាក់ ត្រូវគិតតែក្នុងខ្វង់ ប្រាក់ឧបត្ថម្ភកូន(ក) ឬបន្ទុក (ប្រ) តែប៉ុណ្ណោះ

ជំពូកទី ១១

ការផ្ទេរប្រាក់ឧបត្ថម្ភគ្រួសារពលី-ជនមរណៈ ជនពិការ និវត្តជន និងជនបាត់បង់ សមត្ថភាពការងារ ពីខេត្តក្រុងមួយ ទៅខេត្តក្រុងមួយទៀត

ប្រការ៥៧:ការផ្ទេរត្រូវធ្វើឡើង២ដងក្នុង១ឆ្នាំ គឺក្នុងខែមករា និងក្នុងខែកក្កដា ។ អ្នកស្នើសុំផ្ទេរក្នុងខែមករា ត្រូវបានបើកប្រាក់

ឧបត្ថម្ភប្រចាំខែ នៅខែកក្កដា ឯអ្នកសុំផ្ទេរក្នុងខែកក្កដា ត្រូវបើកប្រាក់ឧបត្ថម្ភ នៅខែមករានៃឆ្នាំបន្ទាប់ នៅខេត្តក្រុងដែលខ្លួនស្នើសុំ ។

ការសម្រេចឱ្យផ្ទេរមុខសញ្ញា ពីខេត្តក្រុងមួយ ទៅខេត្តក្រុងមួយផ្សេងទៀត ត្រូវកំណត់ដោយប្រកាស របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

ប្រការ៥៨: បែបបទនិងនីតិវិធីផ្ទេរមានកំណត់ដូចតទៅ:

គ្រួសារជនពលី-ជនមរណៈ ជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារនិងគ្រួសារត្រូវមានលិខិតស្នើសុំមកមន្ទីរ តាមរយៈការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្រុកខណ្ឌ តាមគំរូណែនាំ។ ផ្អែកតាមលិខិតស្នើសុំ របស់សាមីខ្លួន មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តក្រុង ត្រូវធ្វើលិខិតស្នើសុំមកក្រសួង ដោយភ្ជាប់មកជាមួយនូវ:

- សំណុំលិខិត និងឯកសារពាក់ព័ន្ធទាំងអស់
- សៀវភៅបើកប្រាក់ឧបត្ថម្ភប្រចាំខែ

ថិរវេលានៃការបំពេញបែបបទផ្ទេរនេះ ត្រូវបានកំណត់ដូចតទៅ:

-ចាប់ពីពេលទទួលពាក្យស្នើសុំផ្ទេរ និងការបំពេញបែបបទ ពីថ្នាក់ស្រុកមកខេត្ត មានថិរវេលា៧ថ្ងៃ

-ពីថ្នាក់ខេត្តមកក្រសួង មានថិរវេលា១៥ថ្ងៃ

-ថ្នាក់ក្រសួងពិនិត្យ និងបំពេញបែបបទតាមនីតិវិធី និងសម្រេចចេញប្រកាសផ្ទេរ មានថិរវេលា២០ថ្ងៃ ។

ជំពូកទី ១២

ការគ្រប់គ្រងសៀវភៅបើកប្រាក់ឧបត្ថម្ភនិងប័ណ្ណសំគាល់

គ្រួសារពលី-ជនមរណៈ ជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ

ប្រការ៥៩: សៀវភៅបើកប្រាក់ឧបត្ថម្ភ និងប័ណ្ណសំគាល់គ្រួសារពលី-ជនមរណៈ ជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារ ត្រូវសរសេរបំពេញដោយ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តក្រុង តាមប្រកាសទទួលស្គាល់មុខសញ្ញា និងសំណុំលិខិតឯកសាររបស់ក្រសួង។

ប្រការ៦០: មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តក្រុង ត្រូវធ្វើលិខិតស្នើសុំហត្ថលេខានិងត្រា លើសៀវភៅបើកប្រាក់ឧបត្ថម្ភ និងប័ណ្ណសំគាល់មកក្រសួង ដោយភ្ជាប់មកជាមួយ បញ្ជីរាយនាមមុខសញ្ញានិងគ្រួសារ។ ចំពោះសៀវភៅបើកប្រាក់ឧបត្ថម្ភបានប្រើប្រាស់អស់ទំព័រ ត្រូវធ្វើលិខិតស្នើសុំដូរថ្មី ដោយភ្ជាប់មកជាមួយសៀវភៅចាស់មកផង។

ប្រការ៦១: សៀវភៅបើកប្រាក់ឧបត្ថម្ភ ត្រូវរក្សាទុកនៅកន្លែងបើកប្រាក់។ ពេលមុខសញ្ញាមកបើកប្រាក់ ត្រូវឱ្យមានផ្តិតមេដៃ ឬចុះហត្ថលេខាទទួលតាមខ្ទង់នៃខែឆ្នាំនីមួយៗ។

ប័ណ្ណសំគាល់មុខសញ្ញា និងគ្រួសារ ត្រូវប្រគល់ឱ្យសាមីជន ឬគ្រួសារប្រើប្រាស់ ពេលមកបើកប្រាក់ ឬក្នុងករណីដែលអាចប្រើបាន ។

ប្រការ៦២: សៀវភៅបើកប្រាក់ឧបត្ថម្ភ និងប័ណ្ណសំគាល់ ត្រូវគ្រប់គ្រង និងប្រើប្រាស់ឱ្យបានល្អ ពេលមានការខូចខាត ឬបាត់បង់ ត្រូវរាយការណ៍ ឱ្យបានទាន់ពេលវេលា និងច្បាស់លាស់ ដើម្បីក្រសួងពិនិត្យ និងផ្តល់លទ្ធភាពចេញ ឱ្យប្រើប្រាស់

ជាលើកទី២។

ជំពូកទី ១៣
ការគ្រប់គ្រងថវិកាសោធនអតីតយុទ្ធជន

ប្រការ១៦៣:ថវិកាសោធនអតីតយុទ្ធជន ត្រូវបានរៀបចំនិងដាក់ឱ្យប្រតិបត្តិ ដោយផ្អែកលើមូលដ្ឋាននៃច្បាប់ហិរញ្ញវត្ថុ និងប្រព័ន្ធថវិការដ្ឋ ស្របតាមស្ថានភាពជាក់ស្តែង និងធានាបាននូវដំណើរការ បើកជូនមុខសញ្ញាបានទៀងទាត់ ត្រឹមត្រូវ មានតម្លាភាព និងទាន់ពេលវេលា។

ប្រការ១៦៤:រាល់គម្រោងថវិកាឆ្នាំ នាយកដ្ឋានសោធនអតីតយុទ្ធជន ត្រូវរៀបចំ ដោយប្រមូលផ្តុំ សរុបសំរួលគំរោង ផែនការចំណាយ ក៏ដូចជាការកែតម្រូវថវិកា បញ្ចូលក្នុងផែនកាថវិការបស់ក្រសួង ។ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តក្រុង ត្រូវមានផែនការកម្មវិធីចំណាយ ការកែតម្រូវថវិកា សំរាប់មុខសញ្ញា ចំណុះការគ្រប់គ្រងរបស់ខ្លួន បញ្ជូនមកនាយកដ្ឋានសោធនអតីតយុទ្ធជន ធ្វើការបូកសរុបអោយបានទៀងទាត់ តាមពេលវេលា កំណត់។

ប្រការ១៦៥:ផែនការ កម្មវិធី ចំណាយថវិកា សំរាប់មុខសញ្ញា ត្រូវបានគ្រោង និងរៀបចំដោយផ្អែកលើលទ្ធផល និងសកម្មភាពការងារដែលបានអនុវត្តកន្លងមក កំពុងអនុវត្ត និងតាមបណ្តាស្ថិតិតួលេខ ដែលក្រសួងស្ថាប័ននានា បានផ្តល់ជូន និងការប៉ាន់ស្មាននូវលទ្ធភាពអនុវត្តទៅខាងមុខ។ ការរៀបចំនេះ ត្រូវផ្អែកលើនីតិវិធីនិងបែបបទ នៃគោលរបបឧបត្ថម្ភ របស់មុខសញ្ញា តាមជំពូក ប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ នៃវិធានហិរញ្ញវត្ថុ ស្របតាមច្បាប់ និងបទបញ្ជាថវិកា ដែលរដ្ឋបានកំណត់ ។

ប្រការ១៦៦:គម្រោងស្នើសុំចំណាយឥណទាន សោធនអតីតយុទ្ធជន ត្រូវអនុវត្តតាមផែនការ ដែលមានចែងក្នុងសៀវភៅថវិកា ស្របតាមច្បាប់ហិរញ្ញវត្ថុ និងប្រព័ន្ធថវិកា តាមនីតិវិធី និងបែបបទ នៃគោលរបបឧបត្ថម្ភមុខសញ្ញា និងតាមមាត្រាកំណត់នៃប្រកាសទទួលស្គាល់មុខសញ្ញារបស់ក្រសួង។

នាយកដ្ឋានសោធនអតីតយុទ្ធជន ត្រូវលើកគំរោងស្នើសុំសេចក្តីសំរេចពីរដ្ឋមន្ត្រី។

ប្រការ១៦៧:ឥណទានសោធនអតីតយុទ្ធជន ផ្តល់ការចំណាយសំរាប់តែលើការងារអតីតយុទ្ធជន និងគ្រួសារដែលមានប្រកាសទទួលស្គាល់និងកំណត់របបឧបត្ថម្ភត្រឹមត្រូវ តាមគោលការណ៍កំណត់។ ការបង្វែរឥណទាននេះ ចំណាយលើវិស័យ ផ្សេងៗបានលុះត្រាតែស្ថានភាពឥណទាននេះ លើសពីតម្រូវការចាំបាច់នៃមុខសញ្ញា និងដោយមានការយល់ព្រម ពីរដ្ឋមន្ត្រី ។

ប្រការ១៦៨:ប្រាក់ឧបត្ថម្ភប្រចាំខែ ត្រូវបើកឱ្យបានទៀងទាត់ តាមពេលវេលាកំណត់។ សាមីជនមកបើកប្រាក់ ត្រូវបង្ហាញលិខិតឬប័ណ្ណទទួលស្គាល់ ជូនភ្នាក់ងារបើកផ្តល់។ ក្នុងករណី ដែលក្រសួងផ្តល់សៀវភៅ និងប័ណ្ណទទួលស្គាល់ មិនទាន់ពេលវេលា មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តក្រុង ត្រូវចេញលិខិតបញ្ជាក់បណ្តោះអាសន្ន ឱ្យសាមីជនប្រើប្រាស់ដើម្បីបើកប្រាក់។ ត្រូវមានបញ្ជីរាយនាមអ្នកទទួលប្រាក់ និងសៀវភៅបើកប្រាក់ឧបត្ថម្ភ ដោយឱ្យសាមីជនផ្តិតមេដៃឬចុះហត្ថលេខាទទួលត្រឹមត្រូវ ។

ប្រការ១៦៩:ការបើកប្រាក់ឧបត្ថម្ភគ្រាដំបូង ឬប្រាក់រំលឹក ត្រូវបានធ្វើឡើងនៅពេល មានសាច់ប្រាក់គ្រប់គ្រាន់ ធានាបាននូវការបើកជូនមុខសញ្ញាតាមចំនួនកំណត់។ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តក្រុង ត្រូវកំណត់ទីកន្លែង និង

ពេលវេលាឱ្យបានពិតប្រាកដ ច្បាស់លាស់ និងធ្វើសេចក្តីជូនដំណឹង ដល់មុខសញ្ញានិងក្រសួង ដើម្បីចាត់តាំងមន្ត្រីជំនាញចូលរួមពិនិត្យការបើកផ្តល់ ។

ប្រការ៧០: ការបើកប្រាក់ឧបត្ថម្ភជូនមុខសញ្ញា ត្រូវប្រគល់ជូនដល់ដៃត្រឹមត្រូវនិងគ្រប់ចំនួន។ សាមីជនមុខសញ្ញាទទួលប្រាក់ ត្រូវរាប់ឱ្យគ្រប់ចំនួនទើបទទួលយក។ មិនត្រូវឱ្យមានសកម្មភាព រៃអង្គាស បដិភាគទាន ឬកាត់កង ប្រាក់ឧបត្ថម្ភរបស់មុខសញ្ញា។ ករណីសាមីជនមានធុរៈធ្ងន់ធ្ងរ មិនអាចមកបើកបាន ត្រូវមានលិខិតផ្ទេរសិទ្ធិ ឱ្យអ្នកមកបើកជំនួសដោយមានលិខិតបញ្ជាក់ពីមេឃុំ ឬចៅសង្កាត់។ ភ្នាក់ងារបើកប្រាក់ ត្រូវដកលិខិតផ្ទេរសិទ្ធិ រក្សាទុកជាឯកសារ។

ការទិញ ការលក់របបឧបត្ថម្ភគោលនយោបាយ របស់អតីតយុទ្ធជនគ្រប់ប្រភេទ ត្រូវហាមឃាត់។

ប្រការ៧១: ប្រាក់ឧបត្ថម្ភគោលនយោបាយ សោធនអតីតយុទ្ធជន ត្រូវបើកជូនមុខសញ្ញា នៅតាមការិយាល័យ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្រុកខណ្ឌ។ ការិយាល័យនេះ ត្រូវធ្វើបញ្ជីរាយនាមមុខសញ្ញា ការដក និងការទូទាត់ប្រាក់ដោយមានការត្រួតពិនិត្យ និងផ្តល់មតិត្រឹមត្រូវ ពីការិយាល័យ អតីតយុទ្ធជនខេត្តក្រុង (ផ្នែកសោធនអតីតយុទ្ធជន) មុនដាក់ជូនថ្នាក់ដឹកនាំ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុងសំរេច ។

ជំពូកទី១៤

បទបញ្ញត្តិរួម

ប្រការ៧២: នាយកដ្ឋានសោធនអតីតយុទ្ធជន ពេលទទួលបានលិខិតឯកសារមុខសញ្ញា ពីក្រសួងស្ថាប័ន ឬខេត្តក្រុង ត្រូវពិនិត្យលិខិតឯកសារនោះ តាមបែបបទនីតិវិធីនិងគោលការណ៍បានកំណត់ ។ រាល់លិខិតឬសំណុំឯកសារពាក់ព័ន្ធ នឹងការងារអតីតយុទ្ធជន ផ្ញើមកនាយកដ្ឋានសោធនអតីតយុទ្ធជន ។ ចំពោះលិខិតឯកសារទាំងឡាយណា ខុសពីនីតិវិធី និងបែបបទគោលការណ៍កំណត់ នាយកដ្ឋានត្រូវធ្វើរបាយការណ៍ និងស្នើសុំយោបល់សំរេចពីរដ្ឋមន្ត្រី ។

ប្រការ៧៣: មុខសញ្ញានិងគ្រួសារ ដែលទទួលប្រាក់ឧបត្ថមគោលនយោបាយបាន លុះត្រាតែមានសំណុំលិខិត និងឯកសារដូចតទៅ:

១-ប្រកាសទទួលស្គាល់ និងផ្តល់របបគោលនយោបាយមុខសញ្ញា ដែលបានចុះហត្ថលេខាជាផ្លូវការ ពីរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬថ្នាក់ដឹកនាំក្រសួង ដែលបានទទួលសិទ្ធិប្រទាន ។

២-តារាងឧបសម្ព័ន្ធនៃបញ្ជីរាយនាមមុខសញ្ញា ដែលត្រូវបានទទួលប្រាក់ឧបត្ថម្ភគោលនយោបាយ ត្រូវមានហត្ថលេខាពីប្រធានការិយាល័យជំនាញ ប្រធាននាយកដ្ឋាន សោធនអតីតយុទ្ធជន និងរដ្ឋមន្ត្រី ឬថ្នាក់ដឹកនាំដែលបានទទួលសិទ្ធិប្រទាន ។

៣-សំណុំលិខិតឯកសារផ្ទាល់ខ្លួនរបស់មុខសញ្ញា ដែលចេញដោយក្រសួងឬស្ថាប័នដើម ។

ប្រការ៧៤: មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តក្រុង ក្រោយពីបានទទួល ប្រកាសទទួលស្គាល់ និងផ្តល់ប្រាក់ឧបត្ថម្ភគោលនយោបាយចំពោះមុខសញ្ញា តារាងឧបសម្ព័ន្ធនៃបញ្ជីរាយនាមមុខសញ្ញា ដែលត្រូវទទួលប្រាក់ឧបត្ថម្ភ និងសំណុំលិខិតឯកសារមុខសញ្ញាពីក្រសួង ត្រូវធ្វើការត្រួតពិនិត្យ និងអនុវត្តតាមនីតិវិធី និងបែបបទបានកំណត់។

ប្រការ៧៥: ចំពោះមុខសញ្ញាថ្មី គ្រប់ប្រភេទ គ្រប់ថ្នាក់ ដែលក្រសួងចេញប្រកាសទទួលស្គាល់ និងផ្តល់ប្រាក់ឧបត្ថម្ភគោលនយោបាយ ការិយាល័យអតីតយុទ្ធជនខេត្តក្រុង (ផ្នែកសោធនអតីតយុទ្ធជន) ជាសេនាធិការឱ្យមន្ទីរ ត្រូវធ្វើការ

ស្រាវជ្រាវ ពិនិត្យអង្កេតវត្តមានមុខសញ្ញា និងគ្រួសារ តាមមូលដ្ឋានជាក់ស្តែង។ មុខសញ្ញានិងគ្រួសារ មានវត្តមានពិតប្រាកដ ត្រូវរៀបចំបែបបទលិខិតស្នាម និងលើកគម្រោងស្នើសុំថវិកា បើកជូនតាមរបបកំនត់។ ឯមុខសញ្ញាដែលពុំមានវត្តមាន ត្រូវធ្វើរបាយការណ៍ជូនក្រសួង។ មុខសញ្ញាអវត្តមាន ត្រូវព្យួរឈ្មោះក្នុងរយៈពេល៣ខែ ក្នុងរយៈពេលនេះ មន្ទីរត្រូវធ្វើសេចក្តីជូនដំណឹងតាមលំនៅស្ថាន និងអាជ្ញាធរដែនដី ចំនួន៣ដង ដើម្បីបានជ្រាប។ ផុតរយៈពេល៣ខែនេះ បើគ្មានដំណឹងឬគ្មានវត្តមាន ត្រូវលើកជាសំណើមកក្រសួង ដើម្បីលុបឈ្មោះចេញពីបញ្ជី បើកប្រាក់។

ប្រការ៧៦: សាមីមុខសញ្ញាឬគ្រួសារដែលបានលុបឈ្មោះ ហើយបានមកបង្ហាញខ្លួនវិញ ដោយមានលិខិតបញ្ជាក់ ពីអាជ្ញាធរឃុំ សង្កាត់ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវលើកជាសំណើមកក្រសួង ដើម្បីចេញប្រកាសទទួលស្គាល់និងផ្តល់របបឧបត្ថម្ភជូនវិញ ចាប់ពីថ្ងៃខែឆ្នាំ ដែលក្រសួងស្ថាប័នដើមបានកំណត់។

ប្រការ៧៧: រៀងរាល់ខែ ត្រីមាស ឆមាស និងឆ្នាំ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ការិយាល័យអតីតយុទ្ធជនខេត្តក្រុង(ផ្នែកសោធនអតីតយុទ្ធជន) ត្រូវធ្វើរបាយការណ៍ បូកសរុបលទ្ធផលអនុវត្តការងារ ស្ថានភាពទូទៅរបស់មុខសញ្ញា ការបើកប្រាក់ឧបត្ថម្ភ និងស្ថានភាពថវិកា ជូននាយកដ្ឋានសោធនអតីតយុទ្ធជន ដើម្បីបូកសរុបលទ្ធផល ជូនក្រសួង។ ក្នុងករណីសំខាន់ចាំបាច់ ត្រូវឡើងមករាយការណ៍ ផ្ទាល់បន្ទាន់។

រៀងរាល់ ឆមាស និងឆ្នាំ នាយកដ្ឋានសោធនអតីតយុទ្ធជន ត្រូវសហការជាមួយ នាយកដ្ឋាននានា និងអង្គភាពចំណុះក្រសួង រៀបចំកម្មវិធីប្រជុំដកពិសោធន៍ លើការអនុវត្តការងារចំណុចខ្លាំងខ្សោយ ដោយមានការចូលរួមពីថ្នាក់ដឹកនាំមន្ទីរ ការិយាល័យអតីតយុទ្ធជនខេត្តក្រុង ស្រុកខ័ណ្ឌ(ផ្នែកសោធនអតីតយុទ្ធជន) និងតំណាងក្រសួងពាក់ព័ន្ធ ចូលរួម។ ត្រូវមានការលើកសរសើរចំពោះ បុគ្គល អង្គភាព ដែលអនុវត្តមានស្នាដៃល្អ សំរេចបានតាមផែនការនិងគោលការណ៍កំណត់

ប្រការ៧៨: នាយកដ្ឋាន សោធនអតីតយុទ្ធជន មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា ខេត្តក្រុង ត្រូវមានកម្មវិធីផ្សព្វផ្សាយនូវគោលការណ៍ គោលនយោបាយ ច្បាប់ អនុក្រឹត្យ ប្រកាស សេចក្តីសំរេច សារាចរ សេចក្តីណែនាំពាក់ព័ន្ធជាមួយការអនុវត្ត របបឧបត្ថមគោលនយោបាយមុខសញ្ញា ឬការងារផ្សេងៗ សំដៅរក្សានូវនិរន្តរភាព ការងារសោធនអតីតយុទ្ធជននិងដើម្បីលើកកំពស់នូវគុណភាព សមត្ថភាពមន្ត្រីរាជការ ក្នុងការអនុវត្តការងារ។ ត្រូវធ្វើការអប់រំចំពោះមន្ត្រីសោធនអតីតយុទ្ធជនគ្រប់ថ្នាក់ ឱ្យមានសីលធម៌ អាកប្បកិរិយាល្អ និងមានស្មារតីស្មោះត្រង់ ក្នុងការបំពេញភារកិច្ចការបើកប្រាក់ឧបត្ថម្ភមុខសញ្ញា។ ត្រូវមានការលើកទឹកចិត្ត ដោយសរសើរ និងជូនរង្វាន់ ចំពោះមន្ត្រីរាជការសោធនអតីតយុទ្ធជនណា ដែលសកម្មក្នុងការអនុវត្តការងារបានល្អ ។ ទន្ទឹមនឹងនោះ ត្រូវមានវិធានការណ៍យ៉ាងម៉ឺងម៉ាត់ ជាក់ស្តែងស្របតាមច្បាប់ជាធរមាន ចំពោះមន្ត្រីអសកម្មទាំងឡាយណា ដែលបានប្រព្រឹត្តផ្ទុយ ពីនីតិវិធី និងគោលការណ៍ ច្បាប់។

ប្រការ៧៩: នាយកដ្ឋាន សោធនអតីតយុទ្ធជន មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បាទា ខេត្តក្រុង ត្រូវសហការ ឱ្យបានល្អក្នុងការពិនិត្យ និងដោះស្រាយគ្រប់បញ្ហា និងបាតុភាព ដែលកើតមានលើការងារអតីតយុទ្ធជន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងផ្ទាល់។ ត្រូវធ្វើរបាយការណ៍ ព្រមទាំងលើកវិធានការ អនុវត្តជាក់ស្តែង និងបំភ្លឺនូវគ្រប់បញ្ហានានា ជូនថ្នាក់ដឹកនាំក្រសួងផ្ទាល់ ឬក៏ក្រសួងស្ថាប័នរដ្ឋពាក់ពន្ធ័នានា ។

ប្រការ៨០: ករណីមានការទាមទារ តវ៉ា ពីបណ្តាមុខសញ្ញាតាមបែបបទជាលាយលក្ខអក្សរ ឬក៏តាមការជួបតវ៉ាដោយផ្ទាល់ មានលក្ខណៈជាពួកក្រុម ឬបុគ្គលផ្ទាល់នៅទីកន្លែងណា មន្ទីរ ឬការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត

ក្រុង ស្រុកខណ្ឌនោះ ត្រូវពិនិត្យដោះស្រាយនិងបំភ្លឺជូនតាមករណីនីមួយៗ ស្របតាមគោលការណ៍និងច្បាប់ជាធរមាន។ ត្រូវសហការណ៍ឱ្យបានល្អជិតស្និទ ជាមួយអាជ្ញាធរដែនដីគ្រប់ថ្នាក់ និងគ្រប់ស្ថាប័នអង្គភាពមានសមត្ថកិច្ច រាំងខ្ទប់ឱ្យបាន នូវសកម្មភាពទាំងឡាយណា ដែលបង្កផលប៉ះពាល់ដល់គោលនយោបាយ និងកិត្យានុភាពនៃការដឹកនាំរបស់ រាជរដ្ឋាភិបាលកម្ពុជា។

ជំពូកទី ១៥

អវសានបញ្ញត្តិ

ប្រការ៤៦: បទបញ្ញត្តិទាំងឡាយណា ផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ៤៧: ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

អ៊ិត សំហេង

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទៀ បាញ់
- ក្រសួងការពារជាតិ
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់សាលាខេត្ត ក្រុង
- ឯកសារ កាលប្បវត្តិ